ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមការងារបច្ចេកទេស
សំរាប់វិស័យកសិកម្ម និង ទឹក

# យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និង ទឹក
# (ឆ្នាំ ២០០៦-២០១០)

រៀបចំដោយ ក្រុមយុទ្ធសាស្ត្រ B1

ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ របស់រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណង ជាអាទិភាព ដើម្បីសំរេចឱ្យបាន នូវការកាត់បន្ថយភាពក្រីក្រ និង កំណើនសេដ្ឋកិច្ច ។ ប្រការនេះ គឺត្រូវមានការ អភិវឌ្ឍន៍ដ៏រឹងមាំ នៅតាមតំបន់ជនបទ ដែលមានប្រជាជនប្រមាណ ៨៥% រស់នៅ ។ កិច្ចអភិវឌ្ឍន៍វិស័យ កសិកម្ម និងកសិ-ធុរកិច្ច ការគ្រប់គ្រងដីធ្លី និង ធនធានទឹក និង កិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ដែលហៅ ដោយខ្លីថា "វិស័យកសិកម្ម និង ទឹក " នឹងជាកត្តាដ៏សំខាន់មួយ សំរាប់ការអភិវឌ្ឍន៍នេះ ។

សកម្មភាព និង គំរោងមួយចំនួនធំ ត្រូវបានស្នើរឡើងរួចហើយ សំរាប់វិស័យកសិកម្ម និង ទឹកនេះ ដែល ជាការរួមចំណែកដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺផ្អែកលើ "អភិក្រមវិស័យ" ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង ក្រសួងនានាជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា បានលើក ជាគំរោងឡើង ដោយមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និង ឧតុនិយម ចូលរួមយ៉ាងសំខាន់ជាស្ថាប័ននាំមុខ នៅក្នុងវិស័យរបស់ខ្លួននេះ ។ ទោះជាយ៉ាងនេះក៏ដោយ កសិកម្ម និងទឹក គឺជា វិស័យមួយដែលមានសកម្មភាពទូលំទូលាយ ហើយជាប់ទាក់ទងទៅនឹងផ្នែកជាច្រើនទៀតនៃសង្គម សេដ្ឋកិច្ច និង បរិស្ថាន ។ ដូច្នេះ អភិក្រមវិស័យ អាចផ្តល់អត្ថប្រយោជន៍ជាច្រើន ជាពិសេស ក្នុងការជំរុញដល់ការប្រើប្រាស់ ធនធាន ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាព និងការសំរបសំរួលរវាងបណ្តាភាគីពាក់ព័ន្ធទាំងអស់ ។ ក្រុមការងារបច្ចេកទេស សំរាប់វិស័យកសិកម្ម និងទឹក ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយ ដល់ការសំរបសំរួលក្នុងវិស័យនេះ ។

ក្រុមការងារបច្ចេកទេស សំរាប់វិស័យកសិកម្ម និងទឹក មានភារកិច្ចក្នុងការរៀបចំនូវយុទ្ធសាស្ត្រសំរាប់ វិស័យកសិកម្ម និងទឹក ដើម្បីឆ្លើយតបទៅនឹងគោលដៅជាក់លាក់មួយ របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុង កំលុងឆ្នាំ ២០០៦ ។ ក្រុមរៀបចំយុទ្ធសាស្ត្រ បាន និងកំពុងធ្វើការវិភាគ ដែលចាំបាច់ សំរាប់រៀបចំយុទ្ធសាស្ត្រនេះ ចាប់តាំងពីខែ មករា ឆ្នាំ ២០០៦ មកម្ល៉េះ ។ ឯកសារនេះ គឺជាសមិទ្ធិផលដ៏សំខាន់មួយ ក្នុងចំណោមសមិទ្ធិផល សំខាន់នានា នៃការងាររបស់ក្រុមនេះ ។ ឯកសារនេះ នឹងត្រូវបានបញ្ជាក់បន្ថែម ដោយក្របខ័ណ្ឌកម្មវិធីជា យុទ្ធសាស្ត្រមួយ ដែលកំណត់យ៉ាងលំអិតនូវកិច្ចការដែលត្រូវអនុវត្តន៍ជាក់ស្តែង ។

យើងកំពុងស្ថិតនៅក្នុងដំណាក់កាលមួយ ដែលមានលក្ខណៈអំណោយផលល្អ សម្រាប់ការអភិវឌ្ឍន៍ក្នុង វិស័យកសិកម្ម និងធនធានទឹក ។ នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន រាជរដ្ឋាភិបាលបានទទួលស្គាល់ នូវសារៈសំខាន់នៃវិស័យកសិកម្ម និងទឹក ចំពោះកិច្ចអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ហើយដៃគូរអភិវឌ្ឍន៍ខាងក្រៅ មួយចំនួន ក៏ចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការជួយគាំទ្រ ដល់កិច្ចអភិវឌ្ឍន៍របស់កម្ពុជា ក្នុងវិស័យទាំងនេះផងដែរ ។

ភាគីដែលពាក់ព័ន្ធជាក់ស្តែង ពោល គឺកសិករ និងសហាគមន៍ជនបទ បានប្រាប់ក្រុមអ្នកធ្វើអង្កេតដូចៗគ្នាថា ការគ្រប់គ្រងកសិកម្ម និង ទឹកឱ្យបានល្អប្រសើរនោះ គឺជាតំរូវការចំបងមួយ ក្នុងចំណោមតំរូវការសំខាន់ៗចំនួនពីរ ឬ បី របស់ពួកគេនោះ ។ ហើយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអភិបាលកិច្ចល្អ ជាពិសេសតាមរយៈ គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ បានផ្តល់នូវមូលដ្ឋានសំខាន់មួយ សំរាប់កិច្ចអភិវឌ្ឍន៍នៅថ្នាក់ "មូលដ្ឋាន" នៅតាមសហគមន៍ជនបទ ដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធបំផុត ក្នុងវិស័យកសិកម្ម និងទឹក ។

យើងទន្ទឹងចង់ឃើញនូវការរួមចំណែករបស់យុទ្ធសាស្ត្រនេះ ក្នុងការជំរុញដល់កិច្ចអភិវឌ្ឍន៍របស់ជាតិ ក្នុង រយៈពេលឆ្នាំ ២០០៦-២០១០ និង ក្នុងការធ្វើផែនការ សំរាប់កិច្ចអភិវឌ្ឍន៍នៅក្នុងបណ្តាឆ្នាំខាងមុខៗទៀត ។

ភ្នំពេញ ថ្ងៃទី ............................................

**រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **ក្រសួងធនធានទឹក និង ឧតុនិយម**

**អត្ថបទសង្ខេប:**

## យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និង ទឹក

## ១. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ បានទាមទារអោយមានការបង្កើតនូវយុទ្ធសាស្ត្រមួយ សំរាប់វិស័យកសិកម្ម និង ទឹក ។ នៅពេលដែលយុទ្ធសាស្ត្រនេះ ត្រូវបានអនុម័តហើយនោះ ដំណាក់កាលបន្ទាប់ទៀតនោះ គឺត្រូវរៀបចំនូវកម្មវិធីលំអិត សំរាប់ការអនុវត្តន៍ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានកំណត់អាទិភាពរបស់ជាតិ លើការកាត់បន្ថយភាពក្រីក្រ និងការពង្រីកនូវកំណើនសេដ្ឋកិច្ច ។ ការយកចិត្តទុកដាក់សំខាន់ទីមួយ គឺលើការពង្រីកវិស័យកសិកម្ម ។ ការយកចិត្តទុកដាក់មួយទៀត គឺលើការស្តារឡើងវិញ និងកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយរួមទាំងការគ្រប់គ្រងធនធានទឹក និងប្រពន្ធ័ធារាសាស្ត្រ ដែលជាផ្នែកមួយ ក្នុងចំណោមផ្នែកទាំងបួន របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

## ២. បរិយាកាសគោលនយោបាយ និង ស្ថាប័ន

បរិយាកាសគោលនយោបាយរួម សំរាប់កសិកម្ម និងទឹក ត្រូវបានកំណត់ ជាពិសេស ដោយយុទ្ធសាស្ត្រជាតិ សំរាប់កាត់បន្ថយភាពក្រីក្រ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានតំរូវឱ្យក្រសួងនានា ធ្វើការរៀបចំផែនការ ក្នុងលក្ខណ: តាមវិស័យ និងមានការទំនាក់ទំនងគ្នា ។ ជាងនេះទៅទៀត ក្របខ័ណ្ឌការងារជាយុទ្ធសាស្ត្រ សំរាប់ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ បានជំរុញដល់ការផ្ទេរនូវការទទួលខុសត្រូវ និងធនធាន ដល់ថ្នាក់ខេត្ត ។

ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនាំមុខក្នុងវិស័យកសិកម្ម និងទឹក គឺមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ដោយឡែក១ពីគ្នា ។ យុទ្ធសាស្ត្រនេះ នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតៀងគរ និងណែនាំដល់ការគាំទ្រក្នុងវិស័យកសិកម្ម និងទឹក ពីបណ្តាអ្នកផ្តល់ជំនួយពីខាងក្រៅ (ឬអ្នកផ្តល់ជំនួយ) ។ កសិកម្ម និងទឹក គឺមានសារៈសំខាន់ ជាពិសេស ដល់ការងារនៅថ្នាក់មូលដ្ឋានក្នុងតំបន់ជនបទ ដូចនេះ អ្នកពាក់ព័ន្ធសំខាន់ៗ គឺមានរដ្ឋបាលថ្នាក់ស្រុក និង ខេត្ត អង្គការដែលមាន មូលដ្ឋាននៅក្នុងសហគមន៍ អង្គការក្រៅរដ្ឋាភិបាលនានា និងគ្រួសារនៅទីជនបទ ។

## ៣. ការវិភាគ ជាយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និង ទឹក ត្រូវបានរៀបចំឡើងដោយផ្អែកជាសំខាន់ លើការវិភាគយ៉ាងល្អិតល្អន់ លើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងភាពគំរាមកំហែង (SWOT) ។ គុណសម្បត្តិ ជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា គឺមានធនធានធម្មជាតិ និង ធនធានពលកម្ម ដែលបច្ចុប្បន្ន មិនទាន់បានប្រើប្រាស់អស់នៅឡើយ ។ កាលានុវត្តភាពសំខាន់ៗ គឺទាក់ទងទៅនឹងទីផ្សារក្នុងស្រុក និងការនាំចេញ សំរាប់ផលិតផលកសិកម្ម ។

## ៤. ទស្សនៈវិស័យ និង គោលដៅ សំរាប់វិស័យកសិកម្ម និង ទឹក

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម សំរាប់កសិកម្ម និង ធនធានទឹក ផ្តល់នូវទស្សនៈវិស័យរយៈពេលវែង សំរាប់កសិកម្ម និងធនធានទឹកដូចខាងក្រោម :

***ធានាបាននូវស្បៀង និង ទឹកគ្រប់គ្រាន់ មានសុវត្ថិភាព និងអាចទទួលបាន សំរាប់ប្រជាជនទាំងអស់ កាត់បន្ថយភាពក្រីក្រ និង បង្កើនផលិតផលក្នុងស្រុកសរុប ដែលទន្ទឹមនឹងនោះ ធានាបាននូវនិរន្តរភាពធនធានធម្មជាតិ ។***

គោលដៅចំបង សំរាប់ការគ្រប់គ្រងកសិកម្ម និងធនធានទឹក ក្នុងកំលុងឆ្នាំ ២០០៦-២០១០ គឺ :

***រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និង កំណើនសេដ្ឋកិច្ច តាមរយៈ(១) ការពង្រីកផលិតភាពកសិកម្ម និង ពិពិធកម្ម និង (២) កែលំអការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក ។***

គោលដៅចំបងនេះ នឹងត្រូវសំរេចបាន ដោយ (១) ការប្រើប្រាស់ និង ការ គ្រប់គ្រងដី និង ទឹក ប្រកបដោយប្រសិទ្ធភាពថែមទៀត (២) ផលិតភាពកសិកម្មមានការកើនឡើង (៣) ការពង្រីកនូវដំណើរការ កសិ-ធុរកិច្ច ហើយក៏ចាំបាច់ត្រូវ (៤) ការកសាងសមត្ថភាពស្ថាប័ន (៥) បង្កើនចំណេះដឹង និងបច្ចេកវិទ្យា ។ ការងារក្នុងផ្នែកទាំងប្រាំនេះត្រូវបានកំណត់ជាកម្មវិធី (ក្នុងចំណុ៦) ។

## ៥. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ មានផ្នែកសំខាន់ៗចំនួន ៨:

***១- ធានាថា ឱ្យមានលក្ខខ័ណ្ឌដំបូងល្អ និងផ្អែកលើភាពខ្លាំង ឬ កាលានុវត្តភាព***

ប្រការនេះ ត្រូវការជាចាំបាច់ ជាពិសេស នូវការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លា ពីសំណាក់ថ្នាក់ដឹកនាំជាតិ និងមន្ត្រីជាន់ខ្ពស់ ក៏ដូចជា ដោយអ្នកផ្តល់ជំនួយខាងក្រៅ ឬអ្នកផ្តល់ជំនួយ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹក ។ ទិដ្ឋភាពផ្សេងទៀតនៃបរិយាកាសជាតិ ឧទាហរណ៍ដូចជា ផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការ

កែលំអនូវអភិបាលកិច្ច ពង្រឹងច្បាប់និងបទបញ្ញត្ត ការដាក់បញ្ចូលប្រទេសកម្ពុជា ក្នុងពាណិជ្ជកម្មអន្តរជាតិ បង្កើន ការវិនិយោគពីផ្នែកឯកជន គឺជាករណីចាំបាច់ ដើម្បីសំរេចបានជោគជ័យចំពោះយុទ្ធសាស្ត្រកសិកម្ម និងទឹក ។

## ២- ការពង្រឹងបរិយាកាសល្អ

បរិយកាសល្អ សំរាប់វិស័យកសិកម្ម និងទឹក រួមមាន ជាពិសេស គោលនយោបាយ ច្បាប់-បទបញ្ញត្តិ ការរៀបចំស្ថាប័ន ។ល។ មានការអភិវឌ្ឍន៍ល្អ ក្នុងផ្នែកនេះ ដូចជាមាន គោលនយោបាយធនធានទឹកជាតិ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ការបង្កើនសមត្ថភាពក្នុងក្រសួងធនធានទឹក និងឧតុនិយម ។ ទោះជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវមានការពង្រឹងជាប្រចាំ ដូចជា បង្កើតនូវយន្តការ ដើម្បីអនុវត្តន៍នូវ គោលនយោបាយធនធានទឹកជាតិ អនុម័តលើពង្រាងច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក និងចេញនូវអនុក្រឹត្រនានា ដែលចាំបាច់ និងបង្កើតនូវសមត្ថភាពរបស់ ក្រសួងធនធានទឹក និងឧតុនិយម ដើម្បីអនុវត្តន៍ច្បាប់ និងអនុក្រឹត្រ ដែលទាក់ទងនឹងការប្រើប្រាស់ទឹក ការគ្រប់គ្រងទីជំរាល ដីធ្លី និង ធនធានធម្មជាតិដ៏ទៃទៀត ។

## ៣- ការប្រមែប្រមូលនូវប្រភពធនធានធម្មជាតិៈ ទឹក ដីធ្លី និង ដី

ភាពខ្លាំងសំខាន់មួយរបស់ប្រទេសកម្ពុជា គឺមានដីធ្លី ដី និងទឹក ដែលបច្ចុប្បន្ន មិនទាន់បានប្រើប្រាស់ ប្រកបដោយប្រសិទ្ធិភាពនៅឡើយ ។ យុទ្ធសាស្ត្រនេះ នឹងរួមមាន ដូចជា បង្កើនការគ្រប់គ្រងទឹក សំរាប់ដំណាំ ឱ្យបានល្អ តាមរយៈការប្រមូល ឬ រក្សាទឹកទុក ប្រព័ន្ធស្រោចស្រពដោយបង្ហូរ និងបច្ចេកទេសដូចជា ការ ស្រោចស្រពបន្ថែ បង្កើនការគ្រប់គ្រងជីជាតិដី ការពារធនធានទឹកពីភាពក្រខ្វក់ និងការខូចខាត ដើម្បីឱ្យវា នៅតែអាចប្រើប្រាស់បានសំរាប់ផ្នែកជលផល ការថៃរក្សាប្រព័ន្ធអេកូឡូស៊ី ។ល។ បង្កើនការចិញ្ចឹមត្រីក្នុង វាលស្រែ និងវារីវប្បកម្ម បង្កើនជីជាំដុះ និងធានានូវកម្មសិទ្ធិដីធ្លីប្រឆាំងនឹងការលួចដី ។

## ៤- ការគៀងគរធនធានមនុស្ស និងហិរញ្ញវត្ថុ

ធនធានមនុស្ស គឺរួមទាំងមន្ត្រីរាជការ (នៅគ្រប់កំរិត) ក៏ដូចជាកសិករ និងសមាជិកផ្សេងទៀត នៃ គ្រួសារនៅទីជនបទ ។ ប្រទេសកម្ពុជា មានកំលាំងពលកម្មដ៏ច្រើន ដែលកំពុងមានការកើនឡើងយ៉ាងលឿន ប៉ុន្តែ ប្រជាជនជាច្រើន ដែលមិនបានធ្វើការងារពេញលេញ ហើយការសិក្សា ឬការបណ្តុះបណ្តាលរបស់គេ លើជំនាញ ដែលត្រូវប្រើប្រាស់ នៅមានកំរិតនៅឡើយ ។ ជាងនេះទៅទៀត លទ្ធភាពក្នុងការទទួលបាននូវថវិការ សំរាប់ទិញ នូវធនធាន របស់ប្រជាជនជាច្រើន (ដូចជា ដី ឬ គ្រឿងចក្រកសិកម្ម) ការថែរក្សា ចំពោះឧបករណ៍នានា (ដូចជា ម៉ាស៊ីនបូមទឹក) ឬ ការបណ្តាក់ទុនក្នុងអាជីវកម្មនានា (ដូចជា ម៉ាស៊ីនកិនស្រូវ) នៅមានកំរិត ។ ដូចនេះ យុទ្ធសាស្ត្រនេះ ត្រូវតែរៀបចំ ដើម្បីគៀងគរ និងប្រើប្រាស់ឱ្យបានល្អ នូវមនុស្ស និងថវិការនោះ រួមទាំង

ការបង្កើននូវការសិក្សា បណ្តុះបណ្តាល និងការផ្សព្វផ្សាយ ក្នុងវិស័យកសិកម្ម និងទឹក ការបង្កើននូវបច្ចេកវិជ្ជាសមស្រប ការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពថែមទៀត នូវអ្នកដែលមានជំនាញ ដូចជា បុគ្គលិកផ្សព្វផ្សាយ និងវិស្វករ ការទទួលបាននូវថវិកាដែលចាំបាច់សំរាប់វិនិយោគ និង កិច្ចដំណើរការ និងការថែទាំ ការចូលរួមដ៏ធំធេងពីផ្នែកឯកជន ក្នុងវិស័យកសិកម្ម ការគ្រប់គ្រងទឹក និងកសិ-ធុរកិច្ច ។

### ៥- ការផ្ទេរអំណាចដល់ប្រជាជន និងសហគមន៍

បន្ថែមពីលើការគៀងគរនូវកំលាំងពលកម្ម (ក្នុងចំណុច៤ ខាងលើ) យុទ្ធសាស្ត្រនេះ មានបំណងក្នុងការផ្ទេរនូវសិទ្ធអំណាច ដល់សហគមន៍ ដើម្បីធ្វើការរួមគ្នា និងមានលក្ខណជឿជាក់លើខ្លួនឯងកាន់តែខ្លាំងឡើង ។ ករណីនេះ រួមមានទាំង ការបង្កើត និងជួយគាំទ្រដល់ សហគមន៍កសិករប្រើប្រាស់ទឹក ជួយកសិករក្នុងការបង្កើតនូវសហករណ៍ និងអង្គការផ្សេងៗទៀត ក្នុងការរកទីផ្សារលក់ផលិតផលដំណាំ និងទិញធនធានផ្សេងមកប្រើប្រាស់ រួមទាំងការរៀបចំ អង្គការនានា ក្នុងសហគមន៍ (ក្រុមប្រឹក្សា ឃុំ-សង្កាត់ គណៈកម្មការអភិវឌ្ឍន៍ភូមិ ។ល។) ក្នុងការចូលរួម ក្នុងការធ្វើផែនការ និងអនុវត្តន៍នូវគំរោងនានា ក្នុងសហគមន៍ សំរាប់ការផ្គត់ផ្គង់ទឹក ។ល។

### ៦- ការអនុវត្តន៍នូវវិធីសាស្ត្រអាងទន្លេចំពោះទឹក និងដីធ្លី

ផ្នែកក្នុងចំណុច ៣ ៤ និង ៥ ត្រូវតែអនុវត្តន៍ក្នុងរបៀបមួយចំរុះ ដើម្បីទទួលបាននូវតំលៃពេញលេញ ។ ការគ្រប់គ្រងទឹក ក្នុងបណ្តាប្រទេសជាច្រើន ត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌអាងទន្លេ ហើយអាងទន្លេ ផ្តល់នូវមូលដ្ឋានដ៏ល្អមួយ ក្នុងការគ្រប់គ្រងធនធានទឹក ជាជាងគ្រប់គ្រងតាមព្រំដែនរដ្ឋបាល ។ ដូចនេះ យុទ្ធសាស្ត្រនេះ តាមការដែលអាចធ្វើទៅបាន នឹងជំរុញដល់ការអនុវត្តន៍ នូវវិធីសាស្ត្រអាងទន្លេ ដើម្បីធ្វើការរៀបចំចំរុះ ផ្អែកតាមស្ថានភាពខេត្ត ស្រុក ។ល។

### ៧- ការបង្កើនផលិតភាពកសិកម្ម

យុទ្ធសាស្ត្រក្នុងផ្នែកនេះ មានគោលបំណងក្នុងការបង្កើននូវផលិតផល កាត់បន្ថយការចំណាយ ក្នុងមួយឯកតា នៃផលិតផល និងជួយក្នុងការធានាដល់គុណភាពផលិលផល ។ វានឹងជួយដល់ការបង្កើននូវផលិតផលដែលមានគុណភាពខ្ពស់ ដែលអាចសំរេចបានទាំងគោលដៅសន្តិសុខស្បៀង និងពាណិជ្ជកម្ម ។ បន្ថែមពីលើសកម្មភាពដែលបានលើកឡើងខាងលើ ក្នុងចំណុច ៤ និង ៥ ផ្នែកនៃយុទ្ធសាស្ត្រ នឹងរួមមាន ការបង្កើនគុណភាពធនធាន ដូចជាគ្រាប់ពូជ និងជី កាត់បន្ថយការបាត់បង់ នៅពេល និងក្រោយពេលប្រមូលផល បង្ហាញនូវរបៀបគ្រប់គ្រងកសិកម្ម និងទឹក ។

### *៨- ការពង្រីកកសិ-ពាណិជ្ជកម្ម*

ការធ្វើពាណិជ្ជកម្ម ក្នុងវិស័យកសិកម្ម ផ្តល់នូវមធ្យោបាយសំរាប់គ្រួសារ នៅជនបទ និងសហគមន៍ ក្នុងការរកចំណូលជាសាច់ប្រាក់ ក៏ដូចជាផ្តល់នូវមូលដ្ឋានមួយ សំរាប់ធ្វើកសិ-ធុរកិច្ច ។ យុទ្ធសាស្ត្រនេះ នឹងជួយដល់កសិករ ក្នុងការផលិតនូវផលិតផល ដែលអាចធ្វើពាណិជ្ជកម្មបាន ដោយផ្តល់នូវពត៌មាន និងការព្យាករណ៍ ទាក់ទងនឹងតំរូវការនៅទីផ្សារ ជំរុញដល់ការផលិត នូវផលិតផលថ្មីៗ បង្កើឱ្យមានមធ្យោបាយក្នុងការកែច្នៃផលិតផល ដើម្បីបង្កើនតំលៃ រៀបចំឱ្យមានការធានានូវគុណភាពផលិតផល និងសុវត្ថិភាពស្បៀង ជួយសំរួលដល់ច្រកចូលទៅកាន់ទីផ្សារ ជាពិសេស តាមរយៈមធ្យោបាយដឹកជញ្ជូន និងរក្សាទុកបានល្អ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ការរៀបចំវេចខ្ចប់ និង លក់ដុំ ។ល។

ផ្នែកទាំង៨នេះ អាចត្រូវបានរៀបជាលំដាប់មួយ ក្នុងបួនដំណាក់កាល ដែលឆ្លុះបញ្ចាំងតាមលំដាប់ពេលវេលា និងភាពទំនាក់ទំនងរវាងផ្នែកទាំងនោះ (រូបភាព ១.១/៥.១) ។ ដ្យាកាមនេះ អាចបង្ហាញក្នុងលក្ខណដូចជា ផ្ទះមួយ : ដំណាក់កាលទី ១ គឺ ដូចជាគ្រឹះ ដំណាក់កាលទី២ ដូចជាសរសរ និង កំរាល ដំណាក់កាលទី ៣ ដូចជាជញ្ជាំង និង ដំណាក់កាលទី ៤ ដូចជាដំបូល ដែលទាំងអស់នេះ នឹងនាំឈានទៅរកការសំរេចបាន នូវគោលដៅ (ចំពោះផ្ទះ) គឺ មានជំរកល្អ និងមានសុខភាពល្អ សំរាប់គ្រួសារ និង (ចំពោះវិស័យកសិកម្ម និងទឹក) គឺការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច សំរាប់ប្រទេសកម្ពុជា ។

ផ្នែកនានានៃយុទ្ធសាស្ត្រនេះ ត្រូវបានកំពុងអនុវត្តន៏រួចមកហើយ ក្នុងកំរិតផ្សេងៗគ្នា ។ ដូចនេះ ដំណាក់កាលនៃផ្នែកផ្សេងៗទាំងនេះ វាបង្ហាញនូវការផ្លាស់ប្តូរ ក្នុងកំរិតនៃកិច្ចខិតខំប្រឹងប្រែង ដែលត្រូវផ្តោតការ យកចិត្តទុកដាក់លើផ្នែកនិមួយៗនោះ ។ ប្រការនេះ វានឹងធានាដល់ការអនុវត្តន៏ដោយជោគជ័យ នៃផ្នែក ផ្សេងៗទៀត ដែលឋិតក្នុងលំដាប់ក្រោយៗ ។ ហើយបន្ទាប់មក ធនធានទាំងនេះ គួរតែត្រូវបែងចែកឡើងវិញ ទៅលើផ្នែកក្រោយៗទៀត ។

## ៦‿ ផ្នែកកម្មវិធី

យុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តន៏នៅក្នុងកម្មវិធីចំនួនប្រាំ ស្របតាមគោលដៅអភិវឌ្ឍន៏ទាំងប្រាំ ។ ដែលកម្មវិធីនិមួយៗ មានគោលដៅរបស់វា និងគោលបំណងមួយចំនួន (រូបភាព ១.១/៥.២) កម្មវិធីមួយទាក់ទងនឹងការបង្កើតឱ្យមានបរិយាកាសល្អ កម្មវិធីពីរទៀត ទាក់ទងនឹងផ្នែកគៀងគរធនធាន និងការផ្តល់សិទ្ធិរបស់យុទ្ធសាស្ត្រនេះ ហើយកម្មវិធីពីរផ្សេងទៀត ទាក់ទងនឹងផលិតភាព និងការធ្វើពាណិជ្ជកម្ម ក្នុងវិស័យកសិកម្ម ។ កម្មវិធីទាំងនោះ គឺ:

១- កម្មវិធី គាំទ្រដល់ការពង្រឹងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រង សំរាប់វិស័យកសិកម្ម និងទឹក

២- កម្មវិធី គាំទ្រដល់ផ្នែកកសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតម្លៃ)

៣- កម្មវិធី គាំទ្រដល់ផ្នែកសន្តិសុខស្បៀង

៤- កម្មវិធីគ្រប់គ្រងធនធានទឹក ប្រព័ន្ធធារាសាស្ត្រ និង ដីធ្លី

៥- កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយកសិកម្ម និងធនធានទឹក ។

កម្មវិធីទាំង ៥ នេះ នឹងរួមមាននូវបណ្តុំសកម្មភាព ដែលរៀបចំឡើង ដើម្បីសំរេចបាន នូវគោលដៅអភិវឌ្ឍន៍ និងគោលបំណងនានា ។ ជាចំណុចចាប់ផ្តើម កម្មវិធីទាំងនោះ ត្រូវបានហៅថា លក្ខខ័ណ្ឌការងារដំបូងសំរាប់ក្រុមរៀបចំកម្មវិធី ដែលត្រូវរៀបចំសកម្មភាព ក្នុងកំលុងពេលចុងឆ្នាំ ២០០៦ ។ ភ្នាក់ងារផ្តល់ជំនួយខាងក្រៅជាច្រើន បានបង្ហាញនូវឆន្ទះរបស់ខ្លួន ក្នុងការផ្តល់នូវធនធាន សំរាប់ក្រុមរៀបចំកម្មវិធីនេះ ។

## ៧. តំរូវការធនធាន

ចំនួនថវិកា ដែលនឹងត្រូវការ ត្រូវបានប៉ាន់ស្មានថា ប្រមាណប្រហែល ៣៥០ លាន ដុល្លាអាមេរិក សំរាប់រយៈពេល ៥ឆ្នាំ ។ ភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ក៏មានការពាក់ព័ន្ធ ក្នុងសកម្មដែលទាក់ទងនឹងវិស័យកសិកម្ម និងទឹកដែរ ជាពិសេស ផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ។ល។) និងការគ្រប់គ្រងដីធ្លី ។ ថវិការបស់គេ សំរាប់សកម្មភាពនេះ នឹងជួយក្នុងការអនុវត្តន៏យុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹក ផងដែរ ប៉ុន្តែនៅក្នុងដំណាក់កាលនេះ ថវិកាទាំងនេះ មិនគួររាប់បញ្ចូលជាផ្លូវការ ទៅក្នុងថវិការបស់យុទ្ធសាស្ត្រនេះទេ ។ ករណីនេះ វានឹងឃើញជាក់ស្តែងជាងនេះ នៅពេលដែលយុទ្ធសាស្ត្រ ត្រូវបានអនុវត្តន៏ជាបណ្តើរៗ ជាពិសេស នៅដំណាក់កាលនៃការធ្វើផែនការវិនិយោគ ក្នុងកំឡុងពេលក្រោយឆ្នាំ ២០១០ ។

## ៨. ការត្រួតពិនិត្យតាមដាន និង វាយតំលៃ

ផ្នែកសំខាន់នៃយុទ្ធសាស្ត្រ និងការអនុវត្តន៏កម្មវិធី គឺត្រួតពិនិត្យតាមដាននូវលទ្ធផល ចំពោះគោលដៅ ឬសូចនាករនានា ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធាន ទឹក និងឧតុនិយម ដែលជាស្ថាប័នដឹកនាំ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការត្រួតពិនិត្យតាមដាន លើការអនុវត្តន៏ យុទ្ធសាស្ត្រ សំរាប់រាជរដ្ឋាភិបាលកម្ពុជា ។ បទពិសោធន៏ ដែលទទួលបាន នឹងជួយឱ្យយើងពិនិត្យឡើងវិញ នូវយុទ្ធសាស្ត្រសំរាប់ រយៈពេល ២០១១-២០១៥ និង ដើម្បីប្រើប្រាស់ធនធានសំរាប់វិស័យដែលមានអាទិភាព ។




រូបភាព៥.១-យុទ្ធសាស្ត្រ: ដំណាក់កាលបួន ចេញពីលក្ខខ័ណ្ឌដើម ឆ្ពោះទៅគោលដៅ




រូបភាព ៥.២-រចនាសម្ព័ន្ធកម្មវិធីរបស់យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក

# មាតិការ

~~~~

**អារម្ភកថា**........................................................................................................

**<u>អត្ថបទសង្ខេប</u>: យុទ្ធសាស្រ្តសំរាប់វិស័យកសិកម្ម និងទឹក** ....................................

**១_សេចក្តីផ្តើម**..................................................................................................

**២_ការវិភាគលើស្ថានភាព**.........................................................................

២.១-បរិយាកាសគោលនយោបាយជាតិ និងក្របខ័ណ្ឌស្ថាប័ន........................................

២.២-ភាពខ្លាំង ភាពខ្សោយ ឱកាស និង ការគំរាមកំហែង.......................................

២.៣-បញ្ហាតាមវិស័យ..........................................................................................

**៣_ដំណើរការទូទៅរបស់យុទ្ធសាស្រ្ត**.........................................................................

**៤_ទស្សនៈវិស័យ និង គោលដៅសំរាប់វិស័យកសិកម្ម និងទឹក**........................

៤.១-ទស្សនៈវិស័យសំរាប់វិស័យកសិកម្ម និងទឹក...................................................

៤.២-គោលដៅចំបងសំរាប់ឆ្នាំ ២០០៦-២០១០....................................................

**៥_ការបង្កើតយុទ្ធសាស្រ្ត**...................................................................................

៥.១-ផ្នែកសំខាន់ៗ ............................................................................................

៥.២-ដំណាក់កាលនៃការអនុវត្តន៏........................................................................

៥.៣-ការអនុវត្តន៏តាមកម្មវិធីនានា.....................................................................

**៦_ផ្នែកកម្មវិធី**....................................................................................................

៦.១-កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងសំរាប់

វិស័យកសិម្ម និងធនធានទឹក...............................................................................

៦.២-កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង.................................................................
~~~~

៦.៣-កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច ( ប្រព័ន្ធតំលៃ) ................................
៦.៤- កម្មវិធីធនធានទឹក ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងដី.................................
៦.៥-កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយកសិកម្ម និងធនធានទឹក..................

**៧-តំរូវការធនធាន**...........................................................................................

**៨-ការត្រួតពិនិត្យ និង វាយតំលៃ**.........................................................................

**ឧបសម្ព័ន្ធ ១** :ឯកសារយោង.....................................................................................

**ឧបសម្ព័ន ២**: គោលដៅរបស់ក្រសួងកសិកម្ម រុកប្រមាញ់ និងនេសាទ និង
ក្រសួងធនធានទឹក និងឧតុនិយម..........................................................
**ឧបសម្ព័ន ៣**: លក្ខខ័ណ្ឌការងារសំរាប់ការបង្កើតកម្មវិធី.................................................
កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងសំរាប់
វិស័យកសិម្ម និងធនធានទឹក.........................................................................
កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង.......................................................................
កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច ( ប្រព័ន្ធតំលៃ) ..............................................
កម្មវិធីធនធានទឹក ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងដី.............................................
កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយកសិកម្ម និងធនធានទឹក..............................

**ឧបសម្ព័ន ៤** :ឯកសារគោលគំនិតសំរាប់បង្កើតយុទ្ធសាស្រ្តសំរាប់វិស័យកសិកម្មនិងទឹក........

**ឧបសម្ព័ន ៥**: លក្ខខ័ណ្ឌការងារ សំរាប់ការបង្កើតយុទ្ធសាស្រ្ត...........................................

## ១.សេចក្តីផ្តើម

### ១.១. សាវតា និង គោលបំណង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅថ្ងៃទី ២៧ មករា ឆ្នាំ ២០០៦ និងប្រកាសជាផ្លូវការដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៦ ។ ផែនការនេះបានរៀបរាប់នូវយុទ្ធសាស្ត្រចតុកោណសំរាប់ ការរីកចំរើន ការងារ សមភាព និង ប្រសិទ្ធិភាព ដែលផ្តល់នូវក្របខ័ណ្ឌមួយ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា ។ ដោយមានអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងពង្រីកដល់ការលូតលាស់សេដ្ឋកិច្ចនោះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានយកចិត្តទុកដាក់ជាពិសេសដល់ការបង្កើននូវវិស័យកសិកម្ម ដែលជាវិស័យមួយ ក្នុងផ្នែកទាំងបួននៃយុទ្ធសាស្ត្រចតុកោណ ។ យុទ្ធសាស្ត្រនេះ បានលើកឡើងថា គោលដៅជាអាទិភាពក្នុងវិស័យនេះ គឺការបង្កើននូវសន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម និងទីផ្សារសំរាប់ផលិតផលកសិកម្ម ។ យុទ្ធសាស្ត្រនេះ បានបញ្ជាក់ (ក្នុងចំណុច ៤.៤៣) នូវយុទ្ធសាស្ត្រជាអាទិភាពសំរាប់ឆ្នាំ ២០០៦-២០១០ ដែលទីមួយ គឺបង្កើនល្បឿននៃការបង្កើត និងអនុវត្តន៍នូវយុទ្ធសាស្ត្រកសិកម្ម និងធនធានទឹកដីទូលំទូលាយមួយ ។

ផ្នែកទីពីរនៃយុទសាស្ត្រចតុកោណ គឺការស្តារ និងកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលរួមមាន ទាំងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ដែលជាផ្នែកមួយក្នុងបណ្តាផ្នែកទាំងបួននៃយុទ្ធសាស្ត្រនោះ (ចំណុច ៤.៦៤) ។ អាទិភាពក្នុងផ្នែកនេះ គឺទាក់ទងយ៉ាងជិតស្និទជាមួយនឹងការប្រើប្រាស់ទឹកក្នុងវិស័យកសិកម្ម ដែលជាគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំរាប់វិស័យកសិកម្ម ។

ទាំងកសិកម្ម និងការគ្រប់គ្រងធនធានទឹក គឺជាសកម្មភាពដែលពាក់ព័ន្ធនឹងវិស័យជាច្រើនទៀត ដែលមានការទាក់ទងជាមួយ ភ្នាក់ងាររដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ខាងក្រៅ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសសហគមន៍ជនបទ ដែលមានប្រជាជនប្រមាណ ៨៥ ភាគរយ មានការពាក់ព័ន្ធនិងវិស័យនេះ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តោតការយកចិត្តទុកដាក់ពិសេស (ចំណុច ៤.៤០) លើតំរូវការឱ្យមានវិធីសាស្ត្រមួយ ដែលមានលក្ខណទូលំទូលាយ និងប្រកបដោយកិច្ចសហប្រតិបត្តិការ ចំពោះវិស័យកសិកម្ម និងធនធានទឹក ហើយការរៀបចំនូវយុទ្ធសាស្ត្រនេះ នឹងរួមចំណែកក្នុងការសំរេចបាននូវវិធីសាស្ត្រនេះ ។

គោលបំណងនៃឯកសារនេះ គឺដើម្បីរៀបចំបង្កើតនូវយុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹក ដៃឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ជំហានបន្ទាប់ ក្នុងដំណើរការរៀបចំបង្កើតយុទ្ធសាស្ត្រនេះ គឺត្រូវបង្កើតនូវក្របខ័ណ្ឌសំរាប់អនុវត្តន៍មួយ ហើយដែលឯកសារនេះ នឹងផ្តល់នូវចំណុចចាប់ផ្តើមមួយ ។ ក្នុងពេលរៀបចំបង្កើតក្របខ័ណ្ឌនេះ ឯកសារពង្រាងយុទ្ធសាស្ត្រនេះ នឹងត្រូវបានកែសំរួល ។ ជាងនេះទៅទៀតនោះ គឺថា រាល់យុទ្ធសាស្ត្រទាំងអស់ ទាមទារឱ្យមានការត្រួតពិនិត្យ និងតាមដាន ហើយយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹកនេះក៏ដូចគ្នាផងដែរ ។ ក្នុងឆ្នាំ ២០០៩ ឬ ២០១០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០១១-២០១៥

គឺរំពឹងថា នឹងត្រូវបានចាប់ផ្តើមរៀបចំធ្វើ ។ យុទ្ធសាស្ត្រនេះផ្តល់នូវ ចំណុចចាប់ផ្តើមដែលចាំបាច់ ក្នុងការកែតំរូវនូវយុទ្ធសាស្ត្រសំរាប់កសិកម្ម និងទឹក ក្នុងរយៈពេលនៃការធ្វើផែនការលើកក្រោយទៀត ។

### ១.២. សូចនាករនៃជោគជ័យ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបញ្ជាក់ពីការចូលរួមដ៏សំខាន់ដែលកសិកម្ម និងទឹក មានតួនាទីក្នុងការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការរីកចំរើនសេដ្ឋកិច្ច ហើយវាបានរួមបញ្ចូលនូវគោលដៅជាច្រើនដែលទាក់ទងនឹងផ្នែកទាំងនេះ ។ ទោះជាយ៉ាងនេះក៏ដោយ វាមានកត្តាផ្សេងៗទៀត ដែលមានឥទ្ធិពលលើជោគជ័យក្នុងផ្នែកទាំងនេះ ហើយដែលគោលដៅទាំងអស់នោះ មិនអាចយកមកប្រើប្រាស់បាន ក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្តន៍ក្នុងការគ្រប់គ្រងកសិកម្ម និងទឹកទេ ។ វាចាំបាច់ត្រូវបង្កើតនូវសូចនាករបន្ថែមទៀត សំរាប់ប្រើក្នុងរយៈពេលនៃការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិលើកក្រោយទៀត ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (តារាង៤.២) បានកំណត់នូវគោលដៅជាក់លាក់សំរាប់ឆ្នាំ ២០១០ចំពោះវិស័យកសិកម្ម ដែលគោលដៅមួយចំនួនធំនោះទាក់ទងនឹងកសិកម្ម និតីករូបគ្នា (តារាង១.១) ។ ប្រការនេះវាផ្តល់នូវមូលដ្ឋានមួយ ដើម្បីត្រួតពិនិត្យតាមដានលើការអនុវត្តន៍នៃការគ្រប់គ្រងកសិកម្ម និងទឹក បើទោះបីជាកត្តាបីដំបូង វាផ្អែកខ្លាំងទៅលើអាកាសធាតុក៏ដោយ ។

គោលដៅអភិវឌ្ឍន៍សហសវត្សរបស់ប្រទេសកម្ពុជា ក្នុងឯកសារបន្ថែម ១.១ នៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្តល់នូវក្របខ័ណ្ឌមួយទៀត សំរាប់ត្រួតពិនិត្យតាមដាន លើការវិវត្តន៍ក្នុងកិច្ចអភិវឌ្ឍន៍របស់ជាតិ ប៉ុន្តែពុំមានចំណុចណាមួយទាក់ទងផ្ទាល់ទៅនឹងវិស័យកសិកម្ម និងទឹកទេ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ លើកឡើងតែយុទ្ធសាស្ត្រជាអាទិភាព ដែលផ្តល់នូវមូលដ្ឋានសំរាប់ការត្រួតពិនិត្យតាមដាន លើការអនុវត្តន៍ ក្នុងផ្នែកកសិកម្ម (ចំណុច ៤.៤២ ដល់ ៤.៥៤) និងធនធានទឹក និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (ចំណុច៤.៦៤) ។ ក្រសួងផែនការ បានបង្កើតនូវក្របខ័ណ្ឌមួយ សំរាប់ត្រួតពិនិត្យតាមដាន លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយផ្តោតលើសូចនាករ "ថ្នាក់ខ្ពស់" ដែលបានលើកឡើងខាងលើ (សូមមើលផ្នែកទី ៨) ។

**តារាង១.១**-សូចនាករ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលទាក់ទងនឹងវិស័យកសិកម្ម និងធនធានទឹក (ដកស្រង់ពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តារាង ៤.២)

| សូចនាករ | ២០០៥ ប៉ាន់ស្មាន | ២០១០ គោលដៅ |
|---|---|---|
| ផលិតផលស្រូវ (លានតោន) | ៤.១៧ | ៥.៥ |
| ទិណ្នផលស្រូវ (តោន/ហត) | ១.៩៧ | ២.៤ |
| ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពបន្ថែម) (ភាគរយនៃផ្ទៃដីដាំស្រូវ) | ២០ | ២៥ |
| ចំនួនកម្មសិទ្ធដីដែលបានចេញជូនកសិករ (ភាគរយនៃផ្ទៃដីសរុប) | ១២ | ២៤ |

ដោយអនុវត្តន៍តាមការណែនាំរបស់ក្រសួងផែនការ សំរាប់ការរៀបចំដាក់បញ្ចូលក្នុង ផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍ជាតិនោះ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានលើកឡើងនូវគោលបំណង និងសកម្មភាពជាក់លាក់ ដែលរួមមានទាំង គោលដៅរយៈពេលពាក់កណ្តាលការអនុវត្តន៍ (លទ្ធផល ឆ្នាំ ២០០៨) និងគោលដៅចុងក្រោយ (លទ្ធផលឆ្នាំ ២០១០)[១] ផង ។ ប្រការនេះ វាផ្តល់នូវមូលដ្ឋានលំអិតថែមទៀត សំរាប់ត្រួតពិនិត្យតាមដាន លើសមិទ្ធិផល ដែលជាតំលៃសំរាប់អ្នកដែលពាក់ព័ន្ធផ្ទាល់ ក្នុងការធ្វើផែនការ និងត្រួតពិនិត្យ ក្នុងវិស័យកសិកម្ម និងទឹក ។

## ១.៣_ដំណើរការរៀបចំបង្កើតយុទ្ធសាស្រ្ត

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បានតំរូវឱ្យមានការរៀបចំនូវយុទ្ធសាស្រ្ត សំរាប់វិស័យកសិកម្ម និងទឹក ក្នុងកំលុងឆ្នាំ ២០០៦ ។ ដើម្បីឆ្លើយតបនឹងករណីនេះ ក្រុមការងារយុទ្ធសាស្រ្ត B1 នៃក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក បានបង្កើតនូវលក្ខខ័ណ្ឌការងារសំរាប់អនុវត្តន៍ ដែលត្រូវធ្វើដោយ "ក្រុមការងារយុទ្ធសាស្រ្ត" រួមរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ។ ក្រុមនេះ បានប្រមូលផ្តុំគ្នាជាបន្ទាន់ ដើម្បីរៀបចំនូវរបាយការណ៍ដំបូង (Inception Note) ក្នុងខែមករា ឆ្នាំ ២០០៦ ។ ចាប់តាំពីពេលនោះមក កិច្ចដំណើរការ បានប្រព្រឹត្តទៅលើការងារដូចខាងក្រោម (រូបភាព ១.១ នៅទំព័របន្ទាប់) :

១- វិភាគលើ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព ភាពគំរាមកំហែង អ្នកពាក់ព័ន្ធ និងបរិយាកាស នយោបាយ ដែលបានរៀបរាប់ក្នុងរបាយការណ៍ឯកសារយុទ្ធសាស្រ្ត (Strategic Profile) ខែ មេសា ឆ្នាំ ២០០៦ ។

២- បង្កើតនូវជំរើសយុទ្ធសាស្រ្ត (Strategy Options) ចំនួនបួន ដែលមានរៀបរាប់ក្នុងឯកសារ ការបង្កើត យុទ្ធសាស្រ្ត ១ (Strategy Formulation I) នៅខែ ឧសភា ឆ្នាំ ២០០៦ ដែលផ្អែកលើការវិភាគលើ ភាពខ្លាំង ភាពខ្សោយ ឱកាស និង ភាពគំរាមកំហែង ដើម្បីកំណត់នូវយុទ្ធសាស្រ្ត និងបង្កើតនូវវិធីសាស្រ្តជាយុទ្ធសាស្រ្ត ។

៣- ពិនិត្យឡើងវិញលើជំរើសយុទ្ធសាស្រ្ត តាមរយៈសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធ (ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៦) ។

៤- កែសំរួលបន្ថែមលើគោលគំនិតយុទ្ធសាស្រ្ត ដោយក្រុមការងារ ការបង្កើតនូវរចនាសម្ព័ន្ធគោល (Indicative Structure) (របាយការណ៍ស្តីពីគោលគំនិតនៃយុទ្ធសាស្រ្ត: Strategy conception note ដែលត្រូវ ឯកភាព ដើម្បីរៀបចំបន្តក្នុងខែ មិថុនា ឆ្នាំ ២០០៦) និងពិនិត្យឡើងវិញលើកិច្ចដំណើរការ (ផែនការនៃកិច្ច ដំណើរការ ខែ មិថុនា ឆ្នាំ ២០០៦) ។

---

1 លទ្ធផល គឺមានលក្ខណជាក់ស្តែង ជាលទ្ធផលដែលអាចវាស់វែងនូវគោលបំណងបាន ដូចជាពង្រាងអនុក្រឹត្រ ដែលបានដាក់ជូនរដ្ឋមន្រ្តីក្នុងថ្ងៃណាមួយនោះ ។ លទ្ធផលគឺ ត្រូវបានកំណត់ច្បាស់សំរាប់ឆ្នាំ ២០០៨ ដើម្បីឱ្យអាចវាយតំលៃលើកិច្ចដំណើរការចំពោះលទ្ធផលដែលកំណត់សំរាប់ឆ្នាំ ២០១០ ។ លទ្ធផល គឺពិបាកវាស់វែងជាង ក្នុងលក្ខណជាគោលបំណង ។ វារៀបរាប់នូវការផ្លាស់ប្តូរផ្នែកបរិស្ថាន និងសង្គមដែលសកម្មភាពបានគ្រោងនឹងសំរេចនោះ ដូចជាការបង្កើននូវសមត្ថភាពក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធដោយប្រើពត៌មានស្តីពីរំហូរទឹក ។

៥- នាពេលបច្ចុប្បន្ននេះ "ក្នុងដំណាក់កាលពាក់កណ្តាល" នៃដំណើរការនេះ យើងមានពង្រាងរបាយការណ៍យុទ្ធសាស្ត្រកសិកម្ម និងទឹក (Draft A&W Strategy) នេះ ។ វាផ្តល់នូវចំណុចចាប់ផ្តើម សំរាប់ដំណាក់កាលពីរបន្ទាប់ទៀត ក្នុងកិច្ចដំណើរការ :

៦- ការបង្កើតបញ្ចប់នូវលក្ខខ័ណ្ឌការងារសំរាប់កម្មវិធីអភិវឌ្ឍន៍ សំរាប់ក្រុមរៀបចំកម្មវិធី (កំពុងអនុវត្តន៍) ដែលត្រូវចុះកិច្ចសន្យាក្នុងឆ្នាំ ២០០៧ ។ ក្នុងពង្រាងលក្ខខ័ណ្ឌការងារដំបូង ដែលមានភ្ជាប់ក្នុងរបាយការណ៍នេះ (ឧបសម្ព័ន្ធ ៥) ។

៧- ការបង្កើតនូវកម្មវិធីអភិវឌ្ឍន៍ជាតិ និងក្របខ័ណ្ឌកម្មវិធីមួយ សំរាប់អនុវត្តន៍ និងដំណើរការយុទ្ធសាស្ត្រ ដែលកំណត់យ៉ាងច្បាស់នូវអាទិភាព ក្នុងការវិនិយោគ ។ ពង្រាងឯកសារគោលគំនិត (Draft Conception Note) ចំពោះកិច្ច ដំណើរការនេះ ត្រូវបានបង្ហាញ និងបានកំពុងកែសំរួលឡើងវិញ ។

**ដំណាក់កាលនៃកិច្ចដំណើរការ** **លទ្ធផល**




**រូបភាព ១.១**-ដំណើរការសំរាប់ការបង្កើតនូវយុទ្ធសាស្ត្រ និងក្របខ័ណ្ឌ សំរាប់វិស័យកសិកម្ម និងទឹក

## ២. ការវិភាគលើស្ថានភាព

### ២.១. បរិយាកាសគោលនយោបាយជាតិ និង ក្របខ័ណ្ឌស្ថាប័ន

បរិយាកាសគោលនយោបាយជារួម សំរាប់វិស័យកសិកម្ម និងទឹក ត្រូវបានកំណត់ ជាពិសេស ដោយយុទ្ធសាស្ត្រជាតិ សំរាប់កាត់បន្ថយភាពក្រីក្រ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ អាទិភាពចំបងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រ ។ ជាងនេះទៅទៀតនោះ គោលនយោបាយដែលពាក់ព័ន្ធវិស័យជាច្រើន ដូចជាគោលនយោបាយដែលទាក់ទងនឹងការកែទំរង់រដ្ឋបាល សមភាពយ៉ែនឌ័រ និងការអភិវឌ្ឍន៍នូវសហគ្រាសធុនតូច និងមធ្យម ផ្តល់នូវបរិបទមួយ សំរាប់សកម្មភាពក្នុងវិស័យនិមួយៗ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋានតាមវិស័យ មិនមែនតាមក្រសួងទេ ដែលជំរុញឱ្យក្រសួងនានា ធ្វើផែនការ តាមលក្ខណទាក់ទងតាមវិស័យ និងប្រកបដោយការប្រស្រ័យទាក់ទងគ្នា ។ ជាងនោះទៀត ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ បានតំរូវឱ្យមានការផ្ទេរនូវការទទួលខុសត្រូវ និងធនធានដល់ក្រុមប្រឹក្សា នៅថ្នាក់ខេត្ត ក្រុង ស្រុក និង ឃុំ ។ គេត្រូវបានទទួលស្គាល់ថា ការរៀបចំរបស់ប្រទេសកម្ពុជា ចំពោះរដ្ឋបាលសាធារណៈ នៅពេលបច្ចុប្បន្នមិនទាន់បានសុក្រិត្រនៅឡើយ ដោយនៅមានខ្វះចន្លោះ មានការត្រួតស៊ីគ្នា និងមិនមានការទំនាក់ទំនងល្អក្នុងមុខងារទាំងនោះ ។ ដោយសារ ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវរៀបចំ និងអនុវត្តន៍បន្តទៀតនោះ ភាពខ្សោយផ្នែកស្ថាប័ន ក្នុងវិស័យកសិកម្ម និងទឹក នឹងត្រូវកំណត់ឱ្យបានច្បាស់ជាងនេះ ហើយក្រសួងដែលដឹកនាំក្នុងវិស័យនេះ នឹងត្រូវរៀបចំរកដំណោះស្រាយនេះ ។

មូលដ្ឋានយុទ្ធសាស្ត្ររួម សំរាប់វិស័យកសិកម្ម និងទឹក នៅមានកំណត់នៅឡើយ ។ គោលនយោបាយធនធានទឹកជាតិ ត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៤ ដែលផ្តល់នូវគោលនយោបាយថ្មីៗ និងទូលំទូលាយមួយទាក់ទងទៅនឹងទិដ្ឋភាពទាំងអស់ នៃការគ្រប់គ្រងធនធានទឹក ។ ពង្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក បានកំពុងតែរង់ចាំ ការសំរេចពីសភាជាតិ ដែលនាំឱ្យមានការពិបាក ក្នុងការចាត់ចែងការប្រើប្រាស់ទឹក ។ បញ្ហាដែលទាក់ទងនឹងទឹកអន្តរជាតិនៃទន្លេមេគង្គ ត្រូវបានអនុវត្តន៍ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងទន្លេមេគង្គ ដោយមានការជួយជ្រោមជ្រែងពីគណៈកម្មការទន្លេមេគង្គ ។ កិច្ចព្រមព្រៀងនោះ ផ្តល់នូវក្របខ័ណ្ឌរួម និងសំខាន់មួយ សំរាប់ការគ្រប់គ្រងទឹកជំនន់ និងធនធានទឹក តាមទំនាបទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប ហើយដែលផ្តល់នូវបរិបទមួយសំរាប់យុទ្ធសាស្ត្រលំអិតថែមទៀត ក្នុងវិស័យកសិកម្ម និងទឹក ។

ទាក់ទងទៅនឹងធនធានដី យុទ្ធសាស្ត្របណ្តោះអាសន្នមួយ ស្តីពីក្របខ័ណ្ឌគោលនយោបាយដីធ្លី ត្រូវបានអនុម័តក្នុងឆ្នាំ ២០០២ ដែលបន្ថែមទៅលើច្បាប់ដីធ្លីនៅឆ្នាំ ២០០១ ។ ទាក់ទងទៅនឹងកសិកម្ម គឺមាន

គោលនយោបាយតាមអនុ-វិស័យ ស្តីពីការអភិវឌ្ឍន៍ និងស្រាវជ្រាវលើ ដំណាំ ការចិញ្ចឹមសត្វ និងកសិកម្ម (R&D) ។ល។ ដែលគាំទ្រដល់បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានកំណត់ក្នុងអនុក្រឹត្រលេខ ១៧ ។ ការជាប់ទាក់ទងនៃគោលនយោបាយសំខាន់ៗ សំរាប់វិស័យកសិកម្ម និងធនធានទឹក ត្រូវបានវិភាគដោយក្រុមយុទ្ធសាស្ត្រ B1 (ឯកសារការងារ វិភាគយុទ្ធសាស្ត្រ ផ្នែកទី ២) ហើយត្រូវបានសង្ខេបនៅក្នុងតារាង ២.១ នេះ ។

តារាង ២.១- គោលនយោបាយ និងយុទ្ធសាស្ត្រដែលអាចមានឥទ្ធិពលលើកសិកម្ម និងការគ្រប់គ្រងធនធានទឹក (ដកស្រង់ចេញពីឯកសារការងារវិភាគយុទ្ធសាស្ត្រ - Strategy Profile)

| ផ្នែកនៃគោលនយោបាយ និងយុទ្ធសាស្ត្រ | កំរិតនៃការប៉ះពាល់ | ទិសដៅនៃការប៉ះពាល់ |
|---|---|---|
| ការពាក់ព័ន្ធកំរិតជាតិ | ខ្ពស់ | មានការគាំទ្រខ្លាំង |
| ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ | ខ្ពស់ | មានការគាំទ្រ |
| វិមជ្ឈការ និងវិសហមជ្ឈការ | ខ្ពស់ | មានការគាំទ្រ |
| ការកែទំរង់តុលាការ | ខ្ពស់ | មានការគាំទ្រ |
| ការកែទំរង់រដ្ឋបាល | ខ្ពស់ | មានការគាំទ្រ |
| គោលនយោបាយវិនិយោគផ្នែកឯកជន | ខ្ពស់ | មានការគាំទ្រ ឬ រារាំង |
| គោលនយោបាយវិនិយោគផ្នែកសាធារណៈ | ខ្ពស់ | មានការគាំទ្រខ្លាំង |
| គោលនយោបាយយ៉ែនឌ័រ | មធ្យម | មានការគាំទ្រ |
| ស្ថាប័នថ្នាក់តំបន់ និងអន្តរជាតិ | មធ្យម | មានការគាំទ្រខ្លាំង |
| **កំរិតវិស័យ** | | |
| គោលនយោបាយបរិស្ថាន | ខ្ពស់ | មានការរារាំងខ្លាំង |
| ការគ្រប់គ្រងដី | ខ្ពស់ | មានការគាំទ្រ ឬ រារាំង |
| គោលនយោបាយផ្គត់ផ្គង់ទឹកនៅទីក្រុង និងទីជនបទ | មធ្យម | មានការរារាំង |
| គោលនយោបាយគ្រប់គ្រងគ្រោះមហន្តរាយ | មធ្យម | មានការគាំទ្រ |
| គោលនយោបាយព្រៃឈើ | មធ្យម | មានការគាំទ្រ ឬ រារាំង |
| គោលនយោបាយគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខស្បៀង | ទាប ទៅ មធ្យម | មានការគាំទ្រ |
| គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល | ទាប | មានការគាំទ្រ |
| គោលនយោបាយផ្នែកជលផល | ទាប | មានការរារាំង |

រចនាសម្ព័ន្ធស្ថាប័ន ក្នុងវិស័យកសិកម្ម និងទឹក មានភាពស្មុគ្រស្មាញ ។ ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនាំមុខ គឺមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងវិស័យកសិកម្ម និង ទឹក ដោយឡែកៗពីគ្នា ។ ទោះបីជាយ៉ាងនេះក្តី ក្រសួងមួយចំនួនទៀត ក៏មានការពាក់ព័ន្ធនឹងវិស័យកសិកម្ម និង ធនធានទឹកដែរ ដូចជា ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ និង

ក្រសួងពាណិជ្ជកម្ម ។ ក្រសួងផ្សេងៗទៀត ដូចជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិទន្លេមេគង្គ មានការជាប់ពាក់ព័ន្ធតិច ប៉ុន្តែមានការចាប់អារម្មណ៍យ៉ាងសំខាន់ ។ ដោយសារតែការទំនាក់ទំនងរបស់វិស័យកសិកម្ម និងធនធានទឹក ទៅនឹងការងារជនបទនៅថ្នាក់មូលដ្ឋាននោះ អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត គឺមានរដ្ឋបាលថ្នាក់ស្រុក និង ខេត្ត ក៏ដូចជាអង្គការដែលមានមូលដ្ឋាននៅសហគមន៍ និង អង្គការក្រៅរដ្ឋាភិបាល ។ វាជាការពិតណាស់ដែលថា អ្នកពាក់ព័ន្ធសំខាន់បំផុតនោះ គឺកសិករ ។

ក្នុងចំណោមក្រុមការងារបច្ចេកទេសចំនួន ១៨ ដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសំរបសំរួលដល់កិច្ចសហប្រតិបត្តិការជាមួយ និងរវាងបណ្តាដៃគូរអភិវឌ្ឍន៍ខាងក្រៅនោះ ក្រុមការងារបច្ចេកទេសមួយ សំរាប់វិស័យកសិកម្ម និងទឹក បានទទួលភារកិច្ច ចំពោះវិស័យកសិកម្ម និងទឹក ហើយបានបង្កើតក្រុមយុទ្ធសាស្រ្តមួយ ដើម្បីរៀបចំយុទ្ធសាស្រ្តសំរាប់វិស័យកសិកម្ម និងទឹក ។

## ២.២- ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង

ការរៀបចំយុទ្ធសាស្រ្ត សំរាប់វិស័យកសិកម្ម និងទឹក ផ្អែកជាសំខាន់ទៅលើការវិភាគ លើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT) ។ ការវិភាគ គឺមានបង្ហាញនៅក្នុងឯកសារការងារនៃការវិភាគយុទ្ធសាស្រ្ត និងមានសង្ខេបក្នុងឯកសារនេះ ក្នុងតារាង ២.២ ។

ភាពខ្លាំងដែលរៀបរាប់ក្នុងតារាង ២.២ បានលើកឡើងថា គុណសម្បត្តិជាយុទ្ធសាស្រ្ត របស់ប្រទេសកម្ពុជានោះ គឺថា ប្រទេសកម្ពុជា មានធនធានធម្មជាតិ និងធនធានមនុស្ស ដែលនៅពេលបច្ចុប្បន្ន មិនទាន់ប្រើប្រាស់អស់នៅឡើយ ។ ក្នុងចំណោមភាពខ្សោយទាំង ៨ប់ មានប្រាំ ទាក់ទងទៅនឹងធនធានធម្មជាតិ (ជីវជាតិដី និងធនធានទឹក ដែលអាចទុកចិត្តបាន) និងពលកម្ម ។ កត្តាទាំងនេះហើយដែលវាក៏រិតនូវវិសាលភាព ដែលធនធានធម្មជាតិ និងពលកម្មទាំងនោះ អាចចាត់ទុកជាភាពខ្លាំងនោះ ។ ជាពិសេស ភាពខ្សោយចំនួនបី ដែលទាក់ទងទៅនឹងពលកម្មនោះ គឺលើប្រសិទ្ធិភាពនៃការប្រមូលកំលាំងពលកម្មនៅក្នុងប្រទេសកម្ពុជា ។ វាហាក់ដូចជាក៏រិតយ៉ាងខ្លាំង លើតំលៃដែលអាចមាននៃកំលាំងពលកម្មដែលសំបូរនោះ ហើយចាំបាច់ ត្រូវមានសកម្មភាពច្បាស់លាស់ ក្នុងការចាត់ចែងលើបញ្ហាទាំងនេះ ។

ភាពខ្សោយចំនួនបួនទៀតបានបង្ហាញថា ការប្រើប្រាស់នូវធនធានបីប្រភេទ ដូចជា មូលធន ពត៌មាន និងបច្ចេកវិទ្យា និងទីផ្សារ គឺនៅមានក៏រិតនៅឡើយនៅក្នុងប្រទេសកម្ពុជា ។ ភាពខ្សោយដ៏ទៃទៀត គឺ ផលិតភាពនៃពលកម្មកសិកម្ម ដីធ្លី និងទឹកនៅទាប (ធនធានត្រូវបានប្រើប្រាស់ដោយមិនមានប្រសិទ្ធិភាព) ដែលករណីនេះ វាស្ទើរតែជាករណីរួម ដែលក្តោបលើផលវិបាកនៃភាពខ្សោយផ្សេងៗទៀតនោះ ។ សរុបមក ភាពខ្សោយទាំង៨ប់នោះ វាផ្តល់នូវគុណវិបត្តិជាយុទ្ធសាស្រ្តសំរាប់ប្រទេសកម្ពុជា ក្នុងវិស័យកសិកម្ម និងទឹក ។ ធនធានចំនួនបី ត្រូវ

ចាត់ទុកជាភាពខ្សោយ ចំណែកឯធនធានពីរទៀត (ចាត់ទុកជាភាពខ្លាំងក្នុងតារាង ២.២) វាមានកំរិតកំណត់ក្នុងការចាត់ថ្នាក់វា ។ យើងអាចនិយាយម្យ៉ាងទៀតថា យើងមានឱកាសច្រើនក្នុងការបង្កើតនូវភាពខ្លាំង និងបំបាត់នូវភាពខ្សោយ ។

កាលនុវត្តភាព មានទំនាក់ទំនងយ៉ាងច្រើនជាមួយភាពខ្លាំង និងភាពខ្សោយ ហើយដែលទាក់ទងទៅនឹងធនធានចំនួន ៤ ក្នុងចំណោមប្រភេទធនធានទាំង ៥ ដែលបានរៀបរាប់ខាងលើ ។ ជាទូទៅ ភាពគំរាមកំហែងមិនទាក់ទងទៅនឹងធនធានទេ ប៉ុន្តែ វាទាក់ទងទៅនឹងបរិយាកាសសំរាប់វិស័យកសិកម្ម និង ទឹកនេះផ្ទាល់ ។ ដូចនេះ ភាពគំរាមកំហែង មានចំនួន ៤ ដែលទាក់ទងទៅនឹងកត្តានយោបាយ អភិបាលកិច្ច សង្គម និងច្បាប់ ។ កត្តាទាំងអស់នេះ វាគ្របដណ្តប់ទៅលើ បរិយាកាសដែលថា តើវានឹងធ្វើអោយមានការលើកទឹកចិត្តដល់កសិករ ក្នុងការវិនិយោគ និងអភិវឌ្ឍន៏ក្នុងអនុវិស័យនេះ ឬ ក៏វាបន្ទុចបង្អាក់ និងបង្កនូវឧបសគ្គដល់ការវិនិយោគនេះ ។ ជារួមហានិភ័យនោះ គឺថា ការប្តេជ្ញាចិត្តនាពេលបច្ចុប្បន្នចំពោះការកែទំរង់ និងការអនុវត្តន៏របស់វានោះ អាចធ្វើឱ្យរអាក់រអួល ឬ មិនឆ្លើយតបទៅនឹងបញ្ហា ដែលមានការទាក់ទងជាពិសេសទៅនឹងកសិកម្ម និង ទឹក ឬ យ៉ាងណា ។ ប្រសិនបើវាមានករណីដូចនេះមែននោះ ផ្នែកនៃយុទ្ធសាស្រ្តដែលបង្កើតឡើង ដោយផ្អែកលើ បរិយាកាសល្អនោះនឹងមានការពិបាកក្នុងការអនុវត្តន៏ឱ្យបានពេញលេញណាស់ ។ បញ្ហាសំខាន់នោះ គឺថា ក្របខ័ណ្ឌយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ អាចជួបការលំបាក ក្នុងការអនុវត្តន៏ ហើយដែលអាចរាំងស្ទះដល់ការអនុវត្តន៏ នូវយុទ្ធសាស្រ្តសំរាប់វិស័យកសិកម្ម និងទឹក ជាពិសេស នៅថ្នាក់ស្រុក ។

**តារាង ២.២**-ការគ្រប់គ្រងកសិកម្ម និងធនធានទឹក-សេចក្តីសង្ខេបនៃការវិភាគលើ SWOT

| **ភាពខ្លាំង** | **ភាពខ្សោយ** |
|---|---|
| ១-មានធនធានដី<br>២-មានធនធានទឹក<br>៣-មានធនធានមនុស្ស (ពលកម្ម) ច្រើននៅតាម ទីជនបទដែល មានតំលៃពលកម្មថោក<br>៤-រកសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធាន ទឹក និងឧតុនិយម មានសក្តនុពលធនធានមនុស្សល្អ<br>៥-ក្របខ័ណ្ឌយុទ្ធសាស្រ្ត និង/ឬ គោលនយោបាយ ត្រូវបានរៀបចំឡើងសំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម<br>៦-អ្នកពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្ត និងទទួលស្គាល់នូវសារៈសំខាន់ នៃវិស័យនេះ (រដ្ឋាភិបាល | ១-សមត្ថភាពរបស់អង្គភាព ការគ្រប់គ្រង និងការអនុវត្តន៏គំរោងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយមនៅខ្សោយ<br>២-ធនធានទឹកមានភាពប្រែប្រួលខ្លាំងទៅតាមពេលវេលា និង ទីកន្លែង ហើយបច្ចេកទេសគ្រប់គ្រងទឹក សំរាប់កសិកម្ម មិនទាន់បានអភិវឌ្ឍន៏ឱ្យបានល្អ<br>៣-សមត្ថភាពវិនិយោគ ឬការចាប់អារម្មណ៏ ក្នុងការបណ្តាក់ទុន ក្នុងវិស័យកសិកម្មនៅមានកំរិត<br>៤-ការផ្ទេរនូវបច្ចេកវិទ្យានៅខ្សោយ ហើយកសិករ និងអ្នក ផ្សព្វផ្សាយមានចំណេះដឹង បច្ចេកទេស និងជំនាញតិច<br>៥-ជីវជាតិដីទាបនៅកន្លែងជាច្រើន |

| | |
|---|---|
| ដៃគូរអភិវឌ្ឍន៍ខាងក្រៅ អង្គការក្រៅរដ្ឋាភិបាល និងកសិករ)<br>៧-មានពិពិធកម្មក្សេត្រ-បរិស្ថាន ដោយមានប្រភេទដី និងដំណាំដាំដុះច្រើនប្រភេទ<br>៨-បង្កើតឡើង ដោយផ្តោតលើការផ្ទេរសិទ្ធិ និងការអនុវត្តន៍ដោយសហគមន៍ តាមរយៈអន្តរក្រុមប្រឹក្សាសហគមន៍សហគមន៍កសិករប្រើប្រាស់ទឹក និងអង្គការកសិករនានា<br>៩-កសិ-ធុរកិច្ចត្រូវបានកំពុងបង្កើត | ៦-ភាពខ្សោយខាងវប្បធម៌សង្គម មានសាមគ្គីភាពតិច ភាពងាយបាត់បង់ដីធ្លី និងលួចដីធ្លីរបស់កសិករ វប្បធម៌ ដែលផ្តោតការចិញ្ចឹមជីវិតលើកសិកម្ម ដែលថា "ទី១អង្ករ ទី ២ ត្រី"<br>៧-មានពតិមានមិនស៊ីចង្វាក់គ្នា រវាងបណ្តាអ្នកពាក់ព័ន្ធ<br>៨-ផលិតភាពពលកម្មកសិកម្ម ដី និងទឹកនៅទាប ( ធនធាន ត្រូវបានប្រើដោយមិនមានប្រសិទ្ធិភាព)<br>៩-ច្រកចូលទីផ្សារនៅមានតិច<br>១០-ឧបករណ៍អនុវត្តន៍ច្បាប់ សំរាប់វិស័យកសិកម្ម និងទឹក មិនទាន់មានគ្រប់គ្រាន់ ឬ មិនបានអនុវត្តន៍ |
| **កាលានុវត្តភាព**<br>១-ការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច រួមទាំងការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជា (ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល) ការកំណត់គោលនយោបាយ និងស្ថេរភាពនយោបាយ ។<br>២-បង្កើតទីផ្សារ និងបញ្ជ្រាបចូលក្នុង សេដ្ឋកិច្ច តំបន់ និងសកលលោក ។<br>៣-មានការគាំទ្រខ្លាំង ពីដៃគូអភិវឌ្ឍន៍ខាងក្រៅ ក្នុងការវិនិយោគក្នុងវិស័យកសិកម្ម និងទឹក<br>៤-មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗ<br>៥-អាចធ្វើអាជីវកម្មឱ្យពេញលេញថែមទៀត លើធនធានធម្មជាតិ (ដី និងទឹក)ដែលបច្ចុប្បន្ន មិនទាន់បានប្រើអស់ ឬមិនបានប្រើ<br>៦-មានទុនសំរាប់វិនិយោគ រួមទាំងការលើកទឹកចិត្ត ទុនឯកជន និងសេវាកម្មឥណទានជនបទ<br>៧-មានគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | **ការគំរាមកំហែង**<br>១-ការប្រែប្រួលនៅទីផ្សារ រួមទាំងទីផ្សារអន្តរជាតិដែលមានការប្រកួតប្រជែងខ្លាំង<br>២-តំលៃប្រេង និងឧស្ម័នខ្ពស់<br>៣-ស្ថានភាពនយោបាយ រួមទាំងមានការប្រជែងគ្នា ក្នុងការសុំប្រើថវិការរបស់រដ្ឋាភិបាលពីវិស័យផ្សេងទៀត<br>៤-ស្ថានភាពច្បាប់ រួមទាំងការខកខានមិនបានអនុវត្តន៍ច្បាប់ដីធ្លី ទឹក និងព្រៃឈើ ។ល។<br>៥-គ្រោះធម្មជាតិ<br>៦-មានការខូចខាតបរិស្ថាន<br>៧-ការខកខានមិនបានអនុវត្តន៍នូវការកែទំរង់ផ្នែកអភិបាលកិច្ច តុលាការ និងការ កែទំរង់ក្នុងផ្នែកផ្សេងៗទៀត<br>៨-មានការប្រែប្រួលស្ថានភាពសង្គម និងនយោបាយ ដូចជា ទំនាស់សង្គម លើការប្រើប្រាស់ទឹក និងដី ការធ្វើអន្តោប្រវេសន៍ពលកម្ម ។<br>៩-មានការថយចុះ នូវការគាំទ្រពីដៃគូអភិវឌ្ឍន៍ខាងក្រៅ លើវិស័យកសិកម្ម និងធនធានទឹក |

## ២.៣-បញ្ហាតាមវិស័យ

នៅពេលធ្វើការវិភាគដំបូង ក្រុមយុទ្ធសាស្ត្រ B1 បានកំណត់នូវបញ្ហាសំខាន់ៗមួយចំនួន ដែលធ្វើឱ្យមានការកើនឡើងនូវហានិភ័យ ដែលអាចធ្វើឱ្យយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក មិនបានអនុវត្តន៍ទៅបានពេញលេញ ( ផ្នែកទី ៩ នៃឯកសារវិភាគយុទ្ធសាស្ត្រ-Strategic Profile) ។ បញ្ហាទាំងនោះ ជារួម មាន:

### ១-វិស័យជាអាទិភាពក្នុងការវិនិយោគ

ជាទូទៅ តែងមានការប្រជែងគ្នា ក្នុងការប្រើប្រាស់នូវថវិការរបស់រដ្ឋាភិបាល ហើយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ តែងតែយកចិត្តទុកដាក់លើផ្នែកអភិវឌ្ឍន៍សហគមន៍ និងសង្គម មានដូចជា សុខភាព អប់រំ ការផ្តល់សិទ្ធដល់ស្ត្រី ។ល។ ដូចនេះ ការវិនិយោគដោយប្រភពឯកជន និងការកាត់បន្ថយនូវការពឹងផ្អែកលើទុនសាធារណៈ និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ គឺជាការចាំបាច់ក្នុងវិស័យកសិកម្ម និងទឹក ។

### ២-ភាពសំខាន់នៃប្រព័ន្ធគ្រប់គ្រងទឹកតាមគ្រួសារខ្នាតតូច មធ្យម និងធំ

មានការពិភាក្សាវែកញែកលើទំហំនៃការវិនិយោគ ដែលមានប្រសិទ្ធិភាពបំផុត នៅក្នុងប្រទេសកម្ពុជា ។ បញ្ហាសំខាន់ គឺទាក់ទងទៅនឹងបច្ចេកទេស ស្ថេរភាព ប្រសិទ្ធិភាព ភាពពាក់ព័ន្ធសង្គម និងបរិស្ថាន នៃទំហំរបស់ប្រព័ន្ធធារាសាស្ត្រនានានោះ ។ ជាការពិតហើយ វាមិនមែនជាបញ្ហាដែលថា តើទំហំប៉ុណ្ណានោះទេ ប៉ុន្តែថា តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានតុល្យភាព ហើយត្រូវអនុវត្តន៏វា នៅកន្លែងណាដែលសមស្របតាមស្ថានភាពជលសាស្ត្រ និងសង្គម និងអាចបង្កើននូវចំណូលសេដ្ឋកិច្ច ។

### ៣-សារៈសំខាន់នៃដំណាំស្រូវ និងដំណាំដីទៃទៀត

មានផលិតផលស្រូវគ្រប់គ្រាន់ក្នុងរដូវមួយ មានន័យថា មានសន្តិសុខស្បៀង សំរាប់កសិករធម្មតា របស់កម្ពុជា ។ ដូចនេះ ការផលិតស្រូវមានអាទិភាពលើដំណាំផ្សេងទៀត នៅកន្លែងជាច្រើន ។ ដើម្បីជំរុញឱ្យកសិករធម្មតា ក្នុងការដាំនូវដំណាំដីទៃទៀត ដែលមានការប្រថុយប្រថាននោះ គឺទាមទារឱ្យមាននូវកេរ្តិ៍នៃការជឿជាក់ខ្ពស់ថា ផលដែលទទួលបានមកនោះ វាច្រើនជាងស្រូវ និងហានិភ័យក្នុងការបាត់បង់នូវទុនវិនិយោគរបស់គេ ( មានគ្រាប់ពូជ ពលកម្ម ។ល ។) នឹងមានកេរ្តិ៍តទាប និងថា សន្តិសុខស្បៀងមិនត្រូវបានបំភ្លេច ។

### ៤-សារៈសំខាន់នៃដីដាំដំណាំ ដែលមានការស្រោចស្រព និងពឹងលើទឹកភ្លៀង

ការស្រោចស្រពត្រូវបានយកចិត្តទុកដាក់ខ្លាំង ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ប៉ុន្តែតាមតួលេខរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ដីដាំដំណាំដែលមានការស្រោចស្រពមានតិចជាង ២០% នៃផ្ទៃដីដាំដំណាំសរុបដែលមាន ដោយសារតែលក្ខណភូមិសាស្ត្រមិនសមស្រប និងនៅឆ្ងាយពីប្រភពទឹក ដូចនេះ ដីដាំដំណាំភាគច្រើន គឺនឹងនៅតែពឹងផ្អែកលើទឹកភ្លៀង ។ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រព ប្រហែលជាអាចផ្តល់នូវចំណូលលឿន និងមានលក្ខណៈពិតប្រាកដជាង នៅកន្លែងណាដែលវាអាចអនុវត្តន៏បាន ។ ទោះជាយ៉ាងនេះក្តី អ្នកខ្លះលើកឡើងថា ការអនុវត្តន៏នូវបច្ចេកវិទ្យាគ្រប់គ្រងទឹកទំនើប ចំពោះកសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀងនោះ នឹងនាំឱ្យមានប្រសិទ្ធភាពតំលៃ និងងាយស្រួលគ្រប់គ្រង ហើយមានផលប្រយោជន៍ទូលំទូលាយ ក្នុងរយៈពេលវែង ។

វាមិនមែនជាបញ្ហានៃវិធីសាស្ត្រផ្សេងគ្នានោះទេ ប៉ុន្តែវាជាបញ្ហានៃការជ្រើសរើសការប្រើប្រាស់ នៅកន្លែងណា ដែលវាសមស្របនោះ និងថា តើត្រូវប្រៀបធៀបក្នុងលក្ខណជាប្រាក់ និងផលប្រយោជន៍សង្គម យ៉ាងដូចម្តេច ហើយថា តើត្រូវធានានូវការវិនិយោគប្រកបដោយសមភាព ដែលផ្តល់ប្រយោជន៍ដល់ប្រជាជននៅជនបទទាំងអស់នោះ យ៉ាងដូចម្តេច ។

### ៥-ការបែកមែកធាង (proliferation) នៃយុទ្ធសាស្ត្រ

ភាក់ងាររាជរដ្ឋាភិបាលកម្ពុជាជាច្រើន ដែលមានភារៈកិច្ចទាក់ទងនឹងកសិកម្ម និងទឹក បានបង្កើតនូវយុទ្ធសាស្ត្ររបស់ខ្លួន ។ អាទិភាពរបស់គេ គឺមិនមានដូចគ្នានោះទេ ព្រោះថា ភ្នាក់ងារទាំងអស់នោះ ផ្តោតការយកចិត្តទុកដាក់លើបេសកកម្មរបស់គេ ជាជាងលើវិធីសាស្ត្រដែលទាក់ទងតាមវិស័យ ដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានតំរូវឱ្យរៀបចំតាមនោះ ។ ការពិភាក្សា ឬទំនាក់ទំនង នៅពេលដែលរៀបចំយុទ្ធសាស្ត្រនិមួយៗ គឺនៅមានកំរិត ដែលមានន័យថា នៅក្នុងការអនុវត្តន៍ នឹងជួបប្រទះនូវរឿងដូចគ្នានេះដែរ ។

### ៦-ការត្រួតគ្នា និងភាពមិនច្បាស់លាស់ ចំពោះការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ

ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធជាច្រើន ក្នុងអនុវិស័យតែងមានការត្រួតគ្នា ដាច់ៗគ្នា គ្មានការទំនាក់ទំនង ឬ មិនច្បាស់លាស់ ជាពិសេសនៅថ្នាក់ខេត្ត ។ ភ្នាក់ងាររដ្ឋាភិបាល ហាក់ដូចមានគោលដៅ ក្នុងការប្រជែងយកធនធាន និងការពារនូវផ្នែកដែលត្រូវគ្រប់គ្រងរបស់ខ្លួន ដែលធ្វើឱ្យចុះថយដល់កិច្ចសហប្រតិបត្តិការ និងនាំឱ្យមានសកម្មភាពឯករាជរៀងៗខ្លួន ។ អង្គការក្រៅរដ្ឋាភិបាល អង្គការដែលមានមូលដ្ឋាននៅសហគមន៍ និងកសិករខ្លួនឯង ក៏ជាអ្នកពាក់ព័ន្ធ និងមានកាទទួលខុសត្រូវផងដែរ ប៉ុន្តែស្ថាប័នទាំងនេះ កាន់តែពិបាកកំណត់ និងគ្រប់គ្រងទៅទៀត ។ ជាពិសេស អង្គការក្រៅរដ្ឋាភិបាល បានឱ្យតំលៃលើភាពឯករាជរបស់គេពីរដ្ឋាភិបាល ។

ជារួម រាល់បញ្ហាទាំង ៦ ដែលចេញពីមតិយោបល់ផ្សេងគ្នាទាក់ទងនឹងអាទិភាព ។ ប្រការនេះ គឺបានបញ្ជាក់ថា ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ត្រូវកំណត់នូវអាទិភាពច្បាស់លាស់ ចំពោះសកម្មភាព និងការវិនិយោគដែលបានលើកឡើង ។ ក្នុងការបង្កើតនូវក្របខ័ណ្ឌ វានឹងជាប្រការចាំបាច់ផងដែរ ក្នុងការពិនិត្យមើលឡើងវិញ លើបទពិសោធន៍កន្លងមក ក្នុងការអនុវត្តន៍នូវកម្មវិធី ដែលទាក់ទងនឹងវិស័យកសិកម្ម និងទឹក ។ ផ្នែកនេះ និងផ្នែកក្រោយៗទៀត បង្ហាញនូវកត្តាមួយចំនួន (ភាពខ្សោយ ការគំរាមកំហែង និង បញ្ហា) ដែលអាចរារាំងដល់ការអនុវត្តន៍ ។ ឧបសគ្គ ចំពោះជោគជ័យទាំងនេះ គឺតំរូវឱ្យមានការឆ្លើយតប ជាយុទ្ធសាស្ត្រមួយ ដោយអ្នកគ្រប់គ្រងតាមវិស័យ ដែលធ្វើការដោយមានការសហការគ្នាយ៉ាងជិតស្និទ្ធ ។




**រូបភាព៣.១**-លំដាប់នៃការរៀបចំ ឬ រចនាសម្ព័ន្ធនៃសមាសធាតុរបស់យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក

## ៣. លំដាប់នៃការរៀបចំយុទ្ធសាស្ត្រ : ចេញពីសកម្មភាព ឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច

គោលដៅសំខាន់បំផុតរបស់យុទ្ធសាស្ត្រ គឺដើម្បីសំរេចបាននូវអាទិភាព ដែលបានលើកឡើង ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច ។ លំដាប់នៃការរៀបចំ ឬ រចនាសម្ព័ន្ធគោលគំនិតនៃយុទ្ធសាស្ត្រ មានសង្ខេបក្នុងរូបភាព ៣.១ ។ ទស្សនៈវិស័យសំរាប់រយៈពេលវែង ចំពោះវិស័យកសិកម្ម និងទឹក បានបង្ហាញថា តើវិស័យកសិកម្ម និងទឹក ត្រូវរួមចំណែកក្នុងអាទិភាពរួមរបស់ជាតិ យ៉ាងដូម្តេច ។ ពិសេសជាងនេះទៀតនោះ គឺថា គោលដៅចំបងសំរាប់វិស័យកសិកម្ម និងទឹក បានលើកឡើងនូវអ្វីដែលត្រូវសំរេចឱ្យបានក្នុងវិស័យនេះ ក្នុងកំលុងឆ្នាំ ២០០៦-២០១០ ។ គោលដៅអភិវឌ្ឍន៍ចំនួនប្រាំ ត្រូវបានកំណត់ ដែលផ្តោតការយកចិត្តទុកដាក់លើកម្មវិធីចំនួនប្រាំ ។ ដោយអនុវត្តន៍តាមការណែនាំរបស់ក្រសួងផែនការ គោលបំណងជាក់លាក់ថែមទៀត នឹងត្រូវបង្កើតឡើង សំរាប់ផ្នែកនៃកម្មវិធីនិមួយៗ ហើយសកម្មភាព នឹងត្រូវកំណត់ឡើងដើម្បីបំបាត់នូវឧបសគ្គ ដែលរារាំងដល់ការសំរេចនូវគោលបំណងទាំងនោះ ។ ក្នុងលក្ខណជាមធ្យោបាយ នៃការរៀបចំនូវសកម្មភាពឱ្យមានលក្ខណរៀបរយ និងជាក់ស្តែងមួយនោះ សកម្មភាពក្នុងផ្នែកនៃកម្មវិធីនិមួយៗក៏នឹងត្រូវបានកំណត់ផងដែរ ។

## ៤.ទស្សនវិស័យ និងគោលបំណង សំរាប់វិស័យកសិកម្ម និងទឹក

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានលើកឡើងថា អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍ជាតិ ក្នុងកំលុងឆ្នាំ ២០០៦-២០១០ គឺការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច ដែលត្រូវសំរេចឱ្យបាន ជាពិសេស តាមរយៈការបង្កើននូវវិស័យកសិកម្ម ។ ផែនការយុទសាស្ត្រអភិវឌ្ឍន៍ សំរាប់វិស័យកសិកម្ម និងធនធានទឹក ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានលើកឡើងនូវ ទស្សនៈវិស័យ និងគោលដៅតាមវិស័យ ដែលរួមចំណែកដល់ការអភិវឌ្ឍន៍ជាតិ ។ ក្រុមយុទ្ធសាស្ត្រ B1 បានប្រើនូវករណីទាំងនេះ ជាចំណុចចាប់ផ្តើម ក្នុងការកំណត់នូវទស្សនៈវិស័យ និងគោលដៅសំរាប់យុទ្ធសាស្ត្ររួម ក្នុងវិស័យកសិកម្ម និងទឹក ។

### ៤.១.ទស្សនៈវិស័យសំរាប់វិស័យកសិកម្ម និងទឹក

ទស្សនៈវិស័យ សំរាប់រយៈពេលវែង ចំពោះវិស័យកសិកម្ម និងទឹកគឺ:

ធានាឱ្យមានអាហារ និងទឹកគ្រប់គ្រាន់ និងមានសុវត្ថិភាពសំរាប់ប្រជាជនគ្រប់រូប កាត់បន្ថយភាពក្រីក្រ និងរួមចំណែកដល់ការលូតលាស់សេដ្ឋកិច្ច ដែលទន្ទឹមនឹងនោះ ក៏ធានាបាននូវនិរន្តរភាពធនធានធម្មជាតិផងដែរ ។

## ៤.២-គោលដៅចំបងសំរាប់ឆ្នាំ ២០០៦-២០១០

គោលដៅចំបង សំរាប់ការគ្រប់គ្រងវិស័យកសិកម្ម និងធនធានទឹក ក្នុងរយៈពេលឆ្នាំ ២០០៦-២០១០ គឺ:

***រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការលូតលាស់សេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាពកសិកម្ម និងពិពិធកម្ម និងបង្កើនការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក ។***

ដើម្បីសំរេចបាននូវគោលដៅចំបងនេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើ :

១-ការបង្កើននូវសន្តិសុខស្បៀង និងចំណូលរបស់សហគមន៍ និងគ្រួសារនៅជនបទ

២-ការកាត់បន្ថយនូវភាពងាយរងគ្រោះ របស់សហគមន៍ និងគ្រួសារនៅជនបទ

៣-បង្កើននូវផលិតផលកសិកម្ម ដែលលើសសេចក្តីត្រូវការប្រើប្រាស់ក្នុងគ្រួសារ សំរាប់កែច្នៃ និងនាំចេញ

៤-ការអភិវឌ្ឍន៍ និងគ្រប់គ្រងលើដីធ្លី និងធនធានទឹករបស់ជាតិ ប្រកបដោយនិរន្តរភាព

## ៤.៣- គោលដៅអភិវឌ្ឍន៍ សំរាប់កំលុងឆ្នាំ ២០០៦-២០១០

គោលដៅចំបងបំផុតសំរាប់ឆ្នាំ ២០០៦-២០១០ នឹងត្រូវសំរេចបាន ជារួម ដោយការបង្កើននូវផលិតភាពកសិកម្ម ប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពថែមទៀត នូវដីធ្លី និងទឹក និងពង្រីកនូវដំណើរការកសិ-ពាណិជ្ជកម្ម ។ ការកសាងសមត្ថភាពស្ថាប័ន ជាពិសេស ក្នុងការផ្ទេរនូវចំណេះដឹង និងបច្ចេកវិជ្ជា គឺជាករណីចាំបាច់ ។ តាមរយៈនេះ គោលដៅអភិវឌ្ឍន៍ដូចខាងក្រោម ត្រូវបានកំណត់ សំរាប់ឆ្នាំ ២០០៦-២០១០:

១-ប្រព័ន្ធកសិកម្ម និងការរៀបចំសហគមន៍ដែលអាចឱ្យប្រជាជនកម្ពុជាដែលក្រីក្រ និងមានអសន្តិសុខស្បៀងនោះ អាចមានស្បៀង និងចំណីអាហារមានជីវជាតិគ្រប់គ្រាន់គ្រប់ពេល ដើម្បីឆ្លើយតបតាមតំរូវការចំណីអាហារ និងម្ហូបអាហារដែលគេចូលចិត្ត ដើម្បីមានជីវិតរស់នៅដោយសកម្ម និងមានផាសុខភាព ។

២-កសិកម្ម និងកសិ-ធុរកិច្ច ដែលប្រើប្រាស់នូវធនធាន ប្រកបដោយប្រសិទ្ធិភាព និងមានទីផ្សារនោះ ត្រូវបានបង្កើន និងធ្វើពិពិធកម្មជាប្រចាំ និងផ្តល់នូវផលប្រយោជន៍ពេញលេញដល់កសិករ សហគមន៍ជនបទ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

៣-ការគ្រប់គ្រងធនធានទឹក ដែលផ្តល់ប្រយោជន៍ដល់អ្នកក្រ ប្រកបដោយនិរន្តរភាព មធ្យោបាយគ្រប់គ្រងទឹក គ្រោះថ្នាក់ទាក់ទងនឹងទឹក និងធនធានដីធ្លី ដែលមានលក្ខណរួមគ្នា ប្រកបដោយប្រសិទ្ធភាព និងអនុវត្តន៍ទៅ ក្នុងបរិបទអាងទន្លេ ។

៤-សមត្ថភាពទូលំទូលាយ និងប្រកបដោយលក្ខណសំរបសំរួល ដើម្បីប្រមូល និងប្រើប្រាស់នូវចំណេះដឹងពត៌មាន និងការផ្ទេរនូវបច្ចេកវិជ្ជាទាកទងនឹងកសិកម្ម និងទឹក ។

៥-ការរៀបចំ ដែលផ្តល់នូវមូលដ្ឋានគោលនយោបាយ ច្បាប់ ស្ថាប័ន និងរដ្ឋបាលល្អមួយ សំរាប់អនុវត្តន៍ការងារប្រកបដោយប្រសិទ្ធិភាព ក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងកសិកម្ម និងធនធានទឹក ។

គោលដៅអភិវឌ្ឍន៍បីដំបូង ដែលលើកឡើងមុនគេនេះ ដោយសារវាផ្តល់នូវផលប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចផ្ទាល់ ដល់សហគមន៍ ។ គោលដៅពីរចុងក្រោយ ផ្តល់នូវផលប្រយោជន៍ជាប្រយោល ដល់សហគមន៍ តាមរយៈការពង្រឹងនូវសមត្ថភាពស្ថាប័ន នៃភ្នាក់ងារដែលដឹកនាំ ក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវរបស់គេ ។ ទោះជាយ៉ាងណាក៏ដោយ គោលដៅអភិវឌ្ឍន៍ទាំងប្រាំនេះ មានអាទិភាពស្មើៗគ្នា ចំពោះសកម្មភាពរបស់វានោះ ឬ អាចនិយាយម្យ៉ាងទៀតថា វាមានភាពចាំបាច់ដូចគ្នា ចំពោះជោគជ័យក្នុងវិស័យកសិកម្ម និងទឹក ។ គោលដៅអភិវឌ្ឍន៍នេះ វាកំណត់ដោយផ្ទាល់ នូវកម្មវិធីទាំងប្រាំ ដែលមានរៀបរាប់ក្នុងផ្នែកទី ៥ នេះ ។

## ៥.ការបង្កើតយុទ្ធសាស្ត្រ

នៅពេលដែលត្រូវបានរៀបចំរួចហើយ យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹកនេះ នឹងកំណត់នូវទិសដៅ និងដំណាក់កាល ដែលត្រូវអនុវត្តន៍ ដើម្បីសំរេចនូវគោលបំណងដែលបានកំណត់ក្នុងផ្នែក ៤.៣ និងធនធាន ដែលត្រូវការ ។ ចាប់ផ្តើមពីការវិភាគលើ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ដែលមានសង្ខេបក្នុងផ្នែក ២.២ នោះ ការរៀបចំ ត្រូវបានធ្វើឡើងដោយផ្អែកលើភាពខ្លាំង បំបាត់នូវភាពខ្សោយ ទាញយកផលប្រយោជន៍ពីឱកាស ដែលមាន និងជៀសវាង ឬ ប្រឆាំងនឹងការគំរាមកំហែង ។ យុទសាស្ត្រនេះ បានសំយោគនូវការវិភាគ ដែលមានបង្ហាញ ក្នុងឯកសារវិភាគយុទ្ធសាស្ត្រ (Strategic Profile) និងឯកសារបង្កើតយុទ្ធសាស្ត្រ ១ (Strategy Formulation I) ។ ការវិភាគដំបូងលើគោលគំនិតយុទ្ធសាស្ត្រ (Strategy Concept) មានភ្ជាប់ក្នុងឯកសារបន្ថែម ៥ ។

### ៥.១.ផ្នែកសំខាន់ៗ

ការវិភាគ ដែលធ្វើឡើងដោយក្រុមយុទ្ធសាស្ត្រ បានស្នើឱ្យមានជាប្រាំបីផ្នែកសំខាន់ៗ ក្នុងយុទ្ធសាស្ត្រនេះ ។ ផ្នែកទាំងនេះ អាចរៀបចំតាមលំដាប់លំដោយ ដែលឆ្លុះបញ្ចាំង មួយផ្នែក តាមលំដាប់ពេលវេលារបស់វា និងមួយផ្នែកទៀត តាមទិសដៅនៃភាពទំនាក់ទំនងរវាងផ្នែកទាំងនោះ ។

#### ៥.១.១.ការធានាមានលក្ខខ័ណ្ឌដើមដែលចាំបាច់ សំរាប់ជោគជ័យ

ករណីនេះរួមមាន ជាពិសេសៈ

- ស្ថានភាពម៉ាក្រូល្អ រួមទាំងអភិបាលកិច្ចល្អ និងការប្តេជ្ញាចិត្តក្នុងការអនុវត្តន៍ច្បាប់

- ការប្តេជ្ញាចិត្តក្នុងការរៀបចំតាមបែបវិមជ្ឈការ សំរាប់រដ្ឋបាលសាធារណៈ ដែលជាកត្តាចាំបាច់ ចំពោះសកម្មភាពដ៏មានប្រសិទ្ធភាព នៅថ្នាក់មូលដ្ឋាននៃសហគមន៍ជនបទ

- ការរកទីផ្សារអន្តរជាតិ តាមរយៈការចូលរួមក្នុងពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិ

- ការរប្តេជ្ញាចិត្តជាប្រចាំ របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ ក្នុងការវិនិយោគក្នុងវិស័យកសិកម្ម និងទឹក

សមាសធាតុទាំងអស់នេះ គ្រាន់តែជាផ្នែកមួយ ដែលមានការទាក់ទងដល់អ្នកពាក់ព័ន្ធ ក្នុងវិស័យកសិកម្ម និងទឹក ហើយដែលវាជាប្រការមួយល្អ ដែលកត្តាទាំងនោះ មានលក្ខណៈអំណោយផលល្អ នាពេលបច្ចុប្បន្ន ។ ប្រសិនបើមិនដូចនោះទេ លទ្ធភាពទទួលបានជោគជ័យរបស់យុទ្ធសាស្ត្រនេះនឹងត្រូវបានថយចុះជាច្រើន ហើយការគំរាមកំហែងដ៏ធំចំពោះយុទ្ធសាស្ត្រនេះនោះ គឺថា ការកែទំរង់អភិបាលកិច្ច ជាពិសេស ទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការនោះ អាចត្រូវបានពន្យាពេល ។ ទិដ្ឋភាពសំខាន់នៃការអនុវត្តន៍នូវយុទ្ធសាស្ត្រនេះ គឺធ្វើយ៉ាងណាឱ្យកត្តាទាំងនេះ មានលក្ខណអំណោយផលល្អ ដោយសារកត្តាទាំងនេះ វាអាចទទួលឥទ្ធិពលពីអ្នកពាក់ព័ន្ធ ។

## ៥.១.២_ការបង្កើតឱ្យមានបរិយាកាសល្អ ដែលចាំបាច់

បរិយាកាសល្អ សំរាប់វិស័យកសិកម្ម និងទឹក រួមមាន ជាពិសេស គឺគោលនយោបាយ ច្បាប់-បញ្ញត្តិ ការរៀបចំផ្នែកស្ថាប័ន និងហិរញ្ញវត្ថុ ដែលមានឥទ្ធិពលលើទំនុកចិត្តរបស់អ្នកពាក់ព័ន្ធ ក្នុងការវិនិយោគធនធានៈ

-ការអនុវត្តន៍នូវគោលនយោបាយ ច្បាប់ និងឧបករណ៍បទបញ្ជារផ្សេងទៀត ដែលទាក់ទងនឹងវិស័យកសិកម្ម និងទឹក

-កសាងសមត្ថភាពស្ថាប័ន ក្នុងភ្នាក់ងាររបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធ ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ដែលជាភ្នាក់ងារដឹកនាំ និងអង្គភាពថ្នាក់ខេត្ត រួមទាំងត្រូវមានការសំរបសំរួល ដោយមានប្រសិទ្ធិភាព រវាងបណ្តាភ្នាក់ងារទាំងអស់នោះផង

-ការរៀបចំលើកម្មសិទ្ធដីធ្លី និងការប្រើប្រាស់ទឹក ដែលបង្កើតឱ្យមានទំនុកចិត្តក្នុងការវិនិយោគ

-បង្កើតឱ្យមានបរិយាកាសហិរញ្ញវត្ថុ ឬសារពើពន្ធល្អ ដែលជំរុញដល់ការវិនិយោគរបស់ផ្នែកឯកជន

-ផ្តល់ និងរក្សានូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ជាពិសេស ក្នុងរូបភាពជាការដឹកជញ្ជូន ទូរគមនាគមន៍ និងទីផ្សារ ដែលជួយសំរួលដល់ការចូលទៅទីផ្សារ

-ធ្វើការទំនាក់ទំនងរវាងបណ្តាក្រសួងនានា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ

កត្តាទាំងនេះ ភាគច្រើនត្រូវបានលើកឡើង ក្នុងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយមិនចាំបាច់មានក្នុងវិស័យកសិកម្ម និងទឹកលំអិតទៀតទេ ។ ប្រការនេះ រួមមាន ជាពិសេស ការរៀបចំជាលក្ខណៈអន្តរជាតិ សំរាប់គ្រប់គ្រងទឹកទន្លេមេគង្គ ដែលឋិតក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គ របស់បណ្តាប្រទេសជាសមាជិក ក្នុងអាងទន្លេនោះ ។ ការវិភាគខាងដើម ជាពិសេស លើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង បានបង្ហាញថា

យុទ្ធសាស្ត្រនេះ ត្រូវមានបញ្ចូលនូវសកម្មភាព លើផ្នែកជាច្រើន នៃបរិយាកាសល្អនោះ ។ ត្រូវទទួលស្គាល់ថា កត្តាទាំងអស់ខាងលើនេះមានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរួចហើយ ។

### ៥.១.៣_ការប្រមែប្រមូលនូវធនធានធម្មជាតិ

ធនធានធម្មជាតិដែលសំខាន់សំរាប់វិស័យកសិកម្ម គឺដី ដីដាំដំណាំ និងទឹក ហើយធនធានជីវសាស្ត្រ ដូចជាពូជដំណាំ និង ជុលតិវារស ក៏មានសារៈសំខាន់ដែរ (ពន្លឺថ្ងៃ និងឧស្ម័នកាបូនិក ក៏ចាំបាច់ដែរ ប៉ុន្តែមិនអាចគ្រប់គ្រងបាន) ។ ដីដែលអាចដាំដុះជាច្រើន មិនទាន់បានប្រើសំរាប់កសិកម្ម និងនៅគ្របដណ្តប់ដោយព្រៃព្រៃគុម្ពោត ឬ រុក្ខជាតិធម្មជាតិ ឬ ពាក់កណ្តាលធម្មជាតិនៅឡើយ ។ ស្របពេលនោះដែរ ដីជាច្រើនដែលកំពុងដាំដុះបច្ចុប្បន្ន មានទិន្នផលទាប បើប្រៀបធៀបទៅនឹងសក្តានុពលរបស់វា ។ ការមានទឹក ទាំងក្នុងតំបន់ដែលស្រោចស្រព និងតំបន់ដែលពឹងផ្អែកលើទឹកភ្លៀង គឺជាកត្តាជោគជ័យសំខាន់ ក្នុងការជំរុញឱ្យកសិករឈានចេញពីផលិតកម្មដែលសំរាប់តែប្រើប្រាស់ផ្ទាល់ខ្លួន ទៅផលិកម្មសំរាប់ទីផ្សារ ។ ការស្រោចស្រព និងការគ្រប់គ្រងទឹកដ៏ទៃទៀត ដូចជាការការប្រមូលទឹកភ្លៀង គឺបានកាត់បន្ថយនូវហានិភ័យនៃការមិនទទួលបានផលរបស់ដំណាំ និងអាចឱ្យកសិករងាយរងគ្រោះដែលមានដីតិច និងមានធនធានតិច ធ្វើការផលិតនូវផលិតផលដែលមានតំលៃថ្លៃ និងមានហានិភ័យខ្ពស់ ។ សមាសធាតុនៃយុទ្ធសាស្ត្រ ក្នុងផ្នែកទាំងនេះ អាចរួមមាន:

-កំណត់នូវនូវលទ្ធភាពប្រើប្រាស់ និងបើកចំហរ ចំពោះដី ដែលអាចដាំដំណាំ ដែលមិនបានកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន ដោយប្រើនូវបច្ចេកវិជ្ជាដូចជា ការវិភាគកសិ-បរិស្ថាន (Agro-Ecosystems Analysis) ចំណាត់ថ្នាក់នៃសមត្ថភាពប្រើប្រាស់របស់ដី និងការធ្វើផែនការអាងទន្លេ

-កំណត់នូវលទ្ធភាពប្រើប្រាស់ដី ដែលអាចដាំដុះ ដែលមិនទាន់បានប្រើអស់លទ្ធភាព និងជំរុញដល់ការប្រើប្រាស់ ដែលប្រកបដោយផលិតភាពខ្ពស់ថែមទៀត

-រក្សា និងបង្កើននូវជីវជាតិដី ដោយបង្កើនការថែរក្សាដី និងទឹក និងបច្ចេកវិជ្ជាសមស្រប ក្នុងការគ្រប់គ្រងដី ។

-គ្រប់គ្រងធនធានទឹក ក្នុងលក្ខណរួម (ការគ្រប់គ្រងធនធានទឹករួម -IWRM)

-ផ្តល់នូវសមត្ថភាព (ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ។ល។) ក្នុងការផ្តល់នូវទឹកប្រកបដោយប្រសិទ្ធភាព និងមានតំលៃថោក នៅកន្លែង និងពេលណាដែលត្រូវការ និងក្នុងតែបរិមាណដែលត្រូវការ សំរាប់សមត្ថភាពផលិតរបស់ដី និងគុណភាពដីតែប៉ុណ្ណោះ ទាំងនៅលើដីដាំដំណាំ ដែលមានការស្រោចស្រ និងកន្លែង ដែលពឹងលើទឹកភ្លៀង

-កំណត់ និងធ្វើអាជីវកម្មលើធនធានជីវសាស្ត្រថ្មីៗ ដែលមានតំលៃផ្នែកកសិកម្ម និងធ្វើឱ្យប្រសើរឡើងតាមរយៈការបង្កាត់ពូជ

ទិដ្ឋភាពសំខាន់ក្នុងជំហាននេះ គឺត្រូវធានាថា ប្រព័ន្ធអេកូឡូស៊ីដែលសំខាន់ និងជីវចំរុះ ត្រូវបានថែរក្សា ទន្លេ និងបឹង ត្រូវបានការពារទប់ទល់នឹងការធ្វើឱ្យក្រខ្វក់ដោយ ជីគីមីកសិកម្ម (agri-chemical) និងរបស់ក្រខ្វក់ផ្សេងៗទៀត ផ្ទៃរងទឹកភ្លៀង ត្រូវបានការពារទប់ទល់នឹងការហូរច្រោះ និងប្រភេទនៃការខូចខាតដីទៃទៀត ហើយថា ដំណាក់កាលសមស្រប ត្រូវបានអនុវត្តន៍ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអាកាសធាតុ និងភាពប្រែប្រួលនានា ។ ធនធានធម្មជាតិ ត្រូវតែបានប្រើ ប្រកបដោយនិរន្តរភាព និងដោយឈរលើមូលដ្ឋាន មានសមភាព ជាពិសេស ដល់គ្រួសារក្រីក្រ និងមានស្ត្រីជាមេគ្រួសារនោះ ។

## ៥.១.៤.ការប្រមែប្រមូលនូវធនធានមនុស្ស និងហិរញ្ញវត្ថុ

ធនធានមនុស្សសំខាន់ ដែលបានកំណត់ក្នុងការវិភាគលើ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងនោះ គឺធនធានពលកម្មមនុស្ស (manpower) ចំណេះដឹងរបស់មនុស្ស (និយាយជារួម គឺចំណេះដឹងពត៌មាន និងបច្ចេកវិជ្ជា ឬ ដែលភាសាអង់គ្លេសហៅថា KIT) និងថវិការ ។ កត្តាទាំងនេះ រួមមានៈ

-សកម្មភាពស្រាវជ្រាវលើសង្គមវិទ្យា និងសេដ្ឋកិច្ចនៃសហគមន៍ជនបទ កសិកម្ម និងកសិ-ធុរកិច្ច ជាមូលដ្ឋានមួយសំរាប់ការវិភាគគោលនយោបាយ និងធ្វើផែនការ

-ប្រមូល និងផ្តល់នូវចំណេះវិជ្ជា ពត៌មាន និងបច្ចេកវិជ្ជាស្តីពីការអនុវត្តន៍ក្នុងកសិដ្ឋាន និងកសិ-ធុរកិច្ច

-ប្រមូល និងផ្តល់នូវចំណេះវិជ្ជា ពត៌មាន និងបច្ចេកវិជ្ជា ស្តីពីការគ្រប់គ្រងទឹកសំរាប់ដំណាំ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

-ផ្ទេរនូវចំណេះដឹង ពត៌មាន បច្ចេកទេស ដល់អ្នកដែលអាចប្រើប្រាស់ ក្នុងរូបភាព និងលក្ខណមួយ ដែលសមស្របទៅនឹងតំរូវការរបស់គេ

-ជួយដល់កសិករក្នុងការអនុវត្តន៍ នូវការពិសោធន៍ និងការបង្កើតគំនិតថ្មីៗរបស់គេផ្ទាល់

-បង្កើននូវកម្មវិធីអប់រំដែលមានលក្ខណរៀបរយ ក្នុងផ្នែកកសិកម្ម និងគ្រប់គ្រងទឹក នៅក៏រិតបណ្តុះបណ្តាលជំនាញ

-អប់រំ និងបណ្តុះបណ្តាលកសិករ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងប្រព័ន្ធតំលៃនៃកសិ-ធុរកិច្ច លើទិដ្ឋភាពបច្ចេកទេស និងការគ្រប់គ្រងអាជីវកម្ម ក្នុងការងាររបស់គេ

-ជួយសំរួលដល់ការចូលរួមរបស់ស្ត្រី ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ នៃការធ្វើកសិដ្ឋាន និងកសិ-ធុរកិច្ច

-ទាក់ទាញធនធានហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជា ដៃគូរអភិវឌ្ឍន៍ខាងក្រៅ អង្គការក្រៅរដ្ឋាភិបាល ។ល។ ក្នុងការវិនិយោគដែលមានលក្ខណល្អសំរាប់ផ្នែកសាធារណៈ

-បង្កើតនូវបរិយាកាសល្អ ទំនុកចិត្ត និងការលើកទឹកចិត្តសំរាប់ការវិនិយោគក្នុងវិស័យកសិកម្ម និងទឹកដោយផ្នែកឯកជន (តាំងពីកសិករម្នាក់ៗ រហូតដល់អាជីវកម្មជាលក្ខណៈអន្តរជាតិ)

-ផល់នូវទុនវិនិយោគ ដែលអាចរកបាន និងមានហានិភ័យទាប និងឥណទានជនបទ សំរាប់កសិករ ជាពិសេស គ្រួសារក្រីក្រ និងដែលមានស្ត្រីជាមេគ្រួសារ

មានផ្នែកមួយចំនួន ដែលទាក់ទងនឹងយុទ្ធសាស្ត្រនេះ មិនឋិតក្នុងក្របខ័ណ្ឌកសិកម្ម និងទឹកទេ ដូចជា សុខភាពសាធារណៈ និងសេវាអប់រំនៅជនបទ ។ បញ្ហាសំខាន់ គឺប្រាក់បៀវត្ស និងការលើកទឹកចិត្តផ្សេងៗទៀត ដែលត្រូវផ្តល់ដល់មន្ត្រីរបស់ក្រសួង ដែលកត្តានេះ វាទាក់ទងទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយដែលមិនអាចគ្រប់គ្រងបាន ដោយក្រសួងនានាខ្លួនឯងនោះ ។ សមាសធាតុខាងលើជាច្រើន ក៏ឋិតនៅក្រៅ ក្របខ័ណ្ឌរបស់អ្នកពាក់ព័ន្ធធំៗដែរ ជាពិសេស ផ្នែកដែលទាក់ទងនឹងថវិការ ហើយប្រហែលជាត្រូវចាត់ទុកវាក្នុង ផ្នែកបរិយាកាសល្អវិញ ។ ដូចនេះ ទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ គោលដៅរយៈពេលវែង ប្រហែលជាថា អ្នកពាក់ព័ន្ធ ទាំងនោះ ត្រូវធ្វើការសំរេចចិត្ត ក្នុងក្របខ័ណ្ឌទីផ្សារសេដ្ឋកិច្ច ដែលមានការប្រកួតប្រជែងមួយ ប៉ុន្តែករណីនេះ វានឹងត្រូវប្រើរយៈពេលច្រើនឆ្នាំ ក្នុងការសំរេចបាននូវគោលបំណងនេះ ។

## ៥.១.៥_ការផ្ទេរសិទ្ធិអំណាចដល់ប្រជាជន និងសហគមន៍

យុទ្ធសាស្ត្រក្នុងផ្នែកនេះ គឺទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងធនធាន ដែលនឹងលើកឡើងខាងក្រោមនេះ ប៉ុន្តែ ដោយផ្តោតលើសមត្ថភាព សំរាប់សកម្មភាពរបស់សហគមន៍ ឬ សហករណ៍នៅជនបទ ។ ជាជាប្រការសំខាន់ណាស់ នៅជនបទ ដែលសមាជិករបស់គេ មានការពឹងពាក់គ្នាទៅវិញទៅមក ជាពិសេស ទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធ ចែកចាយទឹក ទីផ្សារផលិតកម្ម ។ល។ ទិដ្ឋភាពសំខាន់ នៃការផ្ទេរសិទ្ធិអំណាច គឺសមត្ថភាពរបស់សហគមន៍ ក្នុង ការជៀសវាង ឬ យ៉ាងហោចណាស់ កាត់បន្ថយនូវផលប៉ះពាល់អាក្រក់ នៃគ្រោះធម្មជាតិ (ទឹកជំនន់ ដែលនាំ ឱ្យខូចខាត គ្រោះរាំងស្ងួត និងកូនរដូវប្រាំង ការកើតមាននូវសត្វល្អិត និងជំងឺ ។ល។) ។ កត្តាទាំងនោះ រួមមានៈ

-ផ្តល់នូវសិទ្ធិអំណាចដល់សហគមន៍ជនបទ ក្នុងការរៀបចំ និងទទួលខុសត្រូវ ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម របស់គេផ្ទាល់ ដោយជួយសំរួលដល់ការបង្កើតសហគមន៍ ការបណ្តុះបណ្តាលនូវជំនាញដែលចាំបាច់ នឹង បន្តជួយក្នុងផ្នែកស្ថាប័ន

-ផ្តល់នូវសិទ្ធអំណាចដល់ក្រុមកសិករ ឱ្យធ្វើការរួមគ្នា លើផ្នែកដែលទាក់ទងនឹងផលិតកម្ម ឬ ប្រព័ន្ធតំលៃ ដូចជាការទិញជី ការប្រើគ្រឿងចក្ររួម ការទទួលបាននូវពត៌មានទីផ្សារ ដែលអាចទុកចិត្តបាន និងការកែច្នៃ ផលិតផល និងរកទីផ្សារ

-ផ្តល់សិទ្ធដល់កសិករ ក្នុងការគ្រប់គ្រងនូវប្រព័ន្ធចែកចាយទឹក ក្នុងភូមិ-ឃុំ (ការប្រមូលទឹក ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងដោះទឹក)

-ផ្តល់នូវការលើកទឹកចិត្តដល់កសិករ ក្នុងការវិនិយោគ ដោយធានាថា មានបរិយាកាសល្អ ដោយមាន ឥណទានជនបទ មានសេវាកម្មស្តុក និងកែច្នៃ ។ល។ មានលក្ខណអំណោយផលល្អ

-ជួយដល់កសិករ ដើម្បីឱ្យពួកគាត់ អាចកាត់បន្ថយនូវផលប៉ះពាល់អាក្រក់នៃគ្រោះធម្មជាតិ

វាជាប្រការសំខាន់ ដែលទិដ្ឋភាពខាងលើទាំងអស់ នៃការផ្ទេរសិទ្ធអំណាចនេះ មិនត្រូវបានអនុវត្តន៍ឡើង ដោយដាច់ៗពីគ្នានោះ ឧទាហរណ៍ដូចជា មានការបង្កើតឡើងនូវសហគមន៍ជាច្រើន ដែលមិនមានការទំនាក់ទំនងគ្នា ។ ការផ្ទេរសិទ្ធអំណាចដល់សហគមន៍ ត្រូវធ្វើក្នុងរបៀបមួយដែលអាចក្លាយជាទំលាប់ ក្នុងការរស់នៅរបស់សហគមន៍ ។

## ៥.១.៦-គ្រប់គ្រងធនធានធម្មជាតិ ក្នុងកំរិតអាងទន្លេ

ធនធានទឹក ដី និងដីដាំដុះ ត្រូវគ្រប់គ្រងក្នុងក្របខ័ណ្ឌមួយ ដែលអាចឱ្យអ្នកពាក់ព័ន្ធទាំងអស់ មានឥទ្ធិពលលើការគ្រប់គ្រងធនធាន ដែលគេពឹងផ្អែកលើនោះ ។ គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺការធ្វើវិមជ្ឈការ លើផ្នែករដ្ឋបាលសាធារណៈ ដល់ថ្នាក់ខេត្ត ស្រុក និងឃុំ ហើយចំពោះទិដ្ឋភាពជាច្រើន នៃការគ្រប់គ្រងកសិកម្ម និងទឹក ប្រការនេះ វានឹងផ្តល់នូវក្របខ័ណ្ឌដ៏សមស្របមួយ ។ ទោះជាយ៉ាងណាក៏ដោយ ធនធានធម្មជាតិ ទឹក ដី ដីដាំដំណាំ និងរុក្ខជាតិដែលគ្របដណ្តប់នោះ វាកំរនឹងនៅស្របតាមព្រំប្រទល់រដ្ឋបាលណាស់ ។ ទន្លេ ឬ អាងដោះទឹក (ចំពោះទឹកក្រោមដី មានស្រទាប់ផ្ទុកទឹក) គឺជាមូលដ្ឋាន ដែលទឹកមានចលនា នៅពេលដែលទឹកហូរចុះទៅសមុទ្រ ។ ប្រព័ន្ធដី (ដូចជា ជួរភ្នំ ទំនាបឆ្នេរ ។ល។) ប្រភេទដីដាំដុះ និងប្រភេទរុក្ខជាតិធម្មជាតិ ជាទូទៅត្រូវគ្រប់គ្រងតាមតំបន់អាកាសធាតុ កំពស់ធៀបទៅផ្ទៃសមុទ្រ និងលក្ខណៈភូគព្ភសាស្ត្រ (ប្រភេទដី ថ្ម និងល្បាប់) ។ ដូចនេះ ព្រំប្រទល់ដី ដីដាំដុះ និងរុក្ខជាតិ ជាទូទៅ ត្រូវកាត់ទន្លេ ហើយប្រព័ន្ធដោះទឹក ត្រូវបែងចែកក្នុងចន្លោះរវាងទន្លេ ក៏ដូចជាព្រំប្រទល់រដ្ឋបាលផងដែរ ។ មានតែប្រភេទរុក្ខជាតិ និងដីដាំដុះ ដែលនៅតាមទំនាបលិចទឹក តាមដងទន្លេប៉ុណ្ណោះ ដែលមានលក្ខណៈបែងចែងទៅតាមប្រព័ន្ធទន្លេ ។

អាងទន្លេ ត្រូវបានគេគិតថា ជាខ្នាតដែលល្អបំផុត ក្នុងការគ្រប់គ្រងទឹក ដែលជាផ្នែកមួយ នៃគោលគំនិតក្នុងការគ្រប់គ្រងធនធានទឹករួម (IWRM) ។ ទោះជាយ៉ាងនេះក៏ដោយ តាមបទពិសោធន៍ ជាលក្ខណៈអន្តរជាតិ បានបង្ហាញថា ការគ្រប់គ្រងអាងទន្លេដោយជោគជ័យ វាមានតំលៃថ្លៃ ដោយសារវាត្រូវការឱ្យមានការរៀបចំនូវរដ្ឋបាលបន្ថែមសំរាប់អាង មានការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព នៅក្នុងព្រំដែនអាង និងមានមូលដ្ឋានពតិមានរឹងមាំ ។ តាមរយៈនេះ ការគ្រប់គ្រងអាងទន្លេ ភាគច្រើនទទួលបានជោគជ័យ ហើយបានទទួលនូវទុនគ្រប់គ្រាន់ ។ ដូចនេះ នៅកន្លែងណាដែលមានហេដ្ឋារចនាសម្ព័ន្ធធំៗ និងមានតំលៃថ្លៃ ដូចជាប្រព័ន្ធទំនប់វារីអគ្គិសនី នៅកន្លែងដែលតំលៃសេដ្ឋកិច្ចសង្គម និងអេកូឡូស៊ីនៃទឹក និងធនធានដែលទាក់ទងនឹងទឹក មានតំលៃថ្លៃ នៅកន្លែងដែលមានការប្រជែងគ្នា ឬ មានជំលោះរវាងអ្នកដែលចង់ប្រើប្រាស់ ឬ កន្លែងដែលមានបញ្ហាជាលក្ខណៈអន្តរជាតិ ដូចជាការគ្រប់គ្រងនាវាចរ ឬ ការធ្វើឱ្យក្រខ្វក់ដែលនាំឱ្យមានមហន្តរាយនោះ មានន័យថា

ការគ្រប់គ្រង ត្រូវគិតដល់លំហូរធម្មជាតិនៃទឹកតាមប្រព័ន្ធទន្លេ ។ គោលគំនិតនៃវិធីសាស្ត្រគ្រប់គ្រងអាងទន្លេ (RBA) ក្នុងបរិបទនៃយុទ្ធសាស្ត្រកសិកម្ម និងទឹកមានដូចខាងក្រោមៈ

១-វិធីសាស្ត្រគ្រប់គ្រងអាងទន្លេ ក្នុងយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក គឺជាពិសេស សំរាប់ការកំណត់ជាដំបូង នូវធនធានទឹក និងដី ដើម្បីប្រមែប្រមូលនូវធនធានទាំងនោះ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ហើយដែលជួយដល់ផ្នែកសំខាន់ៗនៃយុទ្ធសាស្ត្រ និងជាប់ទាក់ទងជាពិសេស ចំពោះការអនុវត្តន៍យុទ្ធសាស្ត្រ ព្រោះថា បើគ្មានមធ្យោបាយ ក្នុងការប្រមែប្រមូលឱ្យបានល្អទេនោះ ការអនុវត្តន៍នូវយុទ្ធសាស្ត្រ នឹងមានភាពរអាក់រអួល ។

២-ការកំណត់នូវធនធានទាំងនេះ ប្រហែលជាអាចធ្វើឡើង ដោយចែកជាតំបន់អាងទន្លេ យ៉ាងហោចណាស់ ជាបួនតំបន់ ដូចជា (១)តំបន់ដែលសមស្របសំរាប់ការស្រោចស្រពទាំងស្រុង (២) តំបន់ដែលសមស្របសំរាប់ការស្រោចស្រពបន្ថែម (៣) តំបន់សំរាប់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀង ហើយដែលអាចប្រមូលទឹកភ្លៀង និង/ឬ ការគ្រប់គ្រងទឹកផ្សេងទៀត ឬ វិធានការថែរក្សាផ្សេងៗទៀត (៤)តំបន់សំរាប់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង (ប្រហែលជាអាចមាន និយមន័យសមរម្យជាងនេះផ្សេងទៀត សំរាប់តំបន់ទាំងនេះ ឧទាហរណ៍ ដូចជាក្នុងបរិបទនៃកិច្ចអន្តរាគមន៍ ក្នុងការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង ក្នុងកំរិតផ្សេងៗគ្នា (កំរិតមាក្រូ-មធ្យម-macro-intermediate) ។ ការបែងចែកតំន់ទាំងនេះ នឹងជួយជាពិសេស ក្នុងការធ្វើសមិទ្ធិសិក្សា និងការវិនិយោគ ក្នុងការគ្រប់គ្រងទឹក និងវិធានការប្រមែប្រមូលធនធាន របស់យុទ្ធសាស្ត្រនេះ ។ ប្រការនេះគឺវាផ្ទុយទៅនឹងវិធីសាស្ត្រ ដែលមានលក្ខណៈបណ្តោះអាសន្ន ដែលជាករណីមួយត្រូវអនុវត្តន៍ ក្នុងករណីដែលគ្មានវិធីសាស្ត្រគ្រប់គ្រងអាងទន្លេ (RBA) ។

៣-វាមិនមែនជាបំណងដែលចង់ ចាត់ចែងនូវធនធានទឹក ឱ្យមានលក្ខណទូលំទូលាយ រវាងបណ្តាអ្នកប្រើប្រាស់នោះទេ (ឧទាហរណ៍ ដូចជា ទឹកសំរាប់អ្នកប្រើប្រាស់ផ្នែកឧស្សាហកម្ម វារីអគ្គិសនី ។ល។) ប៉ុន្តែការគ្រប់គ្រងអាងទន្លេ ក្នុងផ្នែកកសិកម្ម និងទឹក អាចដាក់បញ្ចូលក្នុងវិធីសាស្ត្រដ៏ទូលំទូលាយនោះ ក្នុងអាងទន្លេ ដែលមានអាទិភាពមួយចំនួន ប្រសិនបើមានការឯកភាព ពីបណ្តាអ្នកពាក់ព័ន្ធទាំងអស់ (ឧទាហរណ៍ សំរាប់អាងទន្លេមេគង្គ និងទន្លេសាប) ។

៤-ផ្អែកតាមមូលដ្ឋាន នៃការបែងចែកតំបន់គ្រប់គ្រងទឹកនេះ វិធីសាស្ត្រគ្រប់គ្រងអាងទន្លេ នឹងរៀបចំនូវចំណាត់ថ្នាក់ដី និងដីដាំដំណាំ កត្តាចូលទៅទីផ្សារ និងបញ្ហាបរិស្ថាន ដែលអាចកើតមាន ទាក់ទងនឹងសកម្មភាពកសិកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំនេះ ត្រូវអនុវត្តន៍ទៅ ក្នុងលក្ខណមួយរស់រវើក និងមានការគិតគូរតាមលទ្ធភាពជាក់ស្តែង អាទិភាព និងភាពសំខាន់ ។ មិនចាំបាច់ថា ត្រូវអនុវត្តន៍នូវគោលគំនិតនេះទាំងមូល គ្រប់អាងទន្លេនោះទេ ប៉ុន្តែវានឹងអាស្រ័យទៅតាមភាពសំខាន់ និងអាទិភាពរបស់ជាតិ នៃអាងទន្លេនិមួយៗ ដែលថែមទាំងអាចខុសៗគ្នា តាមពេលវេលាទៀតផង ។

៥-វាពុំមែនជាការដែលចង់បង្កើតនូវ (យ៉ាងហោចណាស់ មិនមែនជារួម) អង្គភាពគ្រប់គ្រងអាងទន្លេមួយ ក្រោមយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹកនោះទេ (វាមិនមែនជាភារកិច្ចរបស់យើងទេ) ប៉ុន្តែនៅកន្លែងណាដែលមានអង្គភាពនេះរួចហើយនោះ វានឹងមានតួនាទីក្នុងការអនុវត្តន៍ ។ បើពុំនោះទេ ការគ្រប់គ្រងសាធារណៈ នៃកិច្ចអន្តរាគមន៍ ក្រោមយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក នឹងត្រូវជាការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ខេត្ត ស្រុក និងឃុំ ដែលមានស្រាប់ តាមការជាក់ស្តែង ។

ដូចនេះ វិធីសាស្ត្រគ្រប់គ្រងអាងទន្លេ ក្នុងវិស័យកសិកម្ម និងទឹក មានច្រើនប្រភេទ ឧទាហរណ៍ មានតាំងពីវិធីសាស្ត្រគ្រប់គ្រងទឹករួមដោយពេញលេញ (IWMA) នៅចុងម្ខាង រហូតដល់ការសាកល្បង ដែលមានលក្ខណៈ "គ្រាន់តែកំណត់ នៅចុងម្ខាងទៀត ហើយដែល វិធីសាស្ត្រគ្រប់គ្រងទឹករួមដោយពេញលេញ នឹងមានការអនុវត្តន៍ តែនៅក្នុងអាងទន្លេ ដែលមានអាទិភាពខ្ពស់ មួយចំនួនតូចប៉ុណ្ណោះ ។"

នៅក្នុងការណែនាំខាងលើ សមាសធាតុ នៃការគ្រប់គ្រងអាងទន្លេ អាចរួមមាន:

-ការគ្រប់គ្រងដែលមានស្រាប់ លើទឹកទន្លេមេគង្គ និងទឹកជំនន់ ស្របតាមកិច្ចព្រមព្រៀងទន្លេមេគង្គ

-ការគ្រប់គ្រងរួម នៃបឹងទន្លេសាប និងប្រព័ន្ធអេកូឡូស៊ី ជីវចំរុះ និងជលផលដែលទាក់ទង

-ការកំណត់នូវអាងទន្លេផ្សេងទៀត ដែលការគ្រប់គ្រងរបស់វា អាចត្រូវកែសំរួល ព្រោះថា ការប្រជែង គ្នាក្នុងការប្រើប្រាស់ ឬ មានហានិភ័យខ្ពស់ ចំពោះទឹក ធនធានក្នុងទឹក ឬជលផល និងតំលៃផ្សេងទៀត ដែលមានក្នុងទឹកនោះ វាអាចត្រូវខូចខាត ដោយសារការប្រើប្រាស់ទឹក ដោយគ្មានការគ្រប់គ្រងសំរាប់កសិកម្ម ឬ ដោយការធ្វើឱ្យក្រខ្វក់ ដោយសកម្មភាពកសិកម្ម

-ប្រមូលផ្តុំនូវពត៌មានដែលអាចទុកចិត្តបាន ស្តីពី ទឹកដែលមាន តំរូវការ និងការប្រើប្រាស់ ក្នុងប្រព័ន្ធទន្លេដើម្បីឱ្យអ្នកគ្រប់គ្រងធនធាន អាចគ្រប់គ្រងទឹក ក្នុងការចែកចាយដល់អ្នកប្រើប្រាស់ ក្នុងលក្ខណៈមួយ ដែលអ្នកប្រើប្រាស់ទាំងនោះ មិនធ្វើឱ្យមានការប៉ះពាល់អាក្រក់ ដល់គ្នាទៅវិញទៅមក ឬ លើធនធាននោះផ្ទាល់តែម្តង ។

-ប្រមូលផ្តុំនូវពត៌មានដែលអាចទុកចិត្តបាន ស្តីពី ដីដាំដំណាំ អាកាសធាតុក្នុងមូលដ្ឋាន ប្រព័ន្ធដី ប្រភេទរុក្ខជាតិ និងសមត្ថភាពដីដែលអាចប្រើប្រាស់ ដើម្បីឱ្យអ្នកគ្រប់គ្រង អាចកំណត់ថា នៅកន្លែងណា ដែលទឹក ដី និងដីដាំដំណាំ រួមគ្នា អាចផ្តល់នូវសក្តានុពលប្រសើរបំផុត សំរាប់ជាផលប្រយោជន៍ និងការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព នៃធនធានធម្មជាតិនោះ ។

## ៥.១.៧_ការបង្កើននូវផលិតភាពកសិកម្ម

ការបង្កើននូវផលិតភាពកសិកម្ម ដែលជាការទទួលបានមកវិញ ពីធនធានដែលបានប្រើ ដូចជា ពលកម្ម ដី ទឹក ។ល។ នោះ ត្រូវផ្តល់នូវប្រយោជន៍ដល់កសិករគ្រប់គ្នា ទោះជាពួកគេដាំដំណាំសំរាប់ការប្រើប្រាស់របស់គេផ្ទាល់

ឬ សំរាប់លក់ក៏ដោយ ។ បន្ថែមពីលើសកម្មភាពដែលបានលើកឡើងទាក់ទងទៅនឹងការប្រើប្រាស់ធនធានធម្មជាតិ និងចំណេះដឹង ពត៌មាន និងបច្ចេកវិទ្យានោះ កិច្ចអន្តរាគមន៍ ដែលទាក់ទង រួមមានៈ

-ធានាថា ធនធាន ដូចជា គ្រាប់ពូជ មានគុណភាពល្អ ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់

-គាំទ្រដល់ផលិតកម្មដំណាំដែលមានប្រសិទ្ធភាព និងតំលៃផលិតផលទាប ដោយជួយសំរួលដល់ការប្រើប្រាស់នូវបច្ចេកវិទ្យាល្អៗ (ដូចជា គ្រឿងចក្រកសិកម្ម) និងកាត់បន្ថយការបាត់បង់នៅពេល និងក្រោយពេលប្រមូលផល

-ជួយសំរួលដល់ការអនុវត្តន៍នូវវិធីសាស្រ្ត ក្នុងការធ្វើកសិកម្មថ្មីៗ ដូចជា ការគ្រប់គ្រងដំណាំចំរុះ (Integrated Crop Management) រួមមានទាំង ប្រពលវប្បកម្មដំណាំស្រូវ (System of Rice Intensification-SRI)

ផ្នែកផ្សេងៗនៃយុទ្ធសាស្រ្ត មានការទាក់ទងគ្នា ជាមួយនឹងផ្នែកខាងក្រោយៗទៀត ព្រោះថា យើងត្រូវកាត់បន្ថយតំលៃផលិតកម្ម ក្នុងមួយឯកតានៃផលិតផល និងធានានូវគុណភាពផលិតផល ។ ករណីនេះ វានឹងធ្វើឱ្យផលិតផលរបស់ប្រទេសកម្ពុជា កាន់តែមានលក្ខណប្រកួតប្រជែងថែមទៀត ទាំងក្នុងទីផ្សារក្នុងស្រុក និងអន្តរជាតិ ។

## ៥.១.៨.ការពង្រីកនូវកសិ-ពាណិជ្ជកម្ម និងកសិ-ធុរកិច្ច

ការធ្វើកសិ-ពាណិជ្ជកម្ម នឹងផ្តល់នូវមធ្យោបាយសំរាប់គ្រួសារ និងសហគមន៍នៅជនបទ ដែលភាគច្រើនក្នុងពេលបច្ចុប្បន្ន ប្រកបរបរជាលក្ខណសេដ្ឋកិច្ចមិនមែនជាសាច់ប្រាក់ (non-cash economy) ក្នុងការបង្កើតនូវចំណូលជាសាច់ប្រាក់ ដែលគេត្រូវការ ដើម្បីបង្កើនគុណភាពនៃការរស់នៅរបស់គេ ។ នៅកន្លែងណាដែលមានឱកាសក្នុងការធ្វើពាណិជ្ជកម្ម ឧទាហរណ៏ ដូចជានៅជិតទីរួមខេត្ត និងតំបន់ជិតព្រំដែន តំរូវការនៅទីផ្សារ (Denamd pull) វាបានទាក់ទាញកសិករដោយងាយ ឱ្យចូលទៅក្នុងផ្នែក កសិ-ធុរកិច្ច និងឃ្លាតឆ្ងាយពីផលិតកម្ម ដែលគ្រាន់តែសំរាប់ប្រើប្រាស់ខ្លួនឯង ។ ទោះជាយ៉ាងនេះក៏ដោយ មានកិច្ចអន្តរាគមន៍ជាច្រើន ដែលអាចជួយលើកទឹកចិត្តដល់កសិដ្ឋានដែលមានលក្ខណៈជាសហគ្រាសៈ

- ផ្តល់ពត៌មានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា និងការព្យាករណ៏អំពីតំរូវការនៅទីផ្សារ
- កំណត់ និងជំរុញឱ្យមានឱកាសសំរាប់ផលិតផលថ្មីៗ និងតំរូវការអ្នកប្រើប្រាស់
- បង្កើតឱ្យមានឧបករណ៏កែឆ្នៃ សំរាប់បន្ថែមតំលៃ
- រៀបចំឱ្យមានការធានាគុណភាពផលិតផល និងសុវត្ថិភាពស្បៀង

- ជួយសំរួលដល់ការចូលដល់ទីផ្សារ ដែលអាចចំណេញ ជាពិសេស តាមរយៈនៃការកែលំអឧបករណ៍ដឹកជញ្ជូន និងរក្សាទុក ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងការរៀបចំក្នុងការលក់ដុំ ។ល ។

## ៥.២_លំដាប់លំដោយនៃការអនុវត្តន៍

ផ្នែកទាំងប្រាំបីនៃយុទ្ធសាស្ត្រ ត្រូវបានរៀបចំ នៅផ្នែកខាងក្រោយ តាមលំដាប់នៃការអនុវត្តន៍ និង ភាពទាក់ទងគ្នាទៅវិញទៅមក ។ ជាការពិតណាស់ តាមការជាក់ស្តែង វាមានសកម្មភាពរួចទៅហើយ ក្នុងផ្នែកនិមួយៗ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តន៍រួចទៅហើយ នៅក្នុងឆ្នាំដំបូងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់ឆ្នាំ ២០០៦-២០១០ របស់គេនោះ ។ ដូចនេះ តាមការជាក់ស្តែងក្នុងពេលជាមួយគ្នានេះ ផ្នែកនៃយុទ្ធសាស្ត្រទាំងនេះ ត្រូវបានកំពុងអនុវត្តន៍ហើយ ហើយវានឹងមិនអាចអនុវត្តន៍ទៅបានទេ ក្នុងករណីដែលថា មិនត្រូវមានការវិនិយោគ ក្នុងការបង្កើននូវផលិតភាពកសិកម្មទេ (ផ្នែក ៥.១.៧) រហូតដល់ពេលណា មានការពង្រឹងសមត្ថភាពស្ថាប័ន (ក្នុងផ្នែក ៥.១.២) ត្រូវបានបំពេញហើយនោះ ។

ដូចនេះ ដំដាប់លំដោយនៃផ្នែកទាំងនោះ ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ ក្នុងករិតនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រើប្រាស់ធនធាន ។ នៅពេលចាប់ផ្តើមដំបូង គួរត្រូវប្រើប្រាស់ធនធានច្រើន សំរាប់ផ្នែកដែលមានលំដាប់ថ្នាក់ដើមគេ ព្រោះថា វាកំណត់នូវលក្ខខ័ណ្ឌ ដែលនឹងធានាដល់ការអនុវត្តន៍ ដោយជោគជ័យ នូវផ្នែកក្នុងលំដាប់ក្រោយៗទៀត ។ នៅពេលអនុវត្តន៍ជាបណ្តើរៗហើយនោះ ផលប្រយោជន៍នៃការវិនិយោគ ក្នុងផ្នែកនៅដំដាប់ដើមដំបូងៗ នឹងថយចុះជាប្រចាំ ។ ដូចនេះ ត្រូវបែងចែកធនធានឡើងវិញ ដោយប្រើច្រើន សំរាប់ផ្នែកដែលនៅលំដាប់ក្រោយៗវិញ ។

ដូចនេះ ជាមួយនឹងគុណសម្បត្តិនេះ យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ក្នុងផ្នែកទាំងនេះ អាចត្រូវបង្ហាញក្នុងទំរង់ជាដ្យាក្រាមដ៏សាមញ្ញមួយ ដែលផ្តោតការយកចិត្តទុកដាក់លើគោលដៅខ្ពស់បំផុតរបស់យើង គឺការកាត់បន្ថយ ភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច (រូបភាព ៥.១) ។




រូបភាព៥.១-យុទ្ធសាស្ត្រ: ដំណាក់កាលបួន ចេញពីលក្ខខ័ណ្ឌដើម ឆ្ពោះទៅគោលដៅ

ក្នុងដំណើរការអនុវត្តន៍ទាំងមូល មានបួនដំណាក់កាល ។ ដំណាក់កាលទីមួយ គឺលក្ខខ័ណ្ឌដើម ដែល រួមមាន ភាពខ្លាំង និងឱកាស ក្នុងវិស័យ ត្រូវបញ្ជាក់ និងធានាឱ្យមានជាប្រចាំ ។ ដូចដែលបានកត់សំគាល់ រួចមកហើយ អ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្ម និងទឹក មានឥទ្ធិពលមួយចំណែកប៉ុណ្ណោះ លើលក្ខខ័ណ្ឌដើម ដូចជាអភិបាលកិច្ច ល្អចាដើម ប៉ុន្តែក្នុងរយៈពេលឆ្នាំ ២០០៦-២០១០ លក្ខខ័ណ្ឌដើម ហាក់ដូចមានលក្ខណៈអំណោយផលល្អ សំរាប់ វិស័យនេះ ។ ដំណាក់កាលទីពីរ គឺត្រូវពង្រីកនូវបរិយាកាសល្អក្នុងវិស័យ ជាពិសេស តាមរយៈការកសាង

សមត្ថភាពស្ថាប័ន ដែលនឹងត្រូវដឹកនាំ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ ។ ដំណាក់កាលទីបី គឺត្រូវប្រមែប្រមូលនូវធនធានធម្មជាតិ និងមនុស្ស (រួមទាំងហិរញ្ញវត្ថុផង) និងផ្ទេរនូវសិទ្ធអំណាច ដល់សហគមន៍ ដែលចូលរួមក្នុងការអនុវត្តន៍ នៅកន្លែងដែលសមស្រប ក្នុងក្របខ័ណ្ឌដែលផ្តល់ដោយអាងទន្លេ ដែលជាខ្នាតជលសាស្ត្រជាមូលដ្ឋាន (Fundamental hydrological unit) នោះ ។ ដំណាក់កាលទីបួន ត្រូវមានវិធានការ ក្នុងការបង្កើននូវផលិតភាព និងផលិតកម្មកសិកម្ម និងពង្រីកនូវកសិ-ពាណិជ្ជកម្ម (កសិ-ធុរកិច្ច) ។ ផ្នែកទាំងអស់ នេះរួមគ្នា ផ្តល់នូវផលប្រយោជន៍ដល់ ទាំងគ្រួសារ និងសហគមន៍នៅជនបទ រួមទាំងអ្នកដែលផលិតច្រើនជាងអ្វីដែលគេត្រូវការសំរាប់ម្ហូបអាហារផ្ទាល់ខ្លួន និងស្វែងចំណូលជាសាច់ប្រាក់ ដើម្បីបង្កើនគុណភាពរស់នៅរបស់គេ និងអ្នកពាក់ព័ន្ធពេញលេញ ក្នុងកសិ-ពាណិជ្ជកម្ម និងក្នុងផ្នែកផ្សេងទៀតនៃប្រព័ន្ធតំលៃ ដូចជាការកែច្នៃ និងនាំចេញ ជាដើម ។

នៅគ្រប់ដំណាក់កាលទាំងអស់ យុទ្ធសាស្ត្រ មានគោលបំណង ក្នុងការបំបាត់នូវភាពខ្សោយរបស់វិស័យ និងការគំរាមកំហែងលើវិស័យនេះ (រូបភាព៥.១)។ គោលការណ៍ណែនាំ សំរាប់រួមចំណែក ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពនេះ ដោយតំរូវឱ្យកំណត់នូវឧបស័គ្គនានា ហើយថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ត្រូវកំណត់ច្បាស់លាស់នូវសកម្មភាព ដែលចាំបាច់ ក្នុងការលុបបំបាត់នូវឧបស័គ្គទាំងនោះ ។ គោលការណ៍ណែនាំនេះ ត្រូវបានអនុវត្តន៍តាម ក្នុងរយៈពេលរៀបចំបង្កើតយុទ្ធសាស្ត្រនេះ ។




រូបភាព ៩.២-រចនាសម្ព័ន្ធកម្មវិធីរបស់យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក

## ៥.៣_ការអនុវត្តន៍តាមកម្មវិធីនិមួយៗ

យុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តន៍ក្នុងកម្មវិធីចំនួនប្រាំ (រូបភាព៥.២) ដែលមានគោលបំណង ក្នុងការសំរេចបាននូវគោលដៅទាំងប្រាំដែលបានកំណត់ក្នុងចំណុច ៣.៣ ។ វាអាចបង្ហាញក្នុងលក្ខណជាទំរង់រចនាសម្ព័ន្ធក្នុងរូបភាព៥.១ ។ កម្មវិធីមួយ លើកឡើងពីបរិយាកាសល្អ កម្មវិធីពីរទៀត លើកឡើងពីរការប្រមែប្រមូលធនធាន និងការផ្ទេរសិទ្ធអំណាច របស់យុទ្ធសាស្ត្រ ហើយកម្មវិធីពីរទៀត លើកឡើងពីរផលិតភាព និងការធ្វើពាណិជ្ជកម្មភាវូបនីយកម្ម ក្នុងវិស័យកសិកម្ម ។ កម្មវិធីទាំងអស់នេះ រួមគ្នាដើម្បីសំរេចបាន នូវការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច តាមរយៈភ្នាក់ងារកសិកម្ម និងការគ្រប់គ្រងទឹក ។

## ៦_ ផ្នែកកម្មវិធី

គោលដៅចំបង និងគោលដៅអភិវឌ្ឍន៏សំរាប់វិស័យកសិកម្ម និងទឹកក្នុងរយៈពេលឆ្នាំ ២០០៦-២០១០ នឹងត្រូវសំរេចបានដោយផ្តោតការយកចិត្តទុកដាក់លើកម្មវិធីទាំងប្រាំ (រូបភាព ៥.២):

១-កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងសំរាប់វិស័យកសិម្ម និងធនធានទឹក

២-កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង

៣-កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ)

៤- កម្មវិធីធនធានទឹក ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងដី

៥-កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយកសិកម្ម និងធនធានទឹក

ដូចបានកត់សំគាល់ក្នុងចំណុច ៤.៣ កម្មវិធីទាំងប្រាំមានភាពសំខាន់ស្មើៗគ្នា ក្នុងការសំរេចបាននូវជោគជ័យក្នុងវិស័យកសិកម្ម និងធនធានទឹក ។ ធាតុពិត កម្មវិធីទាំងនេះ មានការគាំទ្រដល់គ្នាទៅវិញទៅមក ជាពិសេសកម្មវិធីទី ២ និងទី ៣ ដែលមានគោលដៅរួមគ្នា ក្នុងការបង្កើននូវផលិតកម្មកសិកម្ម សំរាប់ការប្រើប្រាស់តាមគ្រួសារ (គឺសំរេចបាននូវសន្តិសុខស្បៀង) និងសំរាប់លក់ (ដើម្បីបង្កើតចំណូល) ។ តាមរយៈនេះ កម្មវិធីទាំងពីរនេះ នឹងលើកឡើងនូវផ្នែកជាច្រើន ដែលទាក់ទងនឹងភាពក្រីក្រ ដែលមានលក្ខណជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ។

គោលគំនិតសំរាប់កម្មវិធីទាំងនេះ ត្រូវបានបង្កើតឡើងដោយក្រុមយុទ្ធសាស្ត្រ B1 ដោយផ្អែកតាមការវិភាគ លើស្ថានភាពដែលមានបង្ហាញក្នុងចំណុច ២ ដែលទស្សនៈវិស័យ និងគោលដៅ មានរៀបរាប់ក្នុងចំណុច ៤ ការវាយតំលៃរបស់ក្រុមនេះ (ចំណុច ៥) លើសមាសធាតុសំខាន់ៗ ដែលត្រូវដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹក ។ ជាចំណុចចាប់ផ្តើម ករណីទាំងអស់នេះ វាមាននៅក្នុងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់ការអភិវឌ្ឍន៏ជាតិ ក្នុងកំលុងពេលឆ្នាំ ២០០៦-២០១០ គឺការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច

ដែលត្រូវសំរេចបាន ជាពិសេស តាមរយៈកសិកម្ម ។ កម្មវិធីទីពីរ និងទីបី មានគោលបំណងផ្តល់នូវលទ្ធផលជាអាទិភាព នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ចំពោះកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ លទ្ធផលទាំងនេះ មានសារៈសំខាន់ណាស់ ដែលក្រុមយុទ្ធសាស្ត្របានចាត់ទុកវាជាប្រការសំខាន់ ដែលលទ្ធផលនិមួយៗ ត្រូវតែបានលើកឡើងក្នុងកម្មវិធី ។ កម្មវិធីទីបួន មានគោលបំណងក្នុងការប្រមែប្រមូលនូវទឹក និងដីដែលជាធនធានធម្មជាតិសំខាន់ពីរដែលមានសំរាប់កសិកម្មក្នុងប្រទេសកម្ពុជា ។ ការវិភាគលើ ភាពខ្លាំង ភាពខ្សោយ ឱកាស និង ការគំរាមកំហែងរបស់ក្រុមនេះបានបង្ហាញថា កត្តានេះ ជាប្រការសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍នាពេលអនាគត ក្នុងវិស័យនេះ ហើយដែលជាងនេះទៅទៀតនោះ យុទ្ធសាស្ត្រចតុកោណ របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានយកចិត្តទុកដាក់ ជាពិសេស លើបញ្ហាដែលមានក្នុងកម្មវិធីទី ៤ ។ ការវិភាគលើ ភាពខ្លាំង ភាពខ្សោយ ឱកាស និង ការគំរាមកំហែងរបស់ក្រុមនេះ ក៏បានបង្ហាញផងដែរ នូវការចាំបាច់ដ៏សំខាន់ ក្នុងការកសាងសមត្ថភាពស្ថាប័ន និងការគាំទ្រដល់ការគ្រប់គ្រង ហើយដែលជាការកែលំអជាមូលដ្ឋាន ក្នុងកម្មវិធីទី ១ ។ (ការកសាងសមត្ថភាពស្ថាបន័ ធ្វើឱ្យមានបរិយាកាសល្អ ដែលក្នុងន័យនេះហើយ ធ្វើឱ្យមានការបង្កើតឡើងនូវកម្មវិធីទី ១) ។ ទីបំផុត ការកែសំរួលសំរាប់កម្មវិធីទី ៥ នោះ គឺថា ការប្រើប្រាស់ជាយុទ្ធសាស្ត្រនូវចំណេះដឹងពតិមាន និងបច្ចេកវិទ្យាថ្មីៗវាជាការចាំបាច់សំរាប់កសិកម្មកម្ពុជា ក្នុងការចេញឱ្យផុតពីស្ថានភាពបច្ចុប្បន្ន ដែលមានបច្ចេកវិទ្យាទាប ផលិតភាពទាប និងមានហានិភ័យក្នុងការមិនបានទទួលផលខ្ពស់ ដែលជាផ្នែកមួយ នៃភាពខ្សោយនាពេលបច្ចុប្បន្ន និងជាឱកាស នាពេលអនាគត ។

សំរាប់កម្មវិធីនិមួយៗ ផ្នែកខាងក្រោយៗនេះ បង្ហាញនូវហេតុផល ដោយសង្ខេប និងកំណត់នូវគោលបំណង ។ គោលបំណងទាំងនោះ មានអាទិភាព និងភាពសំខាន់ស្មើៗគ្នា ។ សមាសធាតុដែលមានក្នុងកម្មវិធីនិមួយៗ គឺមានលក្ខណជាបណ្តោះអាសន្ន ហើយដែលត្រូវមានការពិចារណាលំអិតថែមទៀត ក្នុងពេលរៀបចំកម្មវិធីលំអិត និងក្នុងដំណាក់កាលក្រោយទៀត នៃកិច្ចដំណើរការ (ចំណុច ១.៣) ។ ធាតុពិត នៅពេលបច្ចុប្បន្នការរៀបរាប់ពីកម្មវិធី មានលក្ខណជាក់លាក់ និងផ្តល់នូវចំណុចចាប់ផ្តើម សំរាប់ការរៀបចំកម្មវិធី ។ ការរៀបចំកម្មវិធី គឺមានគោលបំណងប្រើប្រាស់នូវ ក្រុមបង្កើតគំរោងកម្មវិធីតូចៗ ដែលធ្វើការរួមគ្នា ក្រោមការណែនាំរបស់ក្រុមការងារយុទ្ធសាស្ត្រ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងធ្វើការងារក្នុងផ្នែកជាច្រើន ដែលមានក្នុងយុទ្ធសាស្ត្រសំរាប់កសិកម្ម និងទឹនេះ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់ឆ្នាំ ២០០៦-២០១០ របស់គេ ។ ដូចនេះ គឺអាចមានលទ្ធភាពបង្កើតនូវផ្នែកផ្សេងៗនៃកម្មវិធី ដែលត្រូវពិចារណាក្នុងពេលរៀបចំគំរោង ដែលជាមធ្យោបាយមួយ ក្នុងការរៀបចំនូវសកម្មភាព ដែលបានលើកឡើង ក្នុងរចនាសម្ព័ន្ធច្បាស់លាស់មួយ ។ នៅពេលបច្ចុប្បន្ន ផ្នែកនានាដែលបានលើកឡើង គ្រាន់តែជាការបង្ហាញប៉ុណ្ណោះ ហើយដែលមិនត្រូវបានរៀបតាមលំដាប់អាទិភាពអ្វីឡើយ ។

ក្នុងការរៀបចំកម្មវិធី វាជាប្រការចាំបាច់ ក្នុងការទទួលស្គាល់នូវភាពខ្លាំង នាពេលបច្ចុប្បន្ន និងផ្តោតការយកចិត្តទុកដាក់ លើការបំបាត់នូវភាពខ្សោយ ។ ការណែនាំរបស់ក្រសួងផែនការ ចំពោះការរួមចំណែក ក្នុងការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ បានតំរូវថា ឧបស័គ្គ ចំពោះការសំរេចបានតាមគោលបំណង ដែលទាក់ទងនឹងភាពខ្សោយ និងការគំរាមកំហែង ដែលបានពិចារណាក្នុងចំណុច ២.២ ត្រូវតែកំណត់ឱ្យបានច្បាស់ ។ ប្រការនេះនាំឱ្យមានការលើកឡើងនូវសកម្មភាព ដើម្បីបំបាត់នូវឧបស័គ្គទាំងនោះ ហើយដែលធ្វើឱ្យមានភាពងាយស្រួល ក្នុងការសំរេចបាននូវគោលបំណងនោះ ។ វាគឺឋិតក្នុងដំណាក់កាលជ្រើសរើសនូវសកម្មភាព និងអាទិភាព ដោយបែងចែកនូវធនធានទៅលើសកម្មភាពនិមួយៗ ដែលសមស្របតាមការរួមចំណែកដែលរំពឹងទុករបស់គេ ក្នុងការសំរេចបាន នូវគោលដៅអភិវឌ្ឍន៍ និងគោលបំណងរបស់កម្មវិធី ។ សកម្មភាពដែលបានលើកឡើង មានបង្ហាញក្នុងតារាងម៉ាទ្រិច ដែលបានប្រើសំរាប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (តារាង៦.១ ដល់ ៦.៤ ក្នុងអត្ថបទបន្ថែម ទី ៣) ។ តារាងនេះ ក៏បានបង្ហាញពីសូចនាករលើការអនុវត្តន៍ (សូមមើលចំណុច ១.២) និងការទទួលខុសត្រូវផងដែរ ។

យុទ្ធសាស្ត្រនេះ គឺមានលក្ខណពាក់ព័ន្ធវិស័យច្រើន ប៉ុន្តែក្នុងរយៈពេលចាប់ពីឥលូវនេះ រហូតដល់ចុងបញ្ចប់នៃកំលុងពេលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននេះ វានឹងត្រូវគ្រប់គ្រង ជាពិសេស ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ។ វាជាប្រការចាំបាច់ ក្នុងការធ្វើទំនាក់ទំនងជាមួយភ្នាក់ងារដ៏ទៃទៀត ដែលមានផលប្រយោជន៍ និងការទទួលខុសត្រូវ ទាក់ទងនឹងវិស័យកសិកម្ម និងទឹកនេះ ។ ករណីនេះ គឺរួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ល។ និងអង្គការនានា ដូចជា សកលវិទ្យាល័យភូមិន្ទកសិកម្ម ជាដើម ។

## ៦.១. កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាព និងការគ្រប់គ្រងសំរាប់វិស័យកសិកម្ម និងធនធានទឹក

### ៦.១.១. សន្និធានភាព

វិស័យកសិកម្ម និងទឹកមានលក្ខណប្រមូលផ្តុំចំពោះផែនការរបស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍ជាតិ និងមានការពាក់ព័ន្ធជាមួយក្រសួង និងភ្នាក់ងារជាច្រើន ថែមទាំងអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនទៀតផង ។ ទោះបីជាយុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹកនេះ ចង់មានលក្ខណទាក់ទងវិស័យច្រើនក៏ដោយ ការកសាងសមត្ថភាពស្ថាប័ន ត្រូវលើកឡើងពីតំរូវការរបស់ស្ថាប័ននិមួយៗ ដោយខានមិនបាន ។ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម គឺជាភ្នាក់ងារដឹកនាំក្នុងវិស័យនេះ ក្រសួងទាំងពីរនេះ ជាក្រសួងធំ ដែលមានបុគ្គលិកទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ ភារៈកិច្ចរបស់ក្រសួងទាំងពីរនេះ គ្របដណ្តប់លើ

កសិកម្ម និងការគ្រប់គ្រងទឹក សំរាប់គោលបំណងកសិកម្ម ហើយក្រសួងនេះ មានទាំងការទទួលខុសត្រូវ ក្នុងការអនុវត្តន៏ផ្ទាល់ និងក្នុងការជំរុញ ឬគាំទ្រ ។ ឧទាហរណ៏ ក្រសួងធនធានទឹក និងឧតុនិយម សាងសង់ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ប៉ុន្តែក៏ជួយផងដែរដល់កសិករ ក្នុងការគ្រប់គ្រងប្រព័ន្ធដោយខ្លួនឯងផ្ទាល់ ។

កម្មវិធីគាំទ្រនេះ ផ្តោតលើការកសាងសមត្ថភាពក្នុងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ដែលជាភ្នាក់ងារដឹកនាំ ក្នុងវិស័យកសិកម្ម និងទឹក ។ ទំហំនៃការទទួលខុសត្រូវរបស់ក្រសួងទាំងពីរនេះ បង្ហាញនូវកិច្ចខិតខំប្រឹងប្រែងដ៏ធំមួយ ។ គេបានបោះជំហានទៅមុខ គួឱ្យកត់សំគាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប៉ុន្តែគេត្រូវការមានការពង្រឹងជាប្រចាំ ក្នុងគ្រប់ទិដ្ឋភាពនៃសមត្ថភាពក្នុងស្ថាប័ន ។ តំរូវការជាចំបងគឺការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលគ្រប់គ្រាន់ ដូចជា ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ ។ល។ សំរាប់បុគ្គលិក ប៉ុន្តែប្រការទាំងនេះ វាត្រូវបានកំណត់ដោយគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយវាមិនឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទាំងនេះទេ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏របស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម បច្ចុប្បន្នសំរាប់ឆ្នាំ ២០០៦-២០១០ មានដាក់បញ្ចូលរួចហើយ នូវគោលបំណងទាក់ទងនឹងការពង្រឹងសមត្ថភាព ។ ក្រសួងទាំងពីរនេះ មានតំរូវការខុសៗគ្នា ដូចនេះ កម្មវិធីនេះ ដាក់បញ្ចូលគ្នា នូវផ្នែកដែលខុសគ្នានៃក្រសួងទាំងពីរនេះ ។ ទោះជាយ៉ាងនេះក្តី កម្មវិធីនេះ នឹងលើកឡើង នូវយុទ្ធសាស្ត្ររបស់ក្រសួងទាំងពីរ តាមការដែលអាចធ្វើទៅបាន ។

កម្មវិធី នឹងត្រូវអនុវត្តន៏ក្នុងពេលជាមួយគ្នា នឹងការអនុវត្តន៏នូវក្របខ័ណ្ឌជាយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា លើការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលកំពុងអនុវត្តន៏នោះ ។ វាពិតជាចាំបាច់ដោយខានមិនបាន ដែលត្រូវលើកឡើងនូវបញ្ហាដែលទាក់ទងទៅនឹងសមត្ថភាពស្ថាប័ន នៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ និងបណ្តាញដ៏សាំញ៉ាំ នៃការទំនាក់ទំនងគ្នាទៅវិញទៅមក នៅក្នុងកំរិតរដ្ឋបាលទាំងបួនកំរិតនេះ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាអង្គភាព ដែលមានការទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ជាមួយសហគមន៏កសិដ្ឋាន ហើយដែលតាមរយៈនេះ អាចមានឥទ្ធិពលខ្លាំង លើការអនុវត្តន៏នូវយុទ្ធសាស្ត្រនេះ ។

### ៦.១.២. គោលបំណង និងគោលដៅ

គោលបំណងរបស់កម្មវិធីនេះ គឺដើម្បីធានាថា ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម មានលទ្ធភាពផ្តល់នូវការគាំទ្រដ៏ទូលំទូលាយ សក្តិសិទ្ធ និងមានប្រសិទ្ធិភាពដល់កសិករ និងឧស្សាហកម្មកសិកម្ម ។ គោលដៅរបស់កម្មវិធី ដែលកំណត់សំរាប់ឆ្នាំ ២០០៦-២០១០ (ចំណុច ៤.៣) គឺ:

***ការរៀបចំដែល ដែលផ្តល់នូវមូលដ្ឋានគោលនយោបាយ ច្បាប់ ស្ថាប័ន និងរដ្ឋបាលល្អមួយ ដើម្បីអនុវត្តន៏ការងារឱ្យមានប្រសិទ្ធិភាព ក្នុងការអភិវឌ្ឍន៏ និងគ្រប់គ្រងកសិកម្ម និងធនធានទឹក ។***

កម្មវិធី បានលើកឡើងនូវរាល់ទិដ្ឋភាពនៃសមត្ថភាពស្ថាប័ន ដែលក្រសួងទាំងពីរត្រូវការ ក្នុងការគ្រប់គ្រងការងាររបស់គេ ប្រកបដោយភាពសក្តិសិទ្ធ និងមានប្រសិទ្ធិភាព ។ ទិដ្ឋភាពទាំងនេះ រួមមានទាំង គោលនយោបាយ ការធ្វើផែនការ ក្របខ័ណ្ឌច្បាប់-បទបញ្ញត្តិ និងការអនុវត្តន៍ បញ្ហាស្ថាប័ន ឬ អង្គភាព (រួមទាំងអង្គភាពដែលទាក់ទងនឹងការអនុវត្តន៍នូវវិមជ្ឈការ និងវិសហមជ្ឈការផង) ការប្រមែប្រមូលនូវធនធានមនុស្ស នីតិវិធីរដ្ឋបាល និងប្រព័ន្ធគ្រប់គ្រង (រួមទាំងការត្រួតពិនិត្យលើការអនុវត្តន៍ និងការគ្រប់គ្រងហិរញ្ញវត្ថុផង) ការគ្រប់គ្រងទិន្នន័យ និងពត៌មាន និងការទំនាក់ទំនងជាមួយភ្នាក់ងារ និងអ្នកពាក់ព័ន្ធដ៏ទៃទៀត ។ សមត្ថភាពស្ថាប័ន ទាក់ទងនឹងការសិក្សាស្រាវជ្រាវ ចំណេះដឹង ពត៌មាន និងការផ្ទេរនូវបច្ចេកវិទ្យា គឺត្រូវបានលើកឡើងដាច់ពីគ្នា ក្នុងកម្មវិធីទី ៥ ចំណែកឯសមត្ថភាពបច្ចេកទេស ដែលចាំបាច់ ក្នុងការផ្តល់នូវសេវាកម្ម ត្រូវបានលើកឡើងក្នុងកម្មវិធីទី ២ ដល់ទី ៤ ។

## ៦.១.៣ គោលបំណង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ (២០០៦-២០១០) ដែលរៀបចំឡើងដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម មានគោលបំណងមួយចំនួន ដែលផ្តល់នូវមូលដ្ឋាន ក្នុងការអនុវត្តន៍នូវកម្មវិធីនេះ ។ គោលបំណងខាងក្រោមនេះ ត្រូវបានសំយោគចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងពីរនេះ ប៉ុន្តែសកម្មភាពដែលចាំបាច់ ក្នុងការសំរេចបាន នូវគោលបំណងនិមួយៗ របស់ក្រសួងនិមួយៗ អាចមានភាពខុសគ្នាច្រើន ។

១-គោលនយោបាយ ផែនការ និងក្របខ័ណ្ឌនៃច្បាប់-បទបញ្ញត្ត ដែលក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម ដែលត្រូវការ ក្នុងការអនុវត្តន៍ នូវការទទួលខុសត្រូវរបស់គេ ត្រូវបានបង្កើតឡើង និងបានអនុវត្តន៍ជាប្រចាំ ។ ក្រសួងទាំងនេះ មានសមត្ថភាព ដែលចាំបាច់ ក្នុងការអនុវត្តន៍នូវគោលនយោបាយ និងផែនការ និងច្បាប់ និងបទបញ្ញត្ត ចំពោះផ្នែកដែលគេទទួលខុសត្រូវ ។

២-ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម មានមន្ត្រីដែលបានបណ្តុះបណ្តាលត្រឹមត្រូវ ឧបករណ៍ និងមធ្យោបាយគ្រប់គ្រាន់ និងសមត្ថភាពរបស់ស្ថាប័ន ក្នុងការធ្វើផែនការការងាររដ្ឋបាល និងគ្រប់គ្រងទូទៅ (គ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចសន្យា គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងពត៌មានការងារវិស្វកម្ម និងសាធារណៈការ គ្រប់គ្រងគំរោង ត្រួតពិនិត្យ និងវាយតំលៃ ។ល។) ដើម្បីឱ្យគេអាចអនុវត្តន៍នូវការទទួលខុសត្រូវរបស់គេ នៅថ្នាក់ជាតិ និងខេត្ត ។

៣-ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម កំពុងអនុវត្តន៍នូវផែនការ ដែលមានពេលវេលាកំណត់មួយ (Time-bound plan) ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

កម្ពុជា ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងផ្នែកដែលគេទទួលខុសត្រូវ និងក្នុងការសំរេចបាន នូវការទំនាក់ទំនងយ៉ាងជិតស្និទ្ធ ក្នុងការងាររបស់គេ ។

៤-ស្ត្រី និងបុរស មានឱកាសស្មើគ្នា នៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម ក្នុងការបំពាក់បំប៉ន និងចូលរួម ក្នុងគ្រប់ទិដ្ឋភាពនៃការងាររបស់ក្រសួងទាំងពីរនេះ ។

៥-ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម មាននីតិវិធី ដ៏មានប្រសិទ្ធិភាព ក្នុងការធ្វើទំនាក់ទំនងក្នុងស្ថាប័ន (នៅថ្នាក់ជាតិ និងខេត្ត) និងជាមួយភ្នាក់ងាររបស់រដ្ឋាភិបាលផ្សេងទៀត អង្គការក្រៅរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ខាងក្រៅ និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងវិស័យនេះ ។

### ៦.១.៤_ផ្នែកសំខាន់ៗនៃកម្មវិធី

ផ្នែកសំខាន់ៗនៃកម្មវិធី អាចរួមមាន (តាមឯកសារគោលគំនិតរបស់យុទ្ធសាស្ត្រ-Strategy Concept Note)៖

១-បង្កើនសមត្ថភាពស្ថាប័ន (រួមទាំងក្រុមបេសកកម្មជាអាទិភាព-Priority Mission Group)

២-បង្កើនប្រព័ន្ធទិន្នន័យ និងពតិមានស្តីពីកសិកម្ម និងធនធានទឹក

៣-ការបង្កើត និងអនុវត្តន៍ច្បាប់ស្តីពីកសិកម្ម និងធនធានទឹក

៤-ការបញ្ច្រាបយ៉េនឌ័រ និងសន្តិសុខស្បៀង

៥-ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (រួមមានក្របខ័ណ្ឌនៃការចំណាយ ក្នុងរយៈពេលមធ្យម)

៦-ក្របខ័ណ្ឌក្នុងការត្រួតពិនិត្យ និងវាយតំលៃ

### ៦.១.៥_មធ្យោបាយនៃការអនុវត្តន៍ និងការទទួលខុសត្រូវ

ត្រូវមានសកម្មភាពសំខាន់ៗ ដែលចាំបាច់ ក្នុងការអនុវត្តន៍នូវគោលបំណងទាំងប្រាំ ។ សកម្មភាពទាំងនោះ ត្រូវបានសំយោគចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម ដែលជាការរួមចំណែកក្នុងការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្នុងជំហានបន្ទាប់ នៃកិច្ចដំណើរការនេះ សកម្មភាពទាំងនេះ នឹងត្រូវបានពិនិត្យ និងកែសំរួលឡើងវិញ និងកំណត់លំអិតថែមទៀត ក្នុងឯកសាររៀបចំកម្មវិធី (លក្ខខ័ណ្ឌការងារ ក្នុងឧបសម្ព័ន្ធ ៣) ។ នៅពេលដែលក្របខ័ណ្ឌជាយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានបង្កើតឡើង និងអនុវត្តន៍ហើយនោះ មធ្យោបាយ និងការទទួលខុសត្រូវ ក្នុងការអនុវត្តន៍នូវយុទ្ធសាស្ត្រនេះ នៅថ្នាក់ខេត្ត ក៏នឹងត្រូវតែរៀបចំថែមទៀតដែរ ។

## ៦.២_កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង

### ៦.២.១_ សនិទានភាព

ប្រហែល ៣៤.៧% នៃប្រជាជនកម្ពុជា មានចំណូលឋិតនៅក្រោមបន្ទាត់ក្រីក្រ ហើយដែលមួយចំនួនធំទៀត មានចំណូលតែលើនេះបន្តិចតែប៉ុណ្ណោះ ។ ក្នុងឆ្នាំ ២០០៤ ប្រហែល ២០ % នៃប្រជាជន គឺឋិតនៅក្រោមបន្ទាត់ក្រីក្រ ដោយខ្វះខាតស្បៀង ។ ភាពក្រីក្រក្នុងប្រទេសកម្ពុជា គឺជាព្រឹត្តិការណ៍ដែលមានច្រើន នៅក្នុងតំបន់ជនបទ ។ ទាំងគ្រួសារដែលមានស្ត្រី និងបុរស ជាមេគ្រួសារ មានកំរិតក្រីក្រដូចគ្នា គឺមិនខុសគ្នាប៉ុន្មានទេ បើគិតពីស្ថានភាពគ្រួសារ និងជនជាតិនោះ ។ មានអសន្តិសុខស្បៀងនៅគ្រប់តំបន់ជនបទ នៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ទីប្រជុំមួយចំនួន ហើយអាហារូបត្ថម្ភ គឺមានការខ្វះខាតច្រើន ជាពិសេស គឺដោយសារទិន្នផលកសិកម្មទាប និងការដែលពឹងផ្អែកតែលើស្រូវ និងត្រី សំរាប់តែការហូបចុកក្នុងគ្រួសារនោះ ។

កម្មវិធីនេះរួមចំណែកដល់ការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេស គឺការផ្តោតការយកចិត្តទុកដាក់ដ៏សំខាន់របស់វា លើការកាត់បន្ថយភាពក្រីក្រ និងលុបបំបាត់នូវភាពខុសគ្នា និងកាត់បន្ថយនូវគំលាតរវាងតំបន់ និងរវាងអ្នកមាន និងអ្នកដែលមិនមាន (have and have nots) ។ កម្មវិធីនេះ ផ្តោតការយកចិត្តទុកដាក់ លើសន្តិសុខស្បៀង និងចំណូល និងការកាត់បន្ថយនូវភាពក្រីក្រ នៅតាមគ្រួសារ ក្នុងចំណោមប្រជាជនប្រមាណ ៨៥ % ដែលរស់នៅក្នុងតំបន់ជនបទ និងដែលពឹងផ្អែកលើកសិកម្ម និងធនធានធម្មជាតិ និងការងារផ្សេងៗទៀត ដែលទាក់ទង ។ កម្មវិធីនេះ នឹងរួមចំណែកដល់ការបង្កើននូវស្ថានភាពសង្គម និងបញ្ចេញនូវថាមពល សំរាប់ផលិត ដែលនឹងជួយដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាបន្ថែមទៀត ។

កម្មវិធីនេះ មានការគាំទ្រដល់កម្មវិធីកសិកម្ម និងកសិ-ធុរកិច្ច ដែលផ្តោតលើផលិតកម្មកសិកម្ម សំរាប់លក់ និងរកប្រាក់ចំណូល ។ ទិដ្ឋភាពផ្សេងទៀតនៃសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ដូចជា ការបង្កើននូវហេដ្ឋារចនាសម្ព័ន្ធធំៗ ក៏ត្រូវបានពិចារណាផងដែរ ក្នុងផ្នែកផ្សេងទៀតនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

### ៦.២.២_គោលបំណង និងគោលដៅ

កម្មវិធីនេះមានគោលបំណងរួមចំណែកយ៉ាងសំខាន់ដល់ការការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវតទី១ របស់ប្រទេសកម្ពុជា គឺការបំបាត់នូវភាពក្រីក្រ និងអត់ឃ្លានខ្លាំង និងគោលដៅរបស់វា ដែលខុសគ្នារវាង ឆ្នាំ ១៩៩៣ និង ២០១៥ គឺចំនួនប្រជាជនដែលការប្រើប្រាស់របស់គេទាបជាងខ្សែបន្ទាត់ក្រីក្រជាតិនោះ ។ កម្មវិធីនេះនឹងមានផលប៉ះពាល់ជាវិជ្ជមាន លើគោលដៅអភិវឌ្ឍន៍សហសវត្ស ចំនួនប្រាំទៀត តាមរយៈការជួយកាត់បន្ថយនូវការស្លាប់របស់កុមារ និងបង្កើនសុខភាពមាតា (តាមរយៈការរួមចំណែករបស់វា ក្នុងការបង្កើននូវ ការទទួទានអាហារ អនាម័យ និងការគ្រប់គ្រងទឹក ការអប់រំស្តីពីអាហារូបត្ថម្ភ និងសុខភាព) បង្កើនស្ថេរភាពបរិស្ថាន តាម

រយៈការបង្កើននូវចំណេះដឹង លើការគ្រប់គ្រងកសិកម្ម និងធនធានធម្មជាតិ និងផ្តល់សិទ្ធអំណាចដល់ស្ត្រី ជាពិសេសក្នុងសហគមន៍ដែលក្រីក្រ ។

កម្មវិធីនេះ ក៏មានបំណងផងដែរ ក្នុងការសំរេចបាននូវ គោលដៅសន្តិសុខស្បៀង ដែលលើកឡើងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺដើម្បីធានាថា នៅឆ្នាំ ២០១០ ប្រជាជនកម្ពុជាដែលក្រីក្រ និងមានអសន្តិសុខស្បៀងនោះ អាចមានស្បៀងអាហារគ្រប់គ្រាន់ និងមានសុវត្ថិភាពគ្រប់ពេល ដើម្បីឆ្លើយតបតាមតំរូវការអាហារ និងអាហារដែលចូលចិត្តរបស់គេ ដើម្បីឱ្យគេមានការរស់នៅ ប្រកបដោយលក្ខណៈសកម្ម និងមានសុខភាពល្អ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានលើកឡើងថា ការសំរេចបាននូវគោលដៅនេះ គឺត្រូវការឱ្យមានកិច្ចខិតខំប្រឹងប្រែង រវាងបណ្តាវិស័យផ្សេងៗ ហើយដែលផ្តោតការយកចិត្តទុកដាក់លើៈ

- បង្កើន និងធានាឱ្យមានស្បៀងអាហារ

-បង្កើននូវលទ្ធភាពរកស្បៀងអាហារ ( រួមមានចំណូល និងលទ្ធភាពដែលអាចរកបាន)

-ធានាដល់ការប្រើប្រាស់ស្បៀងដោយមានប្រសិទ្ធិភាព និងការប្រើប្រាស់ស្របតាមការអប់រំសុខភាព និងអាហារូបត្ថម្ភ ។

ទិដ្ឋភាពសំខាន់ក្នុងការសំរេចបាននូវសន្តិសុខស្បៀង គឺការផ្ទេរសិទ្ធអំណាចដល់គ្រួសារ ដែលមានហានិភ័យខ្ពស់ ក្នុងការការពារខ្លួនឯង ទប់ទល់នឹងគ្រោះមហន្តរាយ ។ ឧទាហរណ៍ សហគមន៍ដែលមានហានិភ័យ អាចបង្កើត និងរក្សានូវធនាគារស្រូវ និងប្រភេទនៃមធ្យោបាយសុវត្ថិភាពផ្សេងៗទៀត ។ វាក៏ជាប្រការចាំបាច់ដែរ ក្នុងការធានាថា គ្រួសារដែលមានហានិភ័យ មានការជួយឧបត្ថម្ភពីរដ្ឋាភិបាល និងប្រភពផ្សេងៗទៀត ទាំងការដោះស្រាយចំពោះគ្រោះមហន្តរាយ និងបង្កើនសមត្ថភាព សំរាប់រយៈពេលវែងរបស់គេ ក្នុងការបង្កើននូវផលិតផលកសិកម្ម ។ បណ្តុះបណ្តាល និងធ្វើឱ្យប្រជាជនអាច ធ្វើការទំនាក់ទំនងជាមួយអ្នកតំណាងដែលបានជ្រើសរើស និងភ្នាក់ងាររដ្ឋាភិបាល តាំងពីថ្នាក់ក្រុមប្រឹក្សាឃុំសង្កាត់ឡើងទៅនោះ នឹងជួយឱ្យគេអាចទទួលបាននូវជំនួយ និងការផ្តល់នូវយោបល់នានា ។ ក្នុងរយៈពេលវែង ករណីនេះ នឹងជួយឱ្យគេអាចប្រើប្រាស់នូវធនធានរបស់គេ ក្នុងការសំរេចបាននូវសន្តិសុខស្បៀង ។

គោលដៅអភិវឌ្ឍន៍របស់កម្មវិធី ដែលបានកំណត់សំរាប់ឆ្នាំ ២០០៦-២០១០ ( ចំណុច ៤.៤) គឺៈ

ប្រព័ន្ធកសិកម្ម និងការរៀបចំសហគមន៍ ដែលធ្វើឱ្យប្រជាជនកម្ពុជា ដែលក្រីក្រ និងមានអសន្តិសុខស្បៀងនោះ អាចមានស្បៀងអាហារគ្រប់គ្រាន់ និងមានសុវត្ថិភាពគ្រប់ពេល ដើម្បីឆ្លើយតបតាមតំរូវការអាហារ និងអាហារដែលចូលចិត្តរបស់គេ ដើម្បីឱ្យគេមានការរស់នៅ ប្រកបដោយលក្ខណៈសកម្ម និងមានសុខភាពល្អ ។

### ៦.២.៣. គោលបំណង

ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍របស់កម្មវិធី គោលបំណងបួនត្រូវបានកំណត់ៈ

១-ប្រព័ន្ធកសិកម្មដែលមានទិន្នផលខ្ពស់ និងមានពិពិធកម្មដែលកើនឡើងជាប្រចាំ ដែលមានលទ្ធភាពធានាដល់សន្តិសុខស្បៀងសំរាប់ជាតិ និងផ្តល់នូវគុណភាពនៃការរស់នៅ ដែលអាចទទួលយកបាន ដល់សហគមន៍ជនបទ ជាពិសេស អ្នកក្រ ។

២-ការផលិតស្បៀង ដែលមានលក្ខណៈទំនើប និងមានពិពិធកម្ម ដោយគ្រួសារដែលមានដីកសិដ្ឋានតូច ជាពិសេស អ្នកដែលមានអសន្តិសុខស្បៀង អាស្រ័យដោយដីសំរាប់ដំណាំ និងសំរាប់ចំណីសត្វរបស់គេ និងការប្រើប្រាស់នូវធនធានដែលជាកម្មសិទ្ធរួមនៃដី ជលផល និងព្រៃឈើ

៣-ក្រុមសហគមន៍ ជាពិសេស គ្រួសារដែលមានអសន្តិសុខស្បៀង និងស្ត្រី ដែលត្រូវបានផ្តល់សិទ្ធអំណាចឱ្យ ក្នុងការទទួលបាននូវផលប្រយោជន៍ពេញលេញ ពីកម្មវិធីជំនួយរបស់រដ្ឋាភិបាល ផ្តល់នូវមធ្យោបាយសុវត្ថិភាពសន្តិសុខស្បៀងរបស់គេផ្ទាល់ ដូចជាធនាគារស្រូវ និងបង្ហាញនូវផលប្រយោជន៍របស់គេផ្ទាល់ ក្នុងបរិយាកាសនយោបាយ និងរដ្ឋបាល ។

៤-គោលនយោបាយ និងពតិមានស្តីពីទិដ្ឋភាពសន្តិសុខស្បៀងទាក់ទងនឹងការគ្រប់គ្រងកសិកម្ម និងទឹក ដែលណែនាំ ប្រកបដោយប្រសិទ្ធភាព ដល់រដ្ឋបាលសាធារណៈ នៅគ្រប់កំរិត ។

## ៦.២.៤ ផ្នែកសំខាន់ៗនៃកម្មវិធី

ផ្នែកសំខាន់ៗនៃកម្មវិធីអាចរួមមាន:

១-ការផលិតស្បៀងអាហារ សំរាប់គ្រួសារ ( ប្រព័ន្ធតំលៃនៅកំរិតគ្រួសារ) ។

២-ការទទួលបាននូវស្បៀងអាហារ (ចំណូល ការឧបត្ថម្ភ ទីផ្សារ សហគ្រាសធនតូច និងមធ្យម គំរោងតូចៗ.........) ។

៣-ការប្រើប្រាស់អាហារ និងការប្រើប្រាស់ : អាហារូបត្ថម្ភ ចំណេះដឹង និងការអប់រំអនាម័យ និងបញ្ហាអេដស៍ ។

៤-ការផ្ទេរសិទ្ធអំណាចដល់សហគមន៍មូលដ្ឋាន រួមទាំងមធ្យោបាយសុវត្ថិភាពសង្គម ក្រុមជួយខ្លួនឯង ក្រុមសន្សំប្រាក់ ក្រុមស្ត្រី (យ៉ែនឌ័រ) អង្គការកសិករ .... ។ល។

៥-ការគាំទ្រដល់ទេសចរណ៍ ដែលជួយដល់អ្នកក្រ ចំពោះសន្តិសុខស្បៀង ។

## ៦.២.៥ មធ្យោបាយក្នុងការអនុវត្តន៍ និងការទទួលខុសត្រូវ

ចាំបាច់ត្រូវមានសកម្មភាពសំខាន់ៗ ក្នុងការអនុវត្តន៍នូវគោលបំណង ។ សកម្មភាពនេះ ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការដាក់បញ្ចូល ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងតាមឯកសារជាច្រើន ដែលព្រាងដោយក្រុមយុទ្ធសាស្ត្រ នៃក្រុមការងារច្នេកទេស

សំរាប់វិស័យកសិកម្ម និងទឹក ។ ក្នុងជំហានបន្ទាប់ នៃកិច្ចដំណើរការនេះ សកម្មភាពទាំងនេះ នឹងត្រូវបានពិនិត្យ និងកែសំរួល និងកំណត់លំអិតថែមទៀត ក្នុងឯកសាររៀបចំកម្មវិធី ( លក្ខខ័ណ្ឌការងារ ក្នុងឧបសម្ព័ន្ធ ៣) ។

## ៦.៣.កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ)

### ៦.៣.១.សន្និទានភាព

កសិកម្ម គឺជាប្រភពស្បៀងអាហារសំខាន់ សំរាប់ប្រជាជនកម្ពុជា ដែលមាន ៨៥% រស់នៅក្នុងតំបន់ជនបទ ។ ដំណាំ និងការចិញ្ចឹមសត្វ គឺជាការរួមចំណែកដ៏សំខាន់មួយដល់សេដ្ឋកិច្ច ដែលមានចំណែកជិត ២០ % នៃផលិតផលជាតិសរុប ក្នុងឆ្នាំ ២០០៥ និងហើយការនេសាទត្រីក្នុងវាលស្រែ និងវារីវប្បកម្ម មានចំណែកបន្ថែម ៣-៤% ។ ផលិតផលមួយភាគធំ ត្រូវបានប្រើប្រាស់ដោយគ្រួសារកសិករខ្លួនឯងផ្ទាល់ ដែលការធានាបាននូវសន្តិសុខស្បៀង គឺវាពិតជាមានលក្ខណសំខាន់ណាស់ ចំពោះករណីទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ ផលិតផលដែលលើសសេចក្តីត្រូវការប្រើប្រាស់ ជាពិសេស នៅពេលដែលមានការកែច្នៃហើយ (value is added) នោះនឹងផ្តល់នូវចំណូល ជាសាច់ប្រាក់ សំរាប់ចំណាយក្នុងការសិក្សា ថៃទាំសុខភាព និងតំរូវការផ្សេងៗទៀត ។ ភាពក្រីក្រ គឺមានច្រើន ចំពោះប្រជាជនក្រីក្រនៅជនបទ និងនៅទីក្រុង ដែលបានចាកចោលទីជនបទមករកការងារធ្វើ ។ ដូចនេះការបង្កើននូវផលិតភាពកសិកម្ម និងផលិតផលដែលកែច្នៃហើយ (Value-added production) ផ្តល់នូវធមធ្យោបាយ ដ៏មានប្រសិទ្ធភាព និងមានល្បឿនលឿន ក្នុងការកាត់បន្ថយនូវភាពក្រីក្រ និងបង្កើននូវគុណភាពនៃការរស់នៅ ក្នុងជនបទ ។

ចំណែករបស់កសិកម្ម (ដំណាំ និងការចិញ្ចឹមសត្វ) ក្នុងផលិតផលក្នុងស្រុកសរុប (GDP) បានថយចុះនៅពេលដែលចំណែក ក្នុងឧស្សាហកម្មផ្សេងៗទៀតបានកើនឡើង ។ ទោះជាយ៉ាងនេះក្តី នៅមានឱកាសល្អជាច្រើនក្នុងការពង្រីកនូវកសិកម្ម ជាពិសេស ដោយការអភិវឌ្ឍន៍នូវកសិដ្ឋានដែលមានលក្ខណៈឧស្សាហកម្ម គឺ កសិ-ធុរកិច្ច ដើម្បីផ្តល់នូវផលិតផលសំរាប់លក់ ទាំងនៅទីផ្សារក្នុងស្រុក និង អន្តរជាតិ ។ ឧទាហរណ៍ ៧០% នៃការប្រើប្រាស់ផ្លែឈើ និង បន្លែរបស់ប្រទេសកម្ពុជា គឺត្រូវបាននាំចូល មកពីក្រៅបសទស ដែលករណីនេះ វាផ្តល់នូវឱកាសមួយក្នុងការបង្កើននូវផលិតផល ដើម្បីជំនួសការនាំចូលនេះ ។ម្យ៉ាងវិញទៀត កសិករនៅតំបន់ជិតព្រំដែន ដែលមានអំណោយផលល្អ ក្នុងការដឹកជញ្ជូន ដែលមានតំលៃថោក មានលទ្ធភាពលក់នូវផលិតផលរបស់គេ ក្នុងប្រទេសជិតខាង និងទទួលបាននូវផលចំណេញល្អ ។ ដើម្បីទាញយកឱកាស ក្នុងការបង្កើនផលិតផលជំនួសការនាំចូល និងនាំចេញនោះ ចាំបាច់ត្រូវមានការអភិវឌ្ឍន៍ ដ៏មានប្រសិទ្ធិភាព នូវទីផ្សារ និងការទំនាក់ទំនងរវាងកសិករ ឬអ្នកផលិត អ្នកលក់ដុំ និងអ្នកប្រើប្រាស់ ។ ត្រូវការធានាបាននូវគុណភាពផលិតផល និងស្ថេរភាពនៃការផ្គត់ផ្គង់ដើម្បីគាំទ្រដល់ករណីនេះ ក៏ដូចជាការធ្វើពិពិធកម្មដំណាំផ្សេងៗ (ឧ. ពូជស្រូវដែលគេចូលចិត្ត ឬ ដំណាំដែលអាច

បញ្ជាក់ថា ដាំដោយប្រើជីធម្មជាតិ) ដែលសមស្របតាមតំរូវការ ដែលមានការផ្លាស់ប្តូរយ៉ាងលឿនរបស់អ្នកប្រើប្រាស់ ។

ផលិតកម្មដែលកើនឡើង និងពិពិធកម្មកសិកម្ម និង ផ្តល់នូវមូលដ្ឋានមួយ សំរាប់ការកែច្នៃផលិតផលនៅកន្លែងដែលត្រូវប្រើប្រាស់នូវផលិតផលនោះ (downstream value-added processing) ។ មានឱកាសជាច្រើនទៀត ក្នុងការបង្កើតឱ្យមានប្រាក់ចំណេញនៅកន្លែងផ្សេងទៀត ក្នុងប្រព័ន្ធតំលៃកសិធុរកិច្ច ។ ឧទាហរណ៍សេវាកម្មនៅកន្លែងបង្កបង្កើនផល (upstream services) (ដូចជាការផ្គត់ផ្គង់គ្រាប់ពូជ ផលិតនូវគ្រឿងចក្រ) គឺត្រូវការចាំបាច់ នៅពេលដែលមធ្យោបាយនៅទីផ្សារលក់ផលិតផល ដូចជាការដឹកជញ្ជូនជាដើមត្រូវតែមានការកែលំអនោះ ។ ដូចនេះ វាមានឱកាសច្រើនសំរាប់ផ្នែកឯកជន និងកសិករ ដែលធ្វើការជាសមូហភាព ក្នុងការបង្កើននូវតំលៃទៅផលិតផលកសិកម្ម ។

ឱកាសទាំងអស់នេះ បង្កើតនូវការងារទាំងនៅកសិដ្ឋាន និងក្រៅកសិដ្ឋាន និងផ្តល់នូវប្រភពប្រាក់ចំណូលដល់កម្មករ និងគ្រួសារ ដែលមានសកម្មភាពក្នុងគ្រប់ដំណាក់កាលនៃប្រព័ន្ធតំលៃ ។ ដើម្បីទាញយកប្រយោជន៍ពីឱកាសទាំងនេះ វាជាការពិត ដែលតំរូវឱ្យមាននូវធនធានហិរញ្ញវត្ថុ ដែលជាយន្តការ ក្នុងការផ្តល់នូវទុនវិនិយោគ ។ ដូចជាឥណទានជនបទ ជាដើម ។ល។ នឹងត្រូវការជាចាំបាច់ ។

ជាទូទៅ ប្រព័ន្ធតំលៃកសិកម្មដែលរឹងមាំ អាចជាកំលាំងចលករដ៏សំខាន់ សំរាប់កាលូតលាស់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ សារៈសំខាន់របស់កសិកម្ម គឺត្រូវបានទទួលស្គាល់ដោយអាទិភាព ដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ យុទ្ធសាស្ត្រនេះមានលក្ខណៈជាតិទាំងមូល ប៉ុន្តែឱកាសទីផ្សារ វាខុស១គ្នា ពីតំបន់មួយទៅតំបន់មួយអាស្រ័យទៅតាមចំងាយផ្សេង១គ្នាទៅទីផ្សារ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។ល។ ក៏ដូចជាភាពខុសគ្នានៃដីដាំដុះ ទឹកដែលមាន អាកាសធាតុ ។ល។ យុទ្ធសាស្ត្រនេះ ត្រូវជៀសវាង កុំឱ្យមានលក្ខណៈល្អសំរាប់តែតំបន់ណាមួយ ជាងតំបន់មួយទៀតនោះ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ត្រូវតែកំណត់ និងផ្តល់អាទិភាពទៅតំបន់ដែលការបណ្តាក់ទុនក្នុងផ្នែកកសិ-ធុរកិច្ច អាចផ្តល់នូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចសង្គមខ្ពស់បំផុត និងបង្កើតនូវមធ្យោបាយ ដែលមានលក្ខណៈស្មើភាព ដើម្បីជំរុញដល់ការបណ្តាក់ទុនក្នុងតំបន់ទាំងនោះ ។

កម្មវិធីនេះ ជួយដល់កម្មវិធីគាំទ្រសន្តិសុខស្បៀង ដែលផ្តោតលើការផលិតនូវស្បៀងអាហារ សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ ។

### ៦.៣.២. គោលបំណង និង គោលដៅ

គោលបំណងសំខាន់នៃកម្មវិធីនេះ គឺដើម្បីបង្កើនចំណូល បង្កើត និងពង្រីកទីផ្សារ សំរាប់ផលិតផលកសិកម្ម និងដើម្បីធានានូវសន្តិសុខស្បៀង សំរាប់ប្រជាជនកម្ពុជាក្រីក្រ ។ គោលការណ៍ចំបង ក្នុងកម្មវិធីនេះ គឺត្រូវបង្កើនផលិតភាពកសិកម្ម និងផលិតផល និងបង្កើនកសិ-ធុរកិច្ច ។ ករណីទាំងនេះ គឺត្រូវការចាំបាច់នូវសកម្មភាព ដែលមានលក្ខណៈល្អ សំរាប់ជាសាធារណៈ ជាពិសេស ក្នុងការផ្តល់នូវសិទ្ធិអំណាចដល់សហគមន៍ជនបទ ក្នុងការគ្រប់គ្រង

លើស្ថានភាពរបស់គេផ្ទាល់ ។ ទោះជាយ៉ាងនេះក្តី គោលបំណងចំបង គឺធ្វើយ៉ាងណាដើម្បីឱ្យផ្នែកឯកជន បាន ចូលរួមក្នុងគ្រប់ដំណាក់កាល នៃប្រព័ន្ធតំលៃកសិកម្ម ដោយបំបាត់នូវឧបស័គ្គនានា និងបង្កើននូវការលើកទឹកចិត្ត ដើម្បីឱ្យសហគ្រិននានាផ្តល់នូវទំនិញ និងសេវាកម្មដ៏ទូលំទូលាយ ។ ការធានាដល់ការចូលទៅទីផ្សារអន្តរជាតិ និង ទីផ្សារតំបន់ ចំពោះផលិតផលកសិកម្ម គឺជាកត្តាចាំបាច់បំផុត ព្រោះថា វានឹងធានាដល់ការទទួលបាន នូវប្រភពទុន វិនិយោគ ។

គោលបំណងអភិវឌ្ឍន៍របស់កម្មវិធីសំរាប់ឆ្នាំ ២០០៦-២០១០ (ចំណុច ៤.៣) គឺ:

***កសិកម្ម និងកសិ-ធុរកិច្ច ដែលប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព និងឱកាសទីផ្សារមានការ ជឿនលឿន និងមានពិពិធកម្មផលិតកម្ម និងផ្តល់នូវផលប្រយោជន៍ពេញលេញ ដល់កសិករ សហគមន៍ជនបទ និង អ្នកពាក់ព័ន្ធផ្សេងៗទៀត ។***

### ៦.៣.៣. គោលបំណង

ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍របស់កម្មវិធី គោលបំណងចំនួនបួន ត្រូវបានកំណត់ :

១- ការផ្តល់នូវធនធាន និងសេវាកម្មរួម ទាំងសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មគ្រប់គ្រងទឹក ដែលផ្តល់ នូវផលិតផលកសិកម្ម ដែលមានផលចំណេញច្រើន មាននិរន្តរភាពបរិស្ថានល្អ និង មានប្រសិទ្ធិភាព តំលៃ ។

២- អនុវត្តន៍នូវបច្ចេកទេសល្អបំផុត ក្នុងការដាំដំណាំ ចិញ្ចឹមសត្វ វារីវប្បកម្ម និងការគ្រប់គ្រងទឹក សំរាប់ដំណាំ ដែលមានលក្ខណៈប្រសិទ្ធិភាពតំលៃ ធានានូវគុណភាព និងសុវត្ថិភាពផលិតផល និងធានាដល់សមត្ថភាពផលិត និងគុណភាពដី និងធនធានទឹក ។

៣- មធ្យោបាយក្នុងការគ្រប់គ្រងផលិតផល ការកែច្នៃក្រោយពេលប្រមូលផល និងការរកទីផ្សារ ឱកាស ក្នុងការលក់ផលិតផល និងការងារក្រៅកសិដ្ឋានផ្សេងៗទៀត សំរាប់កសិករ និងសហគមន៍ជនបទ និង ឱកាសក្នុងការធ្វើកសិ-ធុរកិច្ច សំរាប់ផ្នែកឯកជន និងអង្គការកសិករនានា ។

៤- ការអនុវត្តន៍ក្នុងការត្រួតពិនិត្យគុណភាព និងធានាគុណភាពផលិតផលកសិកម្ម ដែលធានាថា គុណភាព និងសុវត្ថិភាពរបស់ផលិតផល សមស្របតាមតំរូវការរបស់ទីផ្សារ ។

### ៦.៣.៤. ផ្នែកសំខាន់ៗ

ផ្នែកសំខាន់ៗរបស់កម្មវិធី អាចរួមមាន (តាមឯកសារគោលគំនិតយុទ្ធសាស្ត្រ (Strategy Concept Note) :

១- កម្មវិធីផ្គត់ផ្គង់ធនធាន (រួមមានប្រព័ន្ធឥណទាន គ្រាប់ពូជ ជី គ្រឿងចក្រកសិកម្ម។ល។) មានគោលដៅក្នុងការគាំទ្រដល់កសិ-ធុរកិច្ច ក្នុងផ្នែកទាំងនេះ និងផ្តោតលើការប្រមែប្រមូលផ្នែកឯកជនដើម្បីឱ្យផ្តល់នូវសេវាកម្ម ។

២- កម្មវិធីផលិតកម្មនៅកសិដ្ឋាន (រួមមាន ដំណាំ ចំការកៅស៊ូខ្នាតតូច ការចិញ្ចឹមសត្វ ការគ្រប់គ្រងទឹកសំរាប់ដំណាំ និងកម្មវិធីវារីវប្បកម្ម ដែលមានគោលបំណងក្នុងការគាំទ្រដល់កសិ-ធុរកិច្ច ក្នុងផ្នែកទាំងនេះ ។

៣- ការកែច្នៃ និងរកទីផ្សារ (រួមមានការកែច្នៃផលិតផលកសិកម្ម កម្មវិធីក្រោយពេលប្រមូលផល និងកសិ-ធុរកិច្ច) ដែលមានគោលបំណង គាំទ្រដល់កសិ-ធុរកិច្ច ក្នុងផ្នែកទាំងនេះ ។

៤- បង្កើតទីផ្សារសំរាប់អ្នកផលិត និងអ្នកប្រើប្រាស់ (រួមទាំងសុវត្ថិភាពស្បៀង ការត្រួតពិនិត្យគុណភាព និងធានាគុណភាព ពតិមាន.....) ។

៥- ការបង្កើតអង្គការកសិករ (ដែលជាផ្នែកមួយនៃការផ្សព្វផ្សាយផងដែរ) ។

៦- កម្មវិធីឥណទានជនបទ សំរាប់ការអភិវឌ្ឍន៍កសិកម្ម និងទឹក ។

៧- ផ្នែកធានាដល់ដំណាំ ។

៨- កសិ-ទេសចរណ៍ ។

### ៦.៣.៥_ មធ្យោបាយ និងការទទួលខុសត្រូវ ចំពោះការអនុវត្តន៍

ចាំបាច់ត្រូវមានសកម្មភាពសំខាន់ៗ ក្នុងការអនុវត្តន៍នូវគោលបំណងទាំងនេះ ។ សកម្មភាពទាំងនេះ គឺដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំរាប់រួមចំណែកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងពីឯកសារព្រាងនានា របស់ក្រុមយុទ្ធសាស្ត្រ នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។ ក្នុងជំហានបន្ទាប់ នៃកិច្ចដំណើរការនេះ សកម្មភាពទាំងនេះ នឹងត្រូវបានពិនិត្យ និងកែសំរួលឡើញវិញ និងកំណត់លំអិតថែមទៀត ក្នុងឯកសាររៀបចំកម្មវិធី (លក្ខខ័ណ្ឌការងារក្នុងឧបសម្ព័ន្ធ ៣) ។

## ៦.៤_ កម្មវិធីគ្រប់គ្រងធនធានទឹក ប្រព័ន្ធធារាសាស្ត្រ និង ដីធ្លី

### ៦.៤.១_ សន្និដ្ឋានភាព

ដីធ្លី ដី និងទឹក គឺជាធនធានសំខាន់បំផុត សំរាប់កសិកម្ម ។ ទោះជាយ៉ាងនេះក្តី ដីធ្លី និងធនធានទឹក នៅពេលបច្ចុប្បន្ននេះ កំពុងបានប្រើប្រាស់ដោយមិនមានប្រសិទ្ធិភាព ក្នុងកន្លែងជាច្រើននៅក្នុងប្រទេសកម្ពុជា ។ ហើយនៅតំបន់ជាច្រើនដែលដីអាចដាំដុះបាន នាពេលបច្ចុប្បន្ននេះ មិនត្រូវបានប្រើប្រាស់ទេ ។ បញ្ហាសំខាន់ គឺ

ចាំបាច់ត្រូវមានការអនុវត្តន៍នូវសិទ្ធិស្របច្បាប់ ដើម្បីធានាឱ្យមានកម្មសិទ្ធដីធ្លី ក្នុងការកាន់កាប់ដី បើពុំនោះទេកសិករនឹងមានការរួញរា ក្នុងការវិនិយោគក្នុងការផលិតដែលមានលក្ខណទំនើប និងមានពិពិធកម្មនោះ ។ បញ្ហានេះ ត្រូវតែបានដោះស្រាយ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ មុននឹងឈានដល់ការបង្កើននូវទិន្នផលកសិកម្ម ប្រកបដោយនិរន្តរភាពនោះ ។ ការប្រើប្រាស់ដី ដោយពេញលេញ វាក៏អាស្រ័យផងដែរលើលទ្ធភាព និងឆន្ទៈរបស់កសិករក្នុងការផ្តល់នូវធនធានផ្សេងៗទៀត ដូចជា ពលកម្ម ចំណេះដឹង និងបច្ចេកវិទ្យា និងមានប្រាក់គ្រប់គ្រាន់ ក្នុងការទិញនូវគ្រាប់ពូជល្អ ជី ។ល។

ដូចបានកត់សំគាល់ក្នុងចំណុច ៥.១.៣ ទឹក គឺជាកត្តាសំខាន់បំផុត ក្នុងការសំរេចបាននូវផលិតផលកសិកម្មដែលមានការកើនឡើងនោះ ។ ដូចនេះ ការអភិវឌ្ឍន៍ដីសំរាប់កសិកម្ម បានទទួលនូវផលប្រយោជន៍ ផ្នែកសេដ្ឋកិច្ចសង្គមខ្ពស់បំផុត នៅកន្លែងណាដែលមានទឹកគ្រប់គ្រាន់ ឬ អាចផ្តល់ទឹកដោយការប្រមូលទឹកភ្លៀងទុក ការស្តុកទឹកទុកតាមរដូវ ការបង្វែរទឹកពីអាងផ្សេងៗ ឬ ការទាញយកទឹកក្រោមដីមកប្រើប្រាស់ ។ ឧទាហរណ៍ ផ្សេងៗដូចជាបញ្ជីរសារពើភ័ណ្ឌធនធានដី ការធ្វើផែនការ និងវាយតំលៃលើលទ្ធភាពប្រើប្រាស់ដី (រួមទាំងការវាយតំលៃលើទីផ្សារ និងការចូលទៅទីផ្សារ) និងការវិភាគលើកសិ-បរិស្ថាន (Agro-Ecosystems Analysis-AEA) អាចជួយក្នុងការកំណត់នូវទីតាំង ដែលកសិករ និងភ្នាក់ងាររដ្ឋាភិបាល អាចវិនិយោគនូវធនធាន ក្នុងការអភិវឌ្ឍន៍នូវធនធានទឹក និងដី ដើម្បីទទួលបាននូវផលប្រយោជន៍ច្រើនបំផុតត្រលប់មកវិញ ។ ឧបករណ៍ ដែលទាក់ទងនឹងដីទាំងនេះ ត្រូវអនុវត្តន៍ស្របគ្នាជាមួយនឹងឧបករណ៍ ដែលទាក់ទងនឹងទឹក នៃការគ្រប់គ្រងធនធានទឹករួម ការគ្រប់គ្រងអាងទន្លេ និងការចែកចាយទឹក (សូមមើលផ្នែកខាងក្រោម) ដើម្បីធានាដល់ការប្រើប្រាស់ល្អបំផុត នៃធនធានទាំងពីរនេះ រួមគ្នា ។ ដូចបានកត់សំគាល់ក្នុងចំណុច ៦.២.១ យុទ្ធសាស្ត្រនេះ ត្រូវជំរុញដល់ការអភិវឌ្ឍន៍ដែលមានលក្ខណស្មើៗគ្នា ។ ទោះជាយ៉ាងនេះក្តី បញ្ជីរសារពើភ័ណ្ឌ និងការ វិភាគលើធនធានទឹក និងដី នឹងចង្អុលបង្ហាញ នូវកន្លែងណា ដែលផ្តល់ឳកាសក្នុងការអភិវឌ្ឍន៍នូវប្រភេទកសិកម្មផ្សេងៗគ្នា ហើយដែលអាចជំរុញដល់ការបណ្តាក់ទុន ក្នុងតំបន់ដែលអាចផ្តល់ផលប្រយោជន៍ច្រើនបំផុត ។

នៅតំបន់ដីដាំដំណាំ ដែលកំពុងធ្វើការស្រោចស្រពបច្ចុប្បន្ន តំបន់ដែលអាចស្រោចស្រព និងពឹងផ្អែកលើទឹកភ្លៀង ភាគច្រើនក្នុងប្រទេសកម្ពុជា គឺនៅអាចមានលទ្ធភាពគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធិភាព និងទទួលបានលទ្ធផលល្អថែមទៀត ដោយប្រើនូវបច្ចេកវិទ្យា ដែលមាន ។

ការស្រោចស្រពបន្ថែម នៅក្នុងរដូវវស្សា គឺបានកំពុងជា មធ្យោបាយដ៏សំខាន់មួយ ក្នុងការបង្កើននូវផលិតផល និងកាត់បន្ថយនូវហានិភ័យ ចំពោះដីដំណាំប្រមាណ ២០% ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ។ ការស្រោចស្រពទាំងស្រុងនារដូវប្រាំង គឺបានអនុវត្តន៍តែនៅលើដីដំណាំប្រមាណ ៧-៨% នាពេលបច្ចុប្បន្នតែប៉ុណ្ណោះ ។ គោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺដើម្បីបង្កើនផ្ទៃដីស្រោចស្រពឱ្យបានដល់ ២៥% នៅឆ្នាំ ២០១០ (ចំណុច១.២) ។ ដោយសារស្ថានភាពភូមិសាស្ត្រ និងជលសាស្ត្រមិនអំណោយផលល្អនោះ គឺប្រហែលមានតែ

ប្រមាណ២០% នៃដីដែលអាចដាំដំណាំប៉ុណ្ណោះ ដែលអាចធ្វើការស្រោចស្រព ដោយទទួលបានផលល្អ ដោយប្រើរបៀបស្រោចស្រព ដែលធ្លាប់ប្រើប្រាស់ ជាលក្ខណៈប្រពៃណីក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ បច្ចេកវិទ្យាផ្សេងៗទៀត ក្នុងការគ្រប់គ្រងទឹកសំរាប់ដំណាំ (រួមទាំងការប្រមូលទឹកភ្លៀងទុក.......) ដែលត្រូវបានគេប្រើក្នុងប្រទេសផ្សេងៗទៀតនោះ ក៏អាចអនុវត្តន៏ក្នុងប្រទេសកម្ពុជាបានដែរ ។

ដោយសារធនធានទឹក ត្រូវបានគេប្រើប្រាស់កាន់តែច្រើនថែមទៀតនោះ គឺវាមានកាលំបាកកាន់តែច្រើនក្នុងការប្រជែងគ្នា និងមានជំលោះ ក្នុងចំណោមអ្នកប្រើប្រាស់ ដូចជា កសិករ អ្នកនេសាទ អ្នកផ្គត់ផ្គង់ទឹកនៅជនបទ និងទីក្រុង អ្នកផលិតវារីអគ្គីសនី ។ល ។ វាក៏មាន ការកើនឡើងផងដែរ នូវការខូចខាតធនធាន និងប្រព័ន្ធអេកូឡូស៊ី ដោយការយកទឹកមកប្រើប្រាស់ហួសកំណត់ និងការធ្វើឱ្យក្រខ្វក់ទន្លេ និងបឹង ដោយសារតែជាតិគីមី ដែលប្រើប្រាស់ក្នុងផ្នែកកសិកម្ម (agro-chemicals) និងធាតុក្រខ្វក់ផ្សេងៗទៀត ។ល ។ ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ បច្ចេកទេសក្នុងការគ្រប់គ្រងធនធានទឹករួម (IWRM) ការគ្រប់គ្រងអាងទន្លេ (RBM) និងការចែកចាយទឹក ត្រូវបានបង្កើតឡើង ។ បច្ចេកទេសទាំងនេះ ទាមទារឱ្យមាននូវធនធានជាច្រើន និងស្ថាប័នរឹងមាំ ហើយបើតាមបទពិសោធន៏អន្តរជាតិ បានបង្ហាញថា ចាំបាច់ត្រូវប្រើរយៈពេលនៃការខិតខំប្រឹងប្រែងជាប្រចាំដ៏យូរមួយ ដើម្បីទទួលបាននូវជោគជ័យនោះ ។ ទោះជាយ៉ាងនេះក្តី វាត្រូវតែបានអនុវត្តន៏ក្នុងប្រទេសកម្ពុជា នៅកន្លែងណា ដែលមានការប្រជែងទឹកគ្នា និងនាំឱ្យមានជំលោះក្នុងចំណោមអ្នកប្រើប្រាស់ ឬ មានការខូចខាតដល់ធនធាននោះ ។ ទន្លេមេគង្គ ដែលជាប្រភពទឹកអន្តរជាតិដ៏សំខាន់មួយនោះ បានអនុវត្តន៏រួចហើយនូវការគ្រប់គ្រងទឹកជំនន់ តាមរយៈយន្តការនៃកិច្ចព្រមព្រៀងទន្លេមេគង្គ ។ ការគ្រប់គ្រងរួម នៃទឹក និងធនធានក្នុងទឹក (ជលផល ព្រៃឈើ ដែលលិចទឹកតាមរដូវ ។ល ។) ក្នុងអាងទន្លេសាប គឺជាប្រការសំខាន់ នាពេលបច្ចុប្បន្ន ប្រសិនបើយើងមិនចង់ឱ្យមានការខូចខាតដល់ធនធាននោះទេ ។ ការគ្រប់គ្រងរួម លើអាងផ្សេងៗទៀតក៏ជាការ ចាំបាច់ផងដែរ ក្នុងពេលធ្វើផែនការអភិវឌ្ឍន៏ធនធានទឹក ដែលអាចមានជំលោះនោះ ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្រ្តអាងទន្លេ (River Basin approach) ក្នុងយុទ្ធសាស្រ្តនេះ គឺត្រូវបានកំណត់ដូចខាងក្រោម គឺការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនូវធនធានទឹក និងដី សំរាប់កសិកម្ម និងការប្រើប្រាស់ផ្សេងទៀត ដែលទាក់ទង ក្នុងក៏រិតអាងទន្លេ តាមទស្សនៈបច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន ព្រោះថា ការគ្រប់គ្រងអាងទន្លេ ដ៏ពេញលេញ មិនអាចដោះស្រាយបានដោយយុទ្ធសាស្រ្តនេះទេ ដោយសារពេលវេលា និងធនធានមានកំណត់ (ដោយមិនគិតពីការប្រើប្រាស់ក្នុងការដឹកជញ្ជូន វារីអគ្គីសនី ការប្រើប្រាស់ក្នុងផ្នែកឧស្សាហកម្ម ។ល ។) ។

ការគ្រប់គ្រងធនធានទឹក និងផ្ទៃរងទឹកភ្លៀង ជាទូទៅ ត្រូវបានអនុវត្តន៏ទៅ ជាលក្ខណៈសមូហភាព ឬ ក្នុងក្របខ័ណ្ឌបទបញ្ញត្តិមួយ ដែលជៀសវាងបាននូវការប្រើប្រាស់ហួសប្រមាណ ឬ ការខូចខាតដល់ធនធានធម្មជាតិ ដោយសារការប្រើប្រាស់ដោយគ្មានការគ្រប់គ្រង ដោយបុគ្គល និងសហគ្រាសឯកជននោះ ។ ធនធានទឹក ឬ ផ្ទៃរងទឹកភ្លៀង ជាទូទៅ បានផ្តល់នូវផលប្រយោជន៏យ៉ាងសំខាន់ ប្រសិនបើអ្នកប្រើប្រាស់ធនធាន ធ្វើការរួមគ្នា

ជាពិសេស នៅកន្លែងដែលមានកម្មសិទ្ធដីតូចៗ និងមានលក្ខណៈទាក់ទងគ្នាទៅវិញទៅមក នៅកន្លែងដែលផ្លូវទឹកមិនត្រូវបានកំណត់ឱ្យបានត្រឹមត្រូវ ឬ ត្រូវបានកែប្រែដោយសកម្មភាពរបស់មនុស្ស ឬ នៅកន្លែងដែលផ្ទៃរងទឹកភ្លៀង ងាយរងការខូចខាត ដោយសារដីដាំដំណាំ ឬ រុក្ខជាតិគ្រប់ដណ្តប់នោះ មានលក្ខណៈផុយ និងងាយហូរដាច់ ។ វិធីសាស្រ្តក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្ត ដោយមានការចូលរួម (PIMD) ត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ក្នុងប្រទេសកម្ពុជា ហើយនឹងត្រូវបានពង្រីកនាពេលអនាគត ។ ការរៀបចំផ្សេងទៀតក្នុងការជំរុញដល់កិច្ចសហប្រតិបត្តិការ នៅថ្នាក់សហគមន៍ ដូចជាការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង ឬ ធនធានព្រៃឈើក្នុងសហគមន៍ ត្រូវបានកំពុងបង្កើតឡើងផងដែរ ក្នុងប្រទេសកម្ពុជា ។ វាក៏នឹងត្រូវពង្រីកផងដែរ ។ ក្រុមប្រឹក្សាឃុំសង្កាត់ ផ្តល់នូវមធ្យោបាយមួយ ក្នុងការជំរុញដល់កិច្ចសហប្រតិបត្តិការ នៅថ្នាក់សហគមន៍ ក្នុងការគ្រប់គ្រងធនធាន ។

ដីដាំដំណាំ និងទឹក គឺជាធនធានសំខាន់សំរាប់កសិករ ប៉ុន្តែវាក៏អាចមានផលវិបាកច្រើនដែរ ដូចជាការខូចខាត និង ហូរច្រោះដីដាំដំណាំ ទឹកជំនន់នាំឱ្យខូចខាត និង គ្រោះរាំងស្ងួត ឬ កូនរដូវប្រាំង ដែលនាំឱ្យមានការអនុវត្តន៍នូវវិធីសាស្រ្ត ដែលមានលក្ខណៈអភិរក្ស និងមានហានិភ័យមិនល្អ ចំពោះការងារកសិកម្ម ។ មានបច្ចេកទេសជាច្រើន ក្នុងការថែរក្សាដីដាំដំណាំ ការគ្រប់គ្រងទឹកជំនន់ និងការកាត់បន្ថយនូវគ្រោះភ័យ ពីគ្រោះរាំងស្ងួត ដែលអាចអនុវត្តន៍បាន នៅក្នុងទីជនបទនៃប្រទេសកម្ពុជា ដែលសកម្មភាពទាំងនោះ ជាទូទៅត្រូវការឱ្យមានកិច្ចសហការល្អ នៅថ្នាក់សហគមន៍ ហើយដែលកម្មវិធីនេះ មានគោលបំណងផ្តល់នូវអំណាចដល់សកម្មភាពសហគមន៍ ក្នុងផ្នែកនោះ ។

## ៦.៤.២. គោលបំណង និង គោលដៅ

គោលបំណងសំខាន់របស់កម្មវិធីនេះ គឺដើម្បីបង្កើននូវការប្រើប្រាស់ប្រកបដោយផលិតភាព នូវដីដែលអាចដាំដំណាំបាន និងធនធានទឹកដែលទាក់ទង ជាពិសេស តាមរយៈការបង្កើននូវភាពសក្តិសិទ្ធ និងប្រសិទ្ធិភាពដែលតាមរយៈនោះ មានការគ្រប់គ្រងទឹកសំរាប់កាលូតលាស់របស់ដំណាំ ។ ទោះជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បានផ្តោតការយកចិត្តទុកដាក់ជាពិសេស លើការស្រោចស្រពក៏ដោយ កម្មវិធីនេះ នឹងលើកឡើង ទាំងដីដំណាំដែលធ្វើការស្រោចស្រព និងដីដំណាំ ដែលពឹងផ្អែកលើទឹកភ្លៀង ។ កម្មវិធីនេះ មានបំណងជំរុញដល់ការបណ្តាក់ទុនក្នុងតំបន់ (គឺទាំងទីតាំងភូមិសាស្រ្ត និងប្រភេទដំណាំ) ដែលអាចទទួលបាននូវផលប្រយោជន៍ ផ្នែកសេដ្ឋកិច្ចសង្គមខ្ពស់បំផុត ហើយក្នុងពេលជាមួយគ្នានោះ ធានាបានថា ធនធានទឹក និងដីដាំដំណាំ មិនត្រូវបានខូចខាត ដោយសារការប្រើប្រាស់ហួសប្រមាណ និងការប្រជែងដណ្តើមគ្នានោះទេ ។ កម្មវិធីនេះ បានផ្តោតជាសំខាន់លើការបង្កើននូវសមភាពសង្គម ជាពិសេស ក្នុងលទ្ធភាពទទួលបាន និងរក្សាបាននូវដីសំរាប់ប្រើប្រាស់ និងជួយដល់កសិករក្នុងការជៀសវាងបាន នូវផលប៉ះពាល់មិនល្អនៃគ្រោះធម្មជាតិ ។ កម្មវិធីនេះ ក៏មានបំណងផងដែរ ក្នុងការសំរួល

ដល់កិច្ចសហប្រតិបត្តិការ ក្នុងចំណោមសហគមន៍កសិករ ជាពិសេស ទាក់ទងនឹងការគ្រប់គ្រងមធ្យោបាយ ដែលជាកម្មសិទ្ធរបស់សហគមន៍ ។

គោលដៅអភិវឌ្ឍន៍របស់កម្មវិធី ដែលបានកំណត់សំរាប់ឆ្នាំ ២០០៦-២០១០ (ចំណុច ៤.៣) គឺ:

***ការគ្រប់គ្រងធនធានទឹក ប្រកបដោយនិរន្តរភាព និងមានប្រយោជន៍ ដល់អ្នកក្រីក្រ មធ្យោបាយគ្រប់គ្រងទឹក គ្រោះថ្នាក់ដែលទាក់ទងនឹងទឹក និងធនធានទឹក ដែលមានលក្ខណរួមគ្នា មានប្រសិទ្ធិភាព និងអនុវត្តន៍ទៅ ក្នុងបរិបទអាងទន្លេ ។***

## ៦.៤.៣~ គោលបំណង

ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍របស់កម្មវិធីនេះ គោលបំណងចំនួន ៧ ត្រូវបានកំណត់ :

១- ធនធានទឹក ត្រូវបាននិងកំពុងអភិវឌ្ឍន៍ និង ប្រើប្រាស់ក្នុងរបៀបមួយ ដែលចាត់ទុកអាងទន្លេជាខ្នាតគោល ក្នុងការគ្រប់គ្រង ការកាត់បន្ថយនូវការខូចខាតធនធានក្នុងទឹក និងជៀសវាងនូវការប្រជែងដណ្តើមគ្នា រវាងអ្នកប្រើប្រាស់ ហើយនៅកន្លែងណាដែលសមស្រប ត្រូវប្រើនូវបច្ចេកទេសគ្រប់គ្រងធនធានទឹករួម (IWRM) និងការគ្រប់គ្រងអាងអាងទន្លេ (RBM) ។

២- ធនធានដី ត្រូវបានចុះបញ្ជីរសារពើភ័ណ្ឌ និងវាយតំលៃ លើសក្តានុពលកសិកម្មរបស់វា ហើយនីតិវិធីត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍន៍ និងគ្រប់គ្រងរួមគ្នានូវដី និងទឹក និងធនធានដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីសំរេចបាននូវការប្រើប្រាស់ល្អបំផុតលើធនធានទាំងអស់នោះ ។

៣- ដីដាំដុះ និងកសិដ្ឋានផ្សេងៗ ដែលមានសក្តានុពលកសិកម្មខ្ពស់ ត្រូវបានប្រើប្រាស់សំរាប់ផលិតកម្ម ហើយត្រូវបានប្រើ ប្រកបដោយនិរន្តរភាព ក្នុងការផលិតនូវផលិតផលកសិកម្ម ដែលអាចផ្តល់នូវចំណូលល្អបំផុត សំរាប់ការបណ្តាក់ទុន ។

៤- កសិករនៅលើដីដំណាំដែលធ្វើការស្រោចស្រព និងដីដំណាំ ដែលពឹងផ្អែកលើទឹកភ្លៀង អាចគ្រប់គ្រងប្រមែប្រមូល និងប្រើប្រាស់ទឹកបានល្អ (រួមទាំងការស្រោចស្រពបន្ថែម) លើផ្ទៃដីសរុប ដែលមានការកើនឡើងយ៉ាងតិច ២០,០០០ ហិចតា ក្នុងមួយឆ្នាំ ។

៥- កសិករមានកម្មសិទ្ធដីស្របច្បាប់ ។

៦- សហគមន៍ជនបទ អាចជៀសវាងបាន ឬ ដោះស្រាយបាន ដោយគ្មានការបាត់បង់ធំៗ ចំពោះផលប៉ះពាល់មិនល្អ នៃទឹកជំនន់ដែលនាំឱ្យខូចខាត គ្រោះរាំងស្ងួត ឬ កូនរដូវប្រាំង ។

៧- ការវិភាគលើ កសិ-បរិស្ថាន នៃប្រព័ន្ធធារាសាស្ត្រ សម្បទានដីសង្គម និង សម្បទានដីសេដ្ឋកិច្ច ។

## ៦.៤.៤~ ផ្នែកសំខាន់ៗ

ផ្នែកសំខាន់ៗនៃកម្មវិធីអាចរួមមាន (តាមឯកសារគោលគំនិតយុទ្ធសាស្ត្រ –Straegy Concept Note):

១- ការធ្វើផែនការប្រើប្រាស់ទឹក និង ដីរួម និងដោយផ្អែកលើមូលដ្ឋានអាងទន្លេ ។

២- ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ដោយផ្អែកលើមូលដ្ឋាននៃការវិភាគលើកសិ-បរិស្ថាន (ផ្អែកតាមចំណុច ១) ។

៣- អភិវឌ្ឍន៍ និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម (ផ្អែកតាមចំណុច១) ។

៤- ការអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម (រួមទាំងប្រសិទ្ធិភាពនៃការប្រើប្រាស់ទឹក) ។

៥- ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ស្តីពីការគ្រប់គ្រងកសិកម្ម និងទឹកនៅកសិដ្ឋាន ដោយមានការចូលរួម ។

៦- កម្មវិធីបែងចែក និង ផ្តល់កម្មសិទ្ធដីធ្លី ។

៧- កម្មវិធីត្រៀមបង្ការគ្រោះរាំងស្ងួត និងទឹកជំនន់

### ៦.៤.៥. មធ្យោបាយ និង ការទទួលខុសត្រូវ ក្នុងការអនុវត្តន៍

ចាំបាច់ត្រូវមានសកម្មភាពសំខាន់ៗ ក្នុងការអនុវត្តន៍នូវគោលបំណងទាំងប្រាំនេះ ។

សកម្មភាពទាំងនេះ ទាញចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ក្នុងការរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងតាមឯកសារផ្សេងៗ ដែលព្រាងដោយក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (TWGAW) ។ នៅដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនេះ សកម្មភាពទាំងនេះ នឹងត្រូវពិនិត្យ និងកែតំរូវឡើងវិញ និងកំណត់ឱ្យបានលំអិតថែមទៀត ក្នុងឯកសាររៀបចំកម្មវិធី (លក្ខខ័ណ្ឌការងារ ក្នុងឧបសម្ព័ន្ធ ៣) ។

## ៦.៥. កម្មវិធីអប់រំ ផ្សព្វផ្សាយ និងស្រាវជ្រាវកសិកម្ម និងទឹក

### ៦.៥.១. សន្និដានភាព

មានមូលដ្ឋានចំណេះដឹង ពត៌មាន និងបច្ចេកវិទ្យាយ៉ាងទូលំទូលាយ ទាក់ទងនឹងវិស័យកសិកម្ម និងទឹក ។ ការខិតខំប្រឹងប្រែងស្រាវជ្រាវរបស់ប្រទេសកម្ពុជាខ្លួនឯងផ្ទាល់ ជាពិសេស ដោយវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) និងនាយកដ្ឋានបច្ចេកទេស វាជាកត្តបន្ថែម ទៅលើមូលដ្ឋានទាំងនោះថែមទៀត ។ ចំណេះដឹង ពត៌មាន និងបច្ចេកវិជ្ជា (KIT) នេះ ផ្តល់នូវលទ្ធភាព ក្នុងការពង្រីកនូវចំណេះដឹង ជាលក្ខណៈប្រពៃណី និងការអនុវត្តន៍ ក្នុងកសិដ្ឋាន ពិពិធកម្មកសិកម្ម និងការបង្កើននូវផលិតភាព ។ ទោះជាយ៉ាងនេះក្តី នៅមានកន្លែងជាច្រើនដែលត្រូវការនូវចំណេះដឹង និងបច្ចេកវិទ្យាល្អៗ បន្ថែមទៀត ឬ ដែលចំណេះដឹង

ពតិមាន និងបច្ចេកវិជ្ជានេះ មិនត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនោះ ។ ម្យ៉ាងទៀត បញ្ហាដែលកើតមាន ដូចជា ការចាំបាច់ត្រូវប្រមូលទឹកភ្លៀង និងបច្ចេកទេសថែរក្សា ក្នុងតំបន់ដីដាំដំណាំ ដែលពឹងផ្អែកលើទឹកភ្លៀង ឬ ក្នុងការបង្កើនទូវការកែច្នៃក្រោយពេលប្រមូលផល និងការរកទីផ្សារ ដើម្បីបន្ថែមតំលៃ គឺបាននាំមកនូវតំរូវការ បន្ថែមទៀត ចំពោះចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា ដែលសមស្របទៅនឹងស្ថានភាព កសិ-ឧស្សាហកម្ម នៅក្នុង ប្រទេសកម្ពុជា ។

ទិដ្ឋភាពសំខាន់របស់ ចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា គឺជាចំណេះដឹង ក្នុងផ្នែកជនបទ ឬ កសិដ្ឋាន ដែលត្រូវការជាចាំបាច់ សំរាប់ជាមូលដ្ឋាន ក្នុងការវិភាគលើគោលនយោបាយ និងធ្វើផែនការ ។ ចាំបាច់ត្រូវមាន ការស្រាវជ្រាវជាក់ស្តែងជាប្រចាំ ស្តីពីការផ្លាស់ប្តូរក្នុងសហគមន៍ជនបទ ឬ កសិករ កសិ-ឧស្សាហកម្ម សេដ្ឋកិច្ច កសិកម្ម និងការគ្រប់គ្រងទឹក និងបញ្ហាផ្សេងៗទៀត ដែលជួយដល់រាជរដ្ឋាភិបាល ក្នុងការកែតំរូវបរិយាកាស នយោបាយ ។ ដោយសារផលប៉ះពាល់នៃការផ្លាស់ប្តូរអាកាសធាតុ និងការប្រែប្រួលផ្សេងៗទៀត បានក្លាយជា បញ្ហាជាក់ស្តែងក្នុងទូទាំងពិភពលោកនោះ វាជាប្រការសំខាន់ណាស់ ក្នុងការព្យាករណ៍នូវផលប៉ះពាល់លើកសិកម្ម ក្នុងប្រទេសកម្ពុជា និងលើកឡើងនូវវិធានការ ក្នុងការកាត់បន្ថយនូវផលប៉ះពាល់អាក្រក់ និងទទួលបាននូវ ផលប្រយោជន៍ ពីផលប៉ះពាល់វិជ្ជមាន ។

ចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា មានតំលៃតិចតួចណាស់ ប្រសិនបើវាមិនត្រូវបានគេប្រើប្រាស់ទេនោះ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម មានមន្ត្រីផ្សព្វផ្សាយ និងបុគ្គលិក តាមមូលដ្ឋានជាច្រើន ដែលមានភារៈកិច្ចជួយដល់កសិករក្នុងការអនុវត្តន៍នូវចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា ក្នុង កសិដ្ឋានរបស់គេផ្ទាល់ ។ ទោះជាយ៉ាងណាក៏ដោយ មានឧបស័គ្គជាច្រើន ដែលរំខានដល់ប្រសិទ្ធិភាពរបស់ វា ។ ឧបស័គ្គទាំងនោះ រួមមាន ការបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយនៅមានក៏រិត និងការខ្វះខាតនូវ មធ្យោបាយនានា ដូចជា កសិដ្ឋានសំរាប់បង្ហាញជាដើម ។ ដូចនេះ យន្តការក្នុងការផ្ទេរនូវចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា ដល់ថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវតែពង្រឹង ។ ឧទាហរណ៍ សាលារៀនតាមកសិដ្ឋានរបស់កសិករ (Farmer Field School) គឺជាមធ្យោបាយដ៏ល្អប្រសើរមួយ ក្នុងការអប់រំកសិករ និងការផ្ទេរនូវបច្ចេកវិទ្យា ។ ក្នុងពេលជាមួយគ្នានេះដែរ ត្រូវផ្ទេរនូវសិទ្ធអំណាចដល់កសិករ ក្នុងការទទួលខុសត្រូវ ចំពោះ កិច្ចការក្នុងសហគមន៍ របស់គេផ្ទាល់ ឧទាហរណ៍ ដូចជា តាមរយៈការបង្កើត និងពង្រឹងជាប្រចាំ នូវសហគមន៍កសិករប្រើប្រាស់ទឹក និង រាល់គ្រប់រូបភាពនៃអង្គការកសិករ និងមានការកសាងសមត្ថភាព ដែលសមស្របចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ។ សមាសធាតុសំខាន់របស់ ចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា គឺប្រហែលជា ការជួយដល់កសិករ ក្នុងការអនុវត្តន៍នូវ ការពិសោធន៍របស់គេផ្ទាល់ បង្កើតគំនិតថ្មីៗរបស់គេផ្ទាល់ និងផ្ទេរនូវ ចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា របស់គេ ដល់អ្នកដែលអាចទទួលផលប្រយោជន៍ផ្សេងៗទៀត ។

កម្មវិធីនេះ គ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពនៃការទទួលបាន និងប្រើប្រាស់នូវចំណេះដឹង ពតិមាន និង បច្ចេកវិជ្ជា ។ ករណីនេះ គឺរួមមាន ទាំងការស្រាវជ្រាវប្រមែប្រមូលនូវ ចំណេះដឹង ពតិមាន និងបច្ចេកវិជ្ជា ដែលមានក្នុងប្រទេសផ្សេងៗទៀត បន្តអប់រំ និងបណ្តុះបណ្តាលដល់អ្នកវិទ្យាសាស្ត្រ និងមន្ត្រីផ្សព្វផ្សាយ សេវាកម្មផ្សព្វផ្សាយដល់កសិករ ផ្តល់លទ្ធភាពឱ្យកសិករ និងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ ឱ្យចូលរួមក្នុងសកម្មភាពនានា ដូចជាក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រជាដើម។ល។ វារួមមានផងដែរ នូវការប្រមូលនូវពតិមានស្តីពីសង្គមជនបទ កសិកម្ម និងកសិ-ធុរកិច្ច និងទីផ្សារកសិកម្ម សំរាប់ផលិតផលកសិកម្ម ដែលជាមូលដ្ឋានក្នុងការធ្វើផែនការ និងការរៀបចំគោលនយោបាយ ។ កម្មវិធីនេះ នឹងគ្របដណ្តប់ផងដែរលើបញ្ហាជាប្រពៃណី ដូចជាការបង្កើននូវប្រភេទដីក្នុងការដាំដំណាំ និងឈានទៅដោះស្រាយបញ្ហាថ្មីៗ ដូចជាការបង្កើននូវបច្ចេកវិទ្យាកែច្នៃផលិតផល បង្កើនតួនាទីក្នុងការផលិតរបស់ស្ត្រី និងបង្កើននូវប្រសិទ្ធិភាពក្នុងការគ្រប់គ្រងទឹកសំរាប់ដំណាំ ។ ផែនការមេ សំរាប់ការសិក្សាស្រាវជ្រាវកសិកម្មធម្មជាតិ ផ្តល់នូវមាគ៌ាណែនាំយ៉ាងសំខាន់ ។ ផ្នែក និងដំណាក់កាលផ្សេងៗនៃកម្មវិធីនេះ ត្រូវតែមានការទំនាក់ទំនងគ្នា ជាពិសេស ផ្នែកដែលទាក់ទងនឹងការគ្រប់គ្រងកសិកម្ម និងទឹក ។

## ៦.៥.២_ គោលបំណង និង គោលដៅ

គោលបំណងនៃកម្មវិធីនេះ ចែកចេញជាពីរផ្នែក : ទីមួយ គឺដើម្បីធានាថា មន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កសិករ និងអ្នកពាក់ព័ន្ធនឹងកសិ-ធុរកិច្ចផ្សេងៗទៀត បានទទួល និងប្រើប្រាស់នូវចំណេះដឹង ពតិមាន និង បច្ចេកវិទ្យាដែលទាក់ទងនឹងកសិកម្ម កសិ-ធុរកិច្ច និងការគ្រប់គ្រងទឹក និង ទីពីរ គឺដើម្បីផ្តល់នូវលទ្ធភាពឱ្យសហគមន៍ជនបទ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអង្គការដែលមានមូលដ្ឋាននៅសហគមន៍ផ្សេងៗទៀត បានចូលរួមប្រកបដោយប្រសិទ្ធិភាព ក្នុងគ្រប់ទិដ្ឋភាពនៃកសិកម្ម កសិ-ធុរកិច្ច និង ការគ្រប់គ្រងទឹក ដែលតំរូវឱ្យមានសកម្មភាព ជាសមូហភាពនោះ ។

គោលដៅអភិវឌ្ឍន៍របស់កម្មវិធី ដែលបានកំណត់សំរាប់ ឆ្នាំ ២០០៦-២០១០ (ចំណុច ៤.៣) គឺ :

សមត្ថភាពប្រកបដោយលក្ខណៈទូលំទូលាយ និងមានការសំរបសំរួល ក្នុងការប្រមូល និង ប្រើប្រាស់នូវចំណេះដឹង ពតិមាន និង បច្ចេកវិទ្យា ទាក់ទងនឹងកសិកម្ម និងទឹក ។

## ៦.៥.៣_ គោលបំណង

ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍នេះ គោលបំណងចំនួនបួន ត្រូវបានកំណត់ :

១- សមត្ថភាព ប្រកបដោយភាពរស់រវើក និងមាននិរន្តរភាព សំរាប់ការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមមានទាំងមធ្យោបាយដែលមានធនធានគ្រប់គ្រាន់ និងអ្នកវិទ្យាសាស្ត្រ ឬ អ្នកបច្ចេកទេស ដែលមានឆន្ទៈ ។

២- មានមូលដ្ឋានចំណេះដឹង ឬ ពតិមានថ្មីៗ និងសមត្ថភាពជំនាញ ដែលផ្អែកតាមបណ្តុំប្រសិទ្ធិភាពតំលៃនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបទពិសោធន៍ធ្វើការងារនៅមូលដ្ឋាន និង ពតិមានដែលប្រមូលបាន ពីប្រភពអន្តរជាតិ ។

៣- សមត្ថភាព ដ៏មានប្រសិទ្ធិភាព និងមានលក្ខណៈទូលំទូលាយ ក្នុងការអប់រំ និងបណ្តុះបណ្តាលដល់មន្ត្រីបច្ចេកទេស និងស្រាវជ្រាវ របស់រាជរដ្ឋាភិបាលកម្ពុជា កសិករ និងអ្នកដទៃទៀត ដែលពាក់ព័ន្ធក្នុងកសិកម្ម កសិ-ធុរកិច្ច និងការគ្រប់គ្រងទឹក និងសំរាប់ផ្ទេរនូវបច្ចេកវិទ្យាដែលសមស្របដល់អ្នកដែលអាចទទួលផលប្រយោជន៍ ។

៤- សមត្ថភាព ប្រកបដោយប្រសិទ្ធិភាព និងមានលក្ខណៈកំរិតជាតិ ក្នុងការផ្ទេរសិទ្ធិអំណាច និងបណ្តុះបណ្តាលដល់សហគមន៍ជនបទ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យចូលរួម និងទទួលខុសត្រូវ ចំពោះគ្រប់ទិដ្ឋភាពនៃកសិកម្ម កសិ-ធុរកិច្ច និងការគ្រប់គ្រងទឹកក្នុងសហគមន៍ ។

## ៦.៥.៤_ ផ្នែកសំខាន់ៗ

ផ្នែកសំខាន់ៗនៃកម្មវិធីនេះ អាចរួមមាន ( តាមឯកសារគោលគំនិតយុទ្ធសាស្ត្រ) :

១- ការសិក្សាស្រាវជ្រាវពីដំណាំ និងទឹក (រួមទាំងប្រព័ន្ធធារាសាស្ត្រ តំរូវការទឹករបស់ដំណាំ ជីជាតិដី ឬដីដាំដំណាំ ចំណាត់ថ្នាក់ដី និងការចែកតំបន់ដំណាំ) ។

២- ការសិក្សាស្រាវជ្រាវ លើដំណាំកៅស៊ូ

៣- ការសិក្សាស្រាវជ្រាវ លើការចិញ្ចឹមសត្វ

៤- ការសិក្សាអាងទន្លេ

៥- ការសិក្សាស្រាវជ្រាវ លើសក្តានុពលអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

៦- ការវិភាគលើសង្គម និងសេដ្ឋកិច្ច នៃសហគមន៍ជនបទ និងសហគ្រាសកសិកម្ម

៧- ការសិក្សាស្រាវជ្រាវ លើការត្រួតពិនិត្យ និងគ្រប់គ្រងសត្វល្អិតចង្រៃ

៨- ការសិក្សាស្រាវជ្រាវ លើកសិ-វិស្វកម្ម និងបច្ចេកវិទ្យាក្រោយពេលប្រមូលផល

៩- ការសិក្សាស្រវជ្រាវ លើការគ្រប់គ្រងកសិដ្ឋាន និងប្រព័ន្ធកសិដ្ឋានរួម

១០- ការបង្កើតនូវគោលនយោបាយផ្សព្វផ្សាយ និងបទបញ្ញាតិ ក្នុងវិស័យកសិកម្ម

១១- ការអភិវឌ្ឍន៍នូវប្រព័ន្ធកសិដ្ឋាន

១២- ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដោយមានការចូលរួម ( ការបណ្តុះបណ្តាលគ្រូបង្គោល (ToT) ការបណ្តុះបណ្តាលគ្រូបង្គោលជាកសិករ (FToT), សាលារៀនកសិករនៅកសិដ្ឋាន (FFSs) ការធ្វើ

ការងារនៅមូលដ្ឋាន និងការបង្ហាញនៅមូលដ្ឋាន ការគ្រប់គ្រងទឹកនៅកសិដ្ឋាន ដោយមានការចូលរួម ដូចជាគោលគំនិតរបស់ការអភិវឌ្ឍន៏ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម

១៣- ការគ្រប់គ្រងទឹកនៅមូលដ្ឋាន ដោយមានការចូលរួម (PIMD Concept)

១៤- ការបង្កើតនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកផ្សព្វផ្សាយ សំរាប់កសិកម្ម និងទឹក

១៥- ការបង្កើតនូវប្រព័ន្ធផ្សព្វផ្សាយពតិមាន និង

១៦- ការវិភាគលើ កសិ-បរិស្ថាន (រួមទាំងសំរាប់ការស្រោចស្រព និង ដី ផង)

១៧- បង្កើតនូវអង្គការកសិករ (សហគមន៏កសិករ) សហគមន៏កសិករប្រើប្រាស់ទឹក FWUCs..)

១៨- ការអភិវឌ្ឍន៏ធនធានមនុស្សក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម រួមទាំងសញ្ញាប័ត្រផ្នែកកសិកម្ម និងធនធានទឹកផង ។

១៩- កម្មវិធីបណ្តុះបណ្តល ស្តីពីការគ្រប់គ្រងកសិកម្ម និងទឹក និង

២០- ការបណ្តុះបណ្តាលកសិករ ស្តីពីការគ្រប់គ្រងកសិកម្ម និងទឹក (ស្របតាមគំរូ សាលារៀនកសិករនៅកសិដ្ឋាន) ។

### ៦.៥.៥_ មធ្យោបាយ និង ការទទួលខុសត្រូវ ចំពោះការអនុវត្តន៍

ចាំបាច់ត្រូវមានសកម្មភាពសំខាន់ៗ សំរាប់អនុវត្តន៏នូវគោលបំណងទាំងបួននេះ ។ សកម្មភាពទាំងនេះទាញចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ និងចេញពីឯកសារព្រាងផ្សេងៗ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។ ក្នុងដំណាក់កាលបន្ទាប់ នៃកិច្ចដំណើរការនេះ សកម្មភាពទាំងនេះ នឹងត្រូវបានពិនិត្យ និងកែតំរូវឡើងវិញ និង បញ្ជាក់ច្បាស់ថែមទៀត ក្នុងឯកសាររៀបចំកម្មវិធី (លក្ខខ័ណ្ឌការងារ ក្នុងឧបសម្ព័ន្ធ ៣) ។

## ៧_ ធនធានដែលត្រូវការ (តំរូវការធនធាន)

ធនធានដែលត្រូវការក្នុងការអនុវត្តន៏នូវយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹកនេះ គឺវាខុសគ្នាពីធនធានដែលត្រូវការក្នុងការគ្រប់គ្រងកសិកម្ម និងធនធានទឹកនោះផ្ទាល់ ។ ការអនុវត្តន៏នូវយុទ្ធសាស្ត្រនេះ ទាមទារជាពិសេស នូវធនធានមនុស្ស សមត្ថភាពគ្រប់គ្រង ឬ រដ្ឋបាល ក្នុងភ្នាក់ងារដែលពាក់ព័ន្ធ មធ្យោបាយ និង ហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានពតិមាន ឬ ចំណេះដឹង ដែលកត្តាទាំងអស់នោះ ទាមទារឱ្យមានថវិកា ក្នុងការចំណាយទៅលើវា ។ ការទទួលបាននូវថវិកាទាំងនោះ គឺអាស្រ័យទៅលើទំនុកចិត្តរបស់អ្នកពាក់ព័ន្ធ ដែលថាតើគេនឹងទទួលបាននូវផលប្រយោជន៏ពីយុទ្ធសាស្ត្រនេះ ឬអត់ ។ នៅពេលបច្ចុប្បន្ននេះ ដូចបានបង្ហាញក្នុងការវិភាគ

លើអ្នកពាក់ព័ន្ធ ក្នុងឯកសាររៀបចំយុទ្ធសាស្ត្រ (Strategy Profile) បានបង្ហាញថា អ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេស ការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជា អ្នកតំណាងដៃគូរអភិវឌ្ឍន៍ខាងក្រៅ និងកសិករ មានទំនុកចិត្តនេះ ហើយមានទឹកចិត្ត ក្នុងការដាក់ធនធានក្នុងវិស័យកសិកម្ម និងទឹក ។

ធនធានហិរញ្ញវត្ថុ គឺថវិកា ដែលចាំបាច់ក្នុងការអនុវត្តន៍នូវយុទ្ធសាស្ត្រនេះ នឹងត្រូវកំណត់ក្នុងដំណាក់កាលរៀបចំកម្មវិធី ។ ទោះជាយ៉ាងណាក៏ដោយ ទោះបីជានៅក្នុងដំណាក់កាលដំបូងនៃរយៈពេលធ្វើផែនការ ឆ្នាំ ២០០៦-២០១០ មានធនធានជាច្រើនដែលបាន សន្យាដោយអ្នកពាក់ព័ន្ធសំខាន់ៗ ដែលករណីនេះ អាចឱ្យយើងលើកឡើងនូវអ្វីដែលអាចជាឧបស័គ្គក្នុងការអនុវត្តន៍ជាក់ស្តែងនោះ ។

ទំហំនៃធនធានហិរញ្ញវត្ថុ ដែលត្រូវការចាំបាច់ គឺបានត្រូវប៉ាន់ស្មានប្រហែល ៣៥០លាន ដុល្លារអាមេរិក សំរាប់កម្មវិធីក្នុងផ្នែកទាំង ៤ (តារាង ៧.១) ។ ដូចបានកំណត់សំគាល់ ក្នុងចំណុច ២.១ ភ្នាក់ងាររបស់រាជរដ្ឋាភិបាលកម្ពុជាផ្សេងៗទៀត ក៏មានការពាក់ព័ន្ធក្នុងសកម្មភាព ដែលទាក់ទងនឹងវិស័យកសិកម្ម និងទឹកដែរ ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ។ល។) និង ការគ្រប់គ្រងដីធ្លី ។ ថវិការបស់គេ សំរាប់សកម្មភាពទាំងនោះ នឹងជួយដល់ការអនុវត្តន៍នូវយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ប៉ុន្តែក្នុងដំណាក់កាលនេះ វាមិនត្រូវបានរាប់បញ្ចូលជាផ្លូវការ ក្នុងថវិការបស់យុទ្ធសាស្ត្រនេះទេ ។ ប្រការនេះ វានឹងឃើញជាក់ស្តែង នៅពេលដែលយុទ្ធសាស្ត្រនេះត្រូវបានអនុវត្តន៍ជាបណ្តើរៗនោះ ជាពិសេស ក្នុងដំណាក់កាលធ្វើផែនការវិនិយោគក្នុងកំលុងឆ្នាំ ២០០៦-២០១០ នេះ ។

មិនមានមូលហេតុច្បាស់លាស់ទេថា ហេតុអ្វីទឹកប្រាក់ ៣៥០លាន ដុល្លារអាមេរិច ទាំងមូលនេះ ត្រូវតែបានមកពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅនោះ ។ ផលប្រយោជន៍ជាច្រើននៃយុទ្ធសាស្ត្រ អាចចាត់ទុកជាកិត្តិយស ឬ ជារបស់សាធារណៈ ដែលរដ្ឋាភិបាលត្រូវតែចំណាយលើវា ។ កត្តាទាំងនេះ រួមមានដូចជា ផលប្រយោជន៍ផ្នែកសង្គមសំរាប់ប្រទេសជាតិទាំងមូល ចំពោះសន្តិសុខស្បៀងសំរាប់គ្រួសារក្រីក្រ ការថែរក្សានូវធនធានទឹកដែលអាចខូចខាត ដោយសារការធ្វើអាជីវកម្មដោយមិនមានការត្រួតពិនិត្យ ឬ ការផ្តល់នូវពត៌មានថ្នាក់ជាតិ ស្តីពីដីដាំដំណាំ និងធនធានដី ដែលពុំមានផ្នែកឯកជនណាអាចប្រមូលបាននោះ ។ ម្យ៉ាងវិញទៀត លទ្ធផលជាច្រើនរបស់យុទ្ធសាស្ត្រនេះ អាចចាត់ទុកជារបស់សាធារណៈ ដែលអ្នកទទួលផលផ្ទាល់ អាចត្រូវបានកំណត់ ហើយថា អ្នកណាដែលគួរចំណាយប្រាក់សំរាប់ករណីនេះ ។ ករណីនេះ រួមមានដូចជា សេវាកម្មផ្ទេរនូវបច្ចេកវិជ្ជា និងការផ្សព្វផ្សាយនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ឬ ពត៌មានទីផ្សារសំរាប់ផលិតផល ។ នៅពេលបច្ចុប្បន្ននេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺថា តំលៃចំពោះការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រត្រូវផ្ទេរជាបណ្តើរៗទៅអ្នកទទួលផល ។ ដូចនេះ វាមានបញ្ហាជាច្រើនដែលត្រូវពិចារណា ដូចជា ប្រភពទុនដែលសមស្រប ក្នុងការផ្តល់នូវទំនិញឯកជន និងសាធារណៈ តំលៃសមស្រប ចំពោះទំនិញនិមួយៗ អត្រានៃតំលៃ ដែលអាចផ្ទេរ

ពីរដ្ឋាភិបាលទៅអ្នកទទួលផល និងកត្តាផ្សេងៗទៀត ។ ប្រការនេះ គឺត្រូវពិចារណាក្នុងក៏រិតនៃការសំរេចចិត្ត ផ្នែកនយោបាយ ហើយនឹងត្រូវការពិភាក្សាបន្ថែមទៀត ក្នុងដំណាក់កាលរៀបចំកម្មវិធី និងក្នុងពេលក្រោយៗទៀត ។

**តារាង ៧.១**_តារាងតំលៃសំខាន់នៃកម្មវិធី សំរាប់ឆ្នាំ ២០០៦-២០១០

| កម្មវិធី | តំលៃសរុប (លានដុល្លារ) |
| --- | --- |
| ១-កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងសំរាប់វិស័យកសិកម្ម និងធនធានទឹក | ៥០ |
| ២-កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង | ៥០ |
| ៣-កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ) | ១០០ |
| ៤- កម្មវិធីធនធានទឹក ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងដី | ១០០ |
| ៥-កម្មវិធីសិក្សាស្រាវជ្រាវកសិកម្ម និងធនធានទឹក អប់រំ និងផ្សព្វផ្សាយ | ៥០ |
| **សរុប** | **៣៥០** |

ធនធានហិរញ្ញវត្ថុ សំរាប់អនុវត្តន៍ នូវយុទ្ធសាស្ត្រត្រូវបានរំពឹងថា នឹងបានមកពីថវិកាជាតិ (រាជរដ្ឋាភិបាលកម្ពុជា) និងពីជំនួយអភិវឌ្ឍន៍ជាផ្លូវការដែលផ្តល់ដោយដៃគូរអភិវឌ្ឍន៍ខាងក្រៅ ។ អង្គការក្រៅរដ្ឋាភិបាល ត្រូវបានរំពឹងថា នឹងផ្តល់ក្នុងចំនួនតិចតួច ប៉ុន្តែទោះ ជាយ៉ាងណាក៏ដោយ ធនធានហិរញ្ញវត្ថុសំខាន់ៗ សំរាប់ការអភិវឌ្ឍន៍ជនបទ ត្រូវបានប្រើ ជាពិសេស សំរាប់ការកាត់បន្ថយភាពក្រីក្រ ក្នុងសហគមន៍ដែលក្រីក្របំផុត ។ គោលបំណងសំខាន់របស់យុទ្ធសាស្ត្រ គឺដើម្បីជំរុញដល់ការវិនិយោគដោយផ្នែកឯកជន និងកសិករខ្លួនឯងផ្ទាល់ ។ ទោះជាយ៉ាងនេះក្តី ការវិនិយោគនោះ នឹងជាលទ្ធផលនៃយុទ្ធសាស្ត្រ ជាងជាង ជាធនធាន ហើយ (ការវិនិយោគរបស់អង្គការមិនមែនរដ្ឋាភិបាល) វាហួសពីក្របខ័ណ្ឌគ្រប់គ្រងរបស់ភ្នាក់ងារ ដែលទទួលខុសត្រូវក្នុងការអនុវត្តន៍ ។

## ៨_ ការត្រួតពិនិត្យ និង វាយតំលៃ

ផ្នែកសំខាន់នៃយុទ្ធសាស្ត្រ និងការអនុវត្តន៍កម្មវិធីនោះ គឺការត្រួតពិនិត្យតាមដាននូវលទ្ធផលដែលសំរេចបាន ចំពោះគោលដៅ ឬ សូចនាករដែលបានកំណត់ ។ ចំណុច ១.២ ពិភាក្សាលើសូចនាករនៃជោគជ័យ ដែលបង្កើតឡើងដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលទាក់ទងទៅនឹងយុទ្ធសាស្ត្រ សំរាប់វិស័យកសិកម្ម និងទឹក ។ ដោយសារ សូចនាកររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានកំរិតខ្ពស់ (តារាង ១.១.) សូចនាករនៃលទ្ធផលពាក់កណ្តាលការអនុវត្តន៍ (Mid-term) និងសូចនាករលទ្ធផលចុងរយៈកាល (ឆ្នាំ២០១០) ដែលមានរៀបរាប់ក្នុងឯកសារបន្ថែម ៣ នឹងជាកត្តាសំខាន់ សំរាប់ត្រួតពិនិត្យ និងវាយតំលៃ លើការអនុវត្តន៍យុទ្ធសាស្ត្រ ។

ក្របខ័ណ្ឌត្រួតពិនិត្យ របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបង្កើតឡើងដោយក្រសួងផែនការ ផ្តល់នូវបរិបទមួយ សំរាប់ត្រួតពិនិត្យលើយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ។ ក្របខ័ណ្ឌត្រួតពិនិត្យ

នោះ បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជានឹង (i)-រៀបចំនូវរបាយការណ៍នៃកិច្ចដំណើរការ ស្តីពីការអនុវត្តន៏នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ និង (ii)-ធ្វើការត្រួតពិនិត្យឡើងវិញ ដោយល្អិតល្អន់ ក្នុងដំណាច់ឆ្នាំ ២០០៩ លើកិច្ចដំណើរការ ក្នុងការសំរេចបាននូវគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ។ ត្រូវមានការយកចិត្តទុកដាក់ លើការវាយតំលៃលើកិច្ចដំណើរការ ក្នុងការសំរេចបាននូវសូចនាករសំខាន់ៗ ដែលបានជ្រើសរើស ការចាត់ចែង ចំពោះការបែងចែកថវិកា និងការវិនិយោគរបស់ដៃគូរអភិវឌ្ឍន៏ខាងក្រៅ តាមអាទិភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ និងសំណើក្នុងការកែតំរូវចំពោះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ដែលជាភ្នាក់ងារដឹកនាំក្នុងវិស័យនេះ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការត្រួតពិនិត្យលើការអនុវត្តន៏យុទ្ធសាស្ត្រ និងផ្តល់នូវពត៌មានដែលក្រសួងផែនការត្រូវការ ដើម្បីរៀបចំរបាយការណ៏របស់គេ ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ។ ក្នុងន័យនេះ នាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងធនធានទឹក និងឧតុនិយម មានភារៈកិច្ចប្រមូលនូវទិន្នន័យ សំរាប់គោលបំណងត្រួតពិនិត្យ ។ ជាការពិតហើយ ថ្នាក់គ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម នឹងប្រើប្រាស់នូវទិន្នន័យទាំងនេះ សំរាប់ការត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុងរបស់ខ្លួន ដោយអនុវត្តន៏តាមនីតិវិធីដែលធ្លាប់អនុវត្តន៏ ។ គេគួរកត់សំគាល់ថា នីតិវិធីក្នុងការត្រួតពិនិត្យ និងវាយតំលៃដ៏ល្អនោះ គឺជាគោលបំណងមួយ នៅក្នុងផ្នែកនៃកម្មវិធីជាច្រើន ។

រហូតមកដល់ពេលនេះ ដោយសារការអនុវត្តន៏ ត្រូវការប្រើប្រាស់នូវទុន ដែលទទួលបានពីដៃគូរអភិវឌ្ឍន៏ខាងក្រៅនោះ ការត្រួតពិនត្យលើការអនុវត្តន៏ នឹងត្រូវធ្វើតាមនីតិវិធីដែលធ្លាប់អនុវត្តន៏ ដែលបង្កើតឡើងដោយដៃគូរអភិវឌ្ឍន៏ខាងក្រៅ ដែលពាក់ព័ន្ធ ។ ករណីនេះ វាឃើញជាក់ស្តែង ជាពិសេស ក្នុងការចំណាយ លើការផ្តល់នូវសេវាប្រឹក្សា ទិញឧបករណ៏ សាងសង់សំណង់វិស្វកម្មផ្សេងៗ ។ល ។

ការត្រួតពិនិត្យលើការអនុវត្តន៏ លើសូចនាករ ដែលមានក្នុងឯកសារបន្ថែម ៣ នឹងជួយឱ្យសមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក រួមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម រៀនសូត្រពីកិច្ចដំណើរការក្នុងរយៈពេលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ បច្ចុប្បន្ន ជាពិសេសទាក់ទងទៅនឹងឧបស័គ្គ ដែលរារាំងដល់កិច្ចដំណើរការ ។ មេរៀននោះ នឹងចាំបាច់ត្រូវកែតំរូវនូវយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០១១-២០១៥ និង ដើម្បីបែងចែកធនធាន ទៅលើផ្នែកដែលមានអាទិភាព ។ ការអនុវត្តន៏ នូវយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក នឹងទទូលនូវឥទ្ធិពលយ៉ាងខ្លាំង ពីកិច្ចដំណើរការ ក្នុងសកម្មភាពនៃផ្នែកផ្សេងៗទៀត ជាពិសេស ការអនុវត្តន៏នូវការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ដូចនេះ ការត្រួតពិនិត្យលើកិច្ចដំណើរការក្នុងយុទ្ធសាស្ត្រនេះ នឹងតំរូវឱ្យមាន ការគិតគូរផងដែរដល់ព្រឹត្តិការណ៏ក្នុងផ្នែកផ្សេងៗទៀត ។

# ឧបសម្ព័ន្ធ ១

## ឯកសារយោង

### ឯកសារយោងសំខាន់ៗ

ក្រុមយុទ្ធសាស្ត្រ ដែលត្រូវបានប្រគល់ភារៈកិច្ចឱ្យក្នុងការរៀបចំពង្រាងយុទ្ធសាស្ត្រជាតិ សំរាប់វិស័យកសិកម្ម និងទឹក សំរាប់ប្រទេសកម្ពុជានោះ បានផ្អែកជាពិសេស លើឯកសារ ដូចខាងក្រោម ក្នុងការរៀបចំនូវយុទ្ធសាស្ត្រនេះ ។ ជាមួយគ្នានោះដែរ ឯកសារដែលទាក់ទងនឹងគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនទៀត ក៏ត្រូវបានពិនិត្យ តាមរយៈឯកសារដែលបានរៀបរាប់ទាំងនេះដែរ ។ ឯកសារយោងសំខាន់ៗ សំរាប់ដំណើរការរៀបចំយុទ្ធសាស្ត្រនេះ ជាទូទៅ ត្រូវបានចងក្រងក្នុងឯកសាររៀបចំយុទ្ធសាស្ត្រ សំរាប់យុទ្ធសាស្ត្ររយៈពេលមធ្យម ក្នុងវិស័យកសិកម្ម និងទឹក (Strategic Profiles for development of a medium term Strategy for agriculture and water sectors- ឯកសារ C ២ ខាងក្រោម) ដែលប្រមូលផ្តុំនូវឯកសារយោងជាច្រើន ជាជំនួយក្នុងការបង្កើតនូវយុទ្ធសាស្ត្រទាំងនេះ ។

### A-ឯកសារយោង ស្តីពីស្ថានភាពរួមរបស់ជាតិ

១-យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ខែមិថុនា ឆ្នាំ ២០០៤ ។

២-គោលដៅអភិវឌ្ឍន៍សហសវត្ស របស់ប្រទេសកម្ពុជា រហូតដល់ឆ្នាំ ២០១៥ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា ខែឧសភា ឆ្នាំ ២០០៣ ។

៣-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ ក្រុមប្រឹក្សារដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា ខែមករា ឆ្នាំ ២០០៦ ។

៤-ក្របខ័ណ្ឌត្រួតពិនិត្យរបស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា ខែឧសភា ឆ្នាំ ២០០៦ ។

៥-កម្ពុជា: ការកាត់បន្ថយភាពក្រីក្រពាក់កណ្តាល នៅឆ្នាំ ២០១៥ ? ការវាយតំលៃលើភាពក្រីក្រ ឆ្នាំ ២០០៦ ធនាគារពិភពលោក ខែកុម្ភៈ ឆ្នាំ ២០០៦ ។

៦-យុទ្ធសាស្ត្រជាតិ សំរាប់កាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម រាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ ២០០២ ។

៧-វេទិកាសេដ្ឋកិច្ចនៃកម្ពុជា: ការវិភាគលើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT) នៃសេដ្ឋកិច្ចកម្ពុជា ក្រុមប្រឹក្សាសេដ្ឋកិច្ចជាន់ខ្ពស់ (ខែមករា ឆ្នាំ ២០០៥) ។

៨-ផែនការសកម្មភាព សំរាប់ស្ថាប័នភាវូបនីយកម្ម (Institutionalisation) នៃក្របខ័ណ្ឌចំណាយសំរាប់រយៈពេលមធ្យម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៥ ។

៩-ក្របខ័ណ្ឌជាយុទ្ធសាស្ត្រ សំរាប់ការកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា ខែមិថុនា ឆ្នាំ ២០០២ ។

១០-ទំរង់ក្របខ័ណ្ឌនៃវិមជ្ឈការ និងវិសហមជ្ឈការ សេចក្តីថ្លែងការ ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខែឧសភា ឆ្នាំ ២០០៦ ។

១១- ពង្រាង យុទ្ធសាស្ត្ររួម របស់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ សំរាប់បំបាត់នូវការអនុវត្តន៍ លើការឧបត្ថម្ភបន្ថែម ទៅលើប្រាក់បៀវត្សក្នុងប្រទេសកម្ពុជា ក្រុមការងារបច្ចេកទេសស្តីពីការកែទំរង់រដ្ឋបាល ខែធ្នូ ឆ្នាំ ២០០៥ ។

## B-ឯកសារយោង ស្តីពីវិស័យជាលក្ខណៈទូទៅ

១-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ ២០០៦-២០១០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែកញ្ញា ឆ្នាំ ២០០៥ ។

២-ពង្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឆ្នាំ ២០០៦-២០១០ ក្រសួងធនធានទឹក និងឧតុនិយម ខែឧសភា ឆ្នាំ ២០០៥ ។

៣-ការធ្វើវេទិការជាតិ ស្តីពីរចនាសម្ព័ន្ធកសិកម្ម ក្នុងបរិបទនៃការចូលក្នុងពាណិជ្ជកម្ម ក្រុមប្រឹក្សាសេដ្ឋកិច្ចជាន់ខ្ពស់ (ខែមិថុនា) ។

៤-កម្ពុជា: ពង្រាងឯកសារ ប្រភពនៃការលូតលាស់-វិស័យកសិកម្ម ធនាគារពិភពលោក (ខែវិច្ឆិកា ឆ្នាំ ២០០៥) ។

៥-គោលនយោបាយ និងយុទ្ធសាស្ត្របញ្ច្រាបយ៉ែនឌ័រ ក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភ្នំពេញ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

## C-ឯកសារយោង ក្នុងការរៀបចំយុទ្ធសាស្ត្រ

១-ឯកសារគោលគំនិត សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យម សំរាប់វិស័យកសិកម្ម និងទឹក ក្រុមយុទ្ធសាស្ត្រ B1 ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ខែមករា ឆ្នាំ ២០០៦ ។

២-ឯកសារវិភាគសំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមសំរាប់វិស័យកសិកម្ម និងទឹក (ឆ្នាំ ២០០៦-២០១០) ក្រុមយុទ្ធសាស្ត្រ ៣១ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ខែមេសា ឆ្នាំ ២០០៦ ។

៣-ឯកសាររៀបចំយុទ្ធសាស្ត្រ I ។ ជំរើស និងរចនាសម្ព័ន្ធសំរាប់ រៀបចំយុទ្ធសាស្ត្រ រយៈពេលមធ្យម សំរាប់វិស័យ កសិកម្ម និងទឹក ក្រុមយុទ្ធសាស្ត្រ នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ខែមករា ឆ្នាំ ២០០៦ ។

៤-ការធ្វើសិក្ខាសាលារបស់ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ស្តីពីការរៀបចំយុទ្ធសាស្ត្រ ខែសភា ឆ្នាំ ២០០៦ ។

៥-(ពង្រាង) ឯកសារគោលគំនិតយុទ្ធសាស្ត្រ សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យម សំរាប់វិស័យ កសិកម្ម និងទឹក (ឆ្នាំ ២០០៦-២០១០) ក្រុមយុទ្ធសាស្ត្រ នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ខែមិថុនា ឆ្នាំ ២០០៦ ។

៦-ឯកសារគោលគំនិតយុទ្ធសាស្ត្រៈ ក្រុមយុទ្ធសាស្ត្រ នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ខែមិថុនា ឆ្នាំ ២០០៦ ។

## D-ឯកសារយោង ស្តីពីកម្មវិធីគ្រប់គ្រងទឹក ប្រព័ន្ធស្រោចស្រព និង ដីធ្លី

១-គោលនយោបាយស្តីពីធនធានទឹកជាតិ ខែមករា ឆ្នាំ ២០០៤ ក្រុមប្រឹក្សារដ្ឋមន្ត្រី រាជរដ្ឋាភិបាល កម្ពុជា។

២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ សំរាប់វិស័យធនធានទឹក ឆ្នាំ២០០៦-២០១០ ក្រសួងធនធានទឹក និងឧតុនិយម ខែធ្នូ ឆ្នាំ ២០០៥ ។

៣-យុទ្ធសាស្ត្រ នៃក្របខ័ណ្ឌគោលនយោបាយដីធ្លី ក្រុមប្រឹក្សាស្តីពីគោលនយោបាយដីធ្លី រាជរដ្ឋាភិបាល កម្ពុជា ខែកញ្ញា ឆ្នាំ ២០០២ ។

៤-ការសិក្សាលើរចនាសម្ព័ន្ធកសិកម្ម ធនាគារពិភពលោក ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា និង Gesellschaft Technische Zusammenarbeit ខែ សីហា ឆ្នាំ ២០០៥ ។

៥-ភាពក្រីក្រនៅជនបទប្រទេសកម្ពុជាៈ ពង្រាង ផលប៉ះពាល់នៃការបែងចែងដីធ្លី និងគោលនយោបាយ នានា ធានាគារពិភពលោក ខែវិច្ឆិកា ឆ្នាំ ២០០៣ ។

៦-កសិដ្ឋានខ្នាតតូច គឺមានប្រសិទ្ធិភាព និងមានលក្ខណនិរន្តរភាពជាង ដោយអ្នកត្រួតពិនិត្យ ច្រើនជាតិសាសន៍ ខែកក្កដា/សីហា ឆ្នាំ ២០០០ ។

## E- ឯកសារយោង ស្តីពីកម្មវិធីកសិកម្ម និង កសិ-ធុរកិច្ច

១-ឯកសារសិក្សាស្វែងយល់ចុងក្រោយ ដោយក្រុមជំនាញផ្នែកកសិ-អាហារអន្តរជាតិ សំរាប់ AusAID ខែមិថុនា ឆ្នាំ ២០០៦ ។

២-ផែនការក្នុងវិស័យហិរញ្ញវត្ថុ សំរាប់ឆ្នាំ ២០០១-២០១០ ធនាគារអភិវឌ្ឍន៍អាស៊ី ខែធ្នូ ឆ្នាំ ២០០១ ។

៣-ការផ្តល់ហិរញ្ញវត្ថុទៅសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជាៈ ហេតុអ្វីបានជាធនាគារនានា មានការ ពិបាក ? ដោយ MPDF ខែមេសា ឆ្នាំ ២០០៦ ។

៤-ការបង្កើតនូវទីផ្សារស្រូវដោយចំហរ ក្នុងប្រទេសកម្ពុជា សមិទ្ធិសិក្សា ដោយ JICA ខែសីហា ឆ្នាំ ២០០៦ ។

៥-សេវាកម្មអភិវឌ្ឍន៍អាជីវកម្មសំរាប់សហគ្រាសខ្នាតតូច គោលការណ៍ណែនាំ សំរាប់កិច្ចអន្តរាគំន៍ របស់អ្នកផ្តល់ជំនួយ ដោយគណៈកម្មការនៃភ្នាក់ងារអ្នកផ្តល់ជំនួយ សំរាប់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ធនាគារពិភពលោក វ៉ាស៊ីនតោន ខែកុម្ភៈ ឆ្នាំ ២០០១ ។

៦-ឯកសារស្តីពីការបង្កើត និងកិច្ចដំណើរការ នៃសហករណ៍កសិកម្ម សមាគមនៃសហករណ៍កសិកម្ម និងសហករណ៍មុនការធ្វើកសិកម្ម (Pre-agricultural Cooperative) ព្រះរាជក្រឹត្យ ខែកក្កដា ឆ្នាំ ២០០១ ។

៧-បញ្ជីឈ្មោះអង្គការកសិករ ក្នុងប្រទេសកម្ពុជា ដោយ AFD ខែកុម្ភៈ ឆ្នាំ ២០០៦ ។

៨-ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

៩-ពង្រាង គោលនយោបាយ ស្តីពីទីផ្សារផលិតផលផ្លែឈើ និង បន្លែ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ ២០០៣ ។

## F- **ឯកសារយោង ស្តីពីកម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយកសិកម្ម និងទឹក**

១-កម្ពុជាៈ ផែនការមេ សំរាប់ការសិក្សាស្រាវជ្រាវកសិកម្មជាតិ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ខែមករា ឆ្នាំ ២០០៦) ។

២-របាយការណ៍ឯករាជ្យ សំរាប់គំរោងកសិកម្មកម្ពុជា-អូស្រ្តាលី (CAAEP) ដោយ AusAID ខែសីហា ឆ្នាំ ២០០៦ ។

៣-ការពិនិត្យឡើងវិញលើការបញ្ចប់គំរោង របស់គំរោងជំនួយដល់ CARDI ដោយ AusAID ខែ កញ្ញា ឆ្នាំ ២០០៦ ។

៤-គោលនយោបាយជាតិស្តីពីកាសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ១៩៩៩ ។

៥-មូលនិធិសំរាប់សិក្សាស្រាវជ្រាវកសិកម្មកម្ពុជា របាយការណ៍ត្រួតពិនិត្យ ដោយ ACIAR ខែមិថុនា ឆ្នាំ ២០០៦ ។

## G-**ឯកសារយោង ស្តីពីកម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រង**

១-រចនាសម្ព័ន្ធក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមុខងាររបស់គោលនយោបាយ និងការធ្វើផែនការ ឯកសារពិភាក្សា ដោយជំនួយបច្ចេកទេស ធនាគារអភិវឌ្ឍន៍អាស៊ី ខែកុម្ភៈ ឆ្នាំ ២០០៦ ។

២-ការរៀបចំ និងកិច្ចដំណើរការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុក្រឹត្យលេខ ១៧ ខែមេសា ឆ្នាំ ២០០០ ។

៣-ការលំបាកដែលមានក្នុងអង្គភាពអនុវត្តនីគំរោង (PIU) ឯកសារអនុវត្តនី ដោយ UNDP ខែ កញ្ញា ឆ្នាំ ២០០៣ ។

## I-ឯកសារយោង ស្តីពីកម្មវិធីសន្តិសុខស្បៀង

១-សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយ CARD រាជរដ្ឋាភិបាលកម្ពុជា ខែមិថុនា ឆ្នាំ ២០០៣ ។

២-ផែនការវិនិយោគលើអាហារូបត្ថម្ភ នៅកម្ពុជា ឆ្នាំ ២០០២-២០០៧ ដោយ ក្រសួងផែនការ ខែមិថុនា ឆ្នាំ ២០០២ ។

៣-ក្របខ័ណ្ឌជាតិរយៈពេលមធ្យម របស់ FAO ឆ្នាំ ២០០៦-២០១០ ខែមិថុនា ឆ្នាំ ២០០៦ ។

៤-កម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ (NPHFSPR) ឆ្នាំ ២០០៧-២០១១ ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ FAO និង UNDP ខែមិថុនា ឆ្នាំ ២០០៦ ។

# ឧបសម្ព័ន្ធ ២

## គោលដៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## និង ក្រសួងធនធានទឹក និងឧតុនិយម

(តាមឯកសារ រៀបចំយុទ្ធសាស្ត្រ I)

## គោលដៅអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម

គោលដៅរួមសំរាប់អភិវឌ្ឍន៍ ក្នុងស័យកសិកម្ម គឺដើម្បីធានានូវសន្តិសុខស្បៀង បង្កើនចំណូល បង្កើនការងារ និងបង្កើនអាហាររូបត្ថម្ភ សំរាប់ប្រជាជនគ្រប់រូប ដោយបង្កើននូវផលិតភាព ពិពិធកម្ម និងធ្វើពាណិជ្ជកម្មក្នុងវិស័យកសិកម្ម ប្រកបដោយការការពារបរិស្ថានល្អ និងមានសុវត្ថិភាពស្បៀងអាហារ ។ ដើម្បីសំរេចបាននូវគោលដៅចំបងក្នុងវិស័យនេះ គឺត្រូវផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រក្នុងផ្នែកដូចខាងក្រោមនេះ :

**I- បង្កើននូវសន្តិសុខស្បៀង ផលិតភាព និង ពិពិធកម្ម**

១- ធានានូវសន្តិសុខស្បៀង សំរាប់ប្រជាជនគ្រប់រូប បង្កើនចំណូល និងបង្កើនជីវភាពរស់នៅ សំរាប់ប្រជាជនក្រីក្រនៅតាមជនបទ តាមរយៈការបង្កើននូវផលិតភាព និង ពិពិធកម្មកសិកម្ម និង

២- ផ្តល់លទ្ធភាពឱ្យគ្រួសារដែលមានអសន្តិសុខស្បៀង ក្នុងការបង្កើននូវស្បៀងអាហារ តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វរបស់គេផ្ទាល់ ជលផល និងព្រៃឈើដែលជាកម្មសិទ្ធសមូហភាព។

**II- បង្កើន និង ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និង ស្រាវជ្រាវកសិកម្ម**

១- បង្កើនការស្រាវជ្រាវ លើបច្ចេកទេសកសិកម្ម និង កម្មវិធីស្រាវជ្រាវសំខាន់ៗ ដោយយកចិត្តទុកដាក់ដល់បច្ចេកទេស ដែលបានបង្កើតឡើងក្នុងតំបន់ និងក្នុងពិភពលោកទាំងមូល និងធ្វើការស្រាវជ្រាវលើសេដ្ឋកិច្ចទីផ្សារសេរី

២- ពង្រឹង និងបង្កើនសមត្ថភាពស្រាវជ្រាវបច្ចេកទេសអភិវឌ្ឍន៍ និងការបង្កើតថ្មី តាមរយៈការសិក្សាផ្លាស់ប្តូរបច្ចេកវិទ្យា ផ្ទេរនូវបច្ចេកវិទ្យា និងការអនុវត្តន៍នូវបច្ចេកទេសកសិកម្មល្អ (Good Agriculture Practices) ដើម្បីធានានូវគុណភាព និងសុវត្ថិភាពរបស់ផលិតផលកសិកម្ម ។

៣- ពង្រឹង និងបង្កើននូវការផ្លាស់ប្តូរបច្ចេកវិទ្យា និងបទពិសោធន៍ ក្នុងចំណោមអ្នកពាក់ព័ន្ធ (អ្នកស្រាវជ្រាវ មន្ត្រីផ្សព្វផ្សាយ និងកសិករ) តាមរយៈសិក្ខាសាលា ទស្សនៈកិច្ចសិក្សា ការបង្ហាញនៅមូលដ្ឋានផ្ទាល់ និងការធ្វើការងារនៅមូលដ្ឋាន និង

៤- ពង្រឹង និងបង្កើនសេវាកម្មផ្សព្វផ្សាយកសិកម្ម ដើម្បីជំរុញដល់ការអនុវត្តន៍នូវបច្ចេកវិជ្ជាល្អៗ ក្នុងផលិតកម្មកសិកម្ម (ដូចជា ជីវ-បច្ចេកទេស- biotechnologies) ប្រសិទ្ធភាពតំលៃ និង

ការអនុវត្តន៍នូវប្រពលវប្បកម្ម និង ពិពិធកម្មកសិកម្ម ដែលមានលក្ខណៈបរិស្ថានល្អ និងការអនុវត្តន៍នូវបច្ចេកទេសថែរក្សាកសិកម្ម និងកសិកម្មដោយប្រើ ជីសរីរាង្គ (organic farming) ។

**III- ទីផ្សារសំរាប់ផលិតផលកសិកម្ម**

១- បង្កើនទីផ្សារ និងការចូលទៅដល់ទីផ្សារនូវផលិតផលកសិកម្ម ដើម្បីធានាបាននូវកាលូតលាស់សេដ្ឋកិច្ច ប្រកបដោយនិរន្តរភាព និងការងារសំរាប់កសិករនៅតាមជនបទ និង

២- បង្កើនបទដ្ឋានសុវត្ថិភាពកសិកម្ម ។

**IV- ការកែទំរង់ដីធ្លី (ដើម្បីធានាដល់កម្មសិទ្ធដីធ្លី និង ទីផ្សារដីធ្លីដ៏មានប្រសិទ្ធិភាព)**

១- ធានាដល់ការប្រើប្រាស់ដីរបស់កសិករក្រីក្រនៅជនបទ ដោយកាត់បន្ថយនូវជំលោះដីធ្លី និងបង្កើននូវសុវត្ថិភាពកម្មសិទ្ធដី និងទីផ្សារដីធ្លី

២- ធានាដល់ការប្រើប្រាស់ដី ប្រកបដោយប្រសិទ្ធិភាព សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និង

៣- ធានាដល់ការការពារ និងប្រើប្រាស់នូវធនធានដី ប្រកបដោយប្រសិទ្ធិភាព ។

**V- ការប្រើប្រាស់ដីដែលមានប្រយោជន៍ដល់អ្នកក្រីក្រ**

១- បង្កើននូវលទ្ធភាពសំរាប់គ្រួសារគ្រីក្រ ឱ្យមានដីសំរាប់លំនៅដ្ឋាន និងកសិកម្មសំរាប់គ្រួសារ តាមរយៈការអនុវត្តន៍នូវកម្មវិធីសម្បទានដីធ្លីសង្គម និងកម្មវិធីបោសសំអាតមីន និងជួយដល់អ្នករងគ្រោះ ។

២- បង្កើនការគ្រប់គ្រងដីធ្លីរបស់រដ្ឋ

៣- ធានាដល់ការប្រើប្រាស់ដីធ្លីរបស់គ្រួសារក្រីក្រនៅជនបទ សំរាប់រៀបចំផលិតផល ក្នុងការបង្កើននូវកសិ-ឧស្សាហកម្ម និងការធ្វើពាណិជ្ជកម្ម និង

៤- ធានានូវសុវត្ថិភាពកម្មសិទ្ធដី សំរាប់គ្រួសារក្រីក្រនៅតំបន់ជនបទ ។

## គោលដៅអភិវឌ្ឍន៍ក្នុងវិស័យទឹក

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់នូវគោលដៅសំខាន់ៗចំនួនប្រាំ ។ គោលដៅសំរាប់គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកនោះ គឺថា ធនធានទឹករបស់ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រង និងអភិវឌ្ឍន៍ក្នុងលក្ខណៈមួយ ប្រកបដោយប្រសិទ្ធិភាព មានសមភាព និងមាននិរន្តរភាព ។ ប្រការនេះ វាធ្វើឱ្យសំរេចបាននូវផលប្រយោជន៍ល្អបំផុត សំរាប់ប្រជាជន ដែលទទឹមនឹងនោះ ក៏បានថែរក្សានូវប្រព័ន្ធអេកូឡូស៊ី ក្នុងទឹកផងដែរ ។

ក្នុងផ្នែកនៃការងារនេះ គោលដៅជាអាទិភាពនោះគឺ :

១- មានយុទ្ធសាស្ត្រជាតិស្តីពីប្រព័ន្ធស្រោចស្រព និងការដោះទឹក ដែលគាំទ្រដោយផែនការអាងទន្លេក្នុងអាងសំខាន់ៗ និងត្រូវបានរៀបចំឡើងដោយសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងបរិស្ថាន ដែលជួយណែនាំ ដល់ការអភិវឌ្ឍន៍រយៈពេលមធ្យម និងរយៈពេលវែង ក្នុងវិស័យនេះ ។

២- កសិករនៅតំបន់ដីដាំដុះ ដែលអាចស្រោចស្រពបាន អាចគ្រប់គ្រងទឹកបានល្អ នៅលើផ្ទៃដីដែលមានការកើនឡើង យ៉ាងហោចណាស់ ១០,000 ហិចតា ក្នុងមួយឆ្នាំ ។ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ (Hardware) (ដូចជាទ្វារទឹក និង ប្រឡាយ) និង ផ្នែកគ្រប់គ្រង (Software) (ដូចជាប្រព័ន្ធគ្រប់គ្រងល្អ ដូចជាសហគមន៍កសិករប្រើប្រាស់ទឹក-FWUC) ត្រូវបាន រៀបចំឡើងក្នុងលក្ខណៈល្អប្រសើរមួយ ។

៣- កសិករនៅតំបន់ដីដាំដុះ ដែលពឹងផ្អែកលើទឹកភ្លៀង អាចគ្រប់គ្រងទឹកបានល្អ លើផ្ទៃដីដែលមានការកើនឡើង យ៉ាងហោចណាស់ ១០,000 ហិចតាក្នុងមួយឆ្នាំ ។ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ (Hardware) (ដូចជាស្រះ ឬ ការរៀបចំដីស្រែ ក្នុងលក្ខណៈប្រសើរថែមទៀត) និងផ្នែកគ្រប់គ្រង (Software) (ដូចជាសេវាកម្មផ្សព្វផ្សាយ ផ្តល់យោបល់) ត្រូវបានរៀបចំ ឱ្យមានលក្ខណៈល្អប្រសើរ និង

៤- ប្រើប្រាស់វិធីសាស្ត្ររួម ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក ដែលគិតគូរដល់ប្រភពទឹកទាំងអស់ដែលមាន ការទាក់ទងរវាងទឹក នឹងផ្នែកផ្សេងៗទៀតនៃបរិស្ថាន ក្នុងអាង និងបែងចែកច្បាស់លាស់នូវតំរូវការរបស់មនុស្ស និងប្រព័ន្ធអេកូឡូស៊ី ចំពោះធនធានទឹក ។

# ឧបសម្ព័ន្ធ ៣
## លក្ខខណ្ឌការងារ សំរាប់ការរៀបចំកម្មវិធី
## ឯកសារសំរាប់កម្មវិធីទូទៅ

### ១. លក្ខណៈទូទៅរបស់កម្មវិធី

កម្មវិធីអភិវឌ្ឍន៍ជាតិ ដែលត្រូវបង្កើតឡើង ក្រោមលក្ខខ័ណ្ឌការងារខាងក្រោមនេះ គឺត្រូវបានហៅថា ទំរង់កម្មវិធី (Outline) ។ ពាក្យនេះ មានន័យថា កម្មវិធីទាំងនេះ ត្រូវបង្កើតឡើង តែក្នុងកំរិតលទ្ធផលតែប៉ុណ្ណោះ (ដោយអនុវត្តន៍តាមក្របខ័ណ្ឌវាក្យស័ព្ទ) សំរាប់ផ្នែកនិមួយៗ ។ ទោះជាយ៉ាងណាក៏ដោយ នៅកន្លែងណាដែលក្រុមរៀបចំកម្មវិធី (Program Design team) យល់ថា វាមានប្រយោជន៍ ឬ ជាការចាំបាច់នោះ ការរៀបចំកម្មវិធី អាចដាក់ បញ្ចូលនូវសកម្មភាពសំខាន់ៗមួយចំនួន ។

គេអាចសង្ឃឹមថា ក្នុងពេលបន្ទាប់មកទៀតនោះ ភ្នាក់ងារដៃគូរអភិវឌ្ឍន៍ខាងក្រៅផ្សេងៗ (អ្នកផ្តល់ជំនួយ) អាចយល់ស្របជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ថវិកាលើផ្នែកមួយ ឬ ច្រើន ក្នុងកម្មវិធីនិមួយៗ ហើយជាបន្តបន្ទាប់ នឹងមានការរៀបចំផ្នែកទាំងនោះ ឱ្យស៊ីជំរៅថែមទៀត (ដោយកំណត់សកម្មភាព ផែនការការងារ ។ល ។) ដោយអនុវត្តន៍តាមវិធីសាស្ត្រគ្រប់គ្រងវដ្តនៃកម្មវិធីនិមួយៗ របស់គេរៀងៗខ្លួន ។ ករណីនេះ មានន័យថា ការពណិនាលំអិតពីលទ្ធផល ត្រូវបានរៀបរាប់ក្នុងឯកសារកម្មវិធី ដោយសារថា វានឹងត្រូវបានប្រើប្រាស់ ជាចំណុចចាប់ផ្តើម សំរាប់ការពិភាក្សាលំអិតថែមទៀត លើគំរោង ឬ សកម្មភាពទាំងនោះ ។

ក្រុមរៀបចំកម្មវិធី និងប្រើប្រាស់នូវវិធីសាស្ត្រក្របខ័ណ្ឌជាក់ស្តែង (Logical framework approach) ដូចមានបង្ហាញក្នុងរូបភាពនៅទំព័របន្ទាប់នេះ ។ គួរត្រូវកត់សំគាល់ថា :

- សំរាប់កម្មវិធីនិមួយៗ មានគោលដៅមួយ ដែលបានលើកឡើងក្នុងឯកសាររៀបចំយុទ្ធសាស្ត្រ និងដែលហៅថា គោលដៅអភិវឌ្ឍន៍របស់កម្មវិធី ។ គោលដៅអភិវឌ្ឍន៍របស់កម្មវិធីទាំងប្រាំនេះ ត្រូវបានកំណត់ក្នុងពេលរៀបចំយុទ្ធសាស្ត្រ ដែលជាគោលដៅល្អបំផុត ក្នុងការធានាដល់ការសំរេចបាន នូវគោលដៅចំបងដែលបានកំណត់ក្នុងឯកសារយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ។ ហេតុដូចនេះហើយ បានជាគោលបំណងទាំងនេះ មិនគួរត្រូវបានកែប្រែទេ ។
- ដំណាក់កាលបន្ទាប់ ក្នុងលំដាប់ថ្នាក់នៃក្របខ័ណ្ឌជាក់ស្តែង គឺថា ជាគោលបំណង ឬ លទ្ធផល (ដែលអាចហៅថា គោលបំណងជាក់លាក់ផងដែរ) ដែលនឹងរួមចំណែកក្នុងការសំរេចបាន នូវគោលដៅអភិវឌ្ឍន៍របស់កម្មវិធី ។ ចាប់តាំងពីកំរិតនេះចុះក្រោម ក្នុងលំដាប់ថ្នាក់នៃការរៀបចំ វាគឺជាការទទួលខុសត្រូវរបស់ក្រុមរៀបចំកម្មវិធី ក្នុងការលើកឡើងនូវសំណើនានា ។ គោលដៅជាក់លាក់សំខាន់ៗមួយចំនួន សំរាប់កម្មវិធីទាំងប្រាំនេះ ត្រូវបានកំណត់ដោយក្រុមយុទ្ធសាស្ត្រ និងមានបង្ហាញក្នុងឯកសារ

យុទ្ធសាស្ត្រ (ចំណុច ៦.១.៣, ៦.២.៣, ៦.៣.៣, ៦.៤.៣ និង ៦.៥.៣)។ គោលដៅទាំងនេះ គឺបានមកពីការពិភាក្សា និងវិភាគពីពេលមុនៗមក រួមទាំងការសំយោគនូវគោលបំណង ដែលបានកំណត់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់គេ ហើយដែលត្រូវចាត់ទុកជាមូលដ្ឋាន សំរាប់ការឆ្លុះបញ្ចាំង និងការវិភាគ បន្ថែមទៀត ដោយក្រុមរៀបចំកម្មវិធី ។ លទ្ធផល ឬ គោលបំណងជាក់លាក់នេះ ត្រូវបានគេគិតថា ជា មូលដ្ឋាន ក្នុងការកំណត់នូវផ្នែកផ្សេងៗនៃកម្មវិធី ។

- បន្ទាប់មក យើងមានលទ្ធផល ដែលត្រូវបានបង្កើតឡើង ដើម្បីសំរេចបាននូវលទ្ធផលដែលចង់បាន ។ វាគឺជាដំណាក់កាលដែលត្រូវរៀបរាប់លំអិតថែមទៀត ។

## ក្របខ័ណ្ឌជាក់ស្តែង/លំដាប់ថ្នាក់នៃគោលបំណង



ផ្នែកសំខាន់ៗ នៃឯកសាររៀបចំកម្មវិធី គួរតែជាការកំណត់នូវអាទិភាព គំរុយសំខាន់ៗ និង ជាលក្ខខ័ណ្ឌនៃជោគជ័យ សំរាប់ផ្នែកផ្សេងៗ ឬ លទ្ធផលផ្សេងៗ ។ ធាតុពិត ឯកសាររៀបចំកម្មវិធី គួរជៀសវាងនូវការរៀបរាប់វែងអន្លាយ មានលក្ខណៈអស្ចារ្យ ប៉ុន្តែមិនមានភាពជាក់ស្តែងដែលអាចអនុវត្តន៏បាននោះ ។ គេអាចធ្វើការជ្រើសរើស ដើម្បីឱ្យកម្មវិធីនោះ មានឥទ្ធិពលជាក់ស្តែងលើស្ថានភាពរបស់វិស័យ ដើម្បីទទួលបាននូវលទ្ធផលដែលចាំបាច់ ក្នុងការសំរេចបាននូវគោលបំណងរបស់កម្មវិធី ។ ដោយសារថា កម្មវិធីទាំងនេះ នឹងត្រូវរៀបរាប់លំអិតថែមទៀត ដោយអ្នកផ្តល់ជំនួយ នៅពេលក្រោយនោះ ឯកសាររៀបចំកម្មវិធី គួរត្រូវផ្តល់ផងដែរនូវអនុសាសន៏ ស្តីពីសូចនាករច្បាស់លាស់មួយចំនួន ចំពោះលទ្ធផលផ្សេងៗ ដែលបានលើកឡើង ក៏ដូចជា លក្ខខ័ណ្ឌក្នុងការវាយតំលៃជាមូលដ្ឋាន មួយចំនួន សំរាប់កម្មវិធីទាំងមូល ។

ដើម្បីភ្ជាប់ជាមួយផ្នែកខាងលើ និងជាពិសេស ដើម្បីពង្រីកនូវប្រសិទ្ធិភាពនៃលទ្ធផល ឬ សកម្មភាពដែលបានលើកឡើងនោះ ក្រុមរៀបចំកម្មវិធីត្រូវចងចាំថា កម្មវិធីនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រតាមវិស័យ ដែលមានការចូលរួមដោយផ្ទាល់ ពីបណ្តាអ្នកពាក់ព័ន្ធជាច្រើន ។ ឧទាហរណ៏ ខាងរដ្ឋាភិបាល ទោះបីជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម គឺជាក្រសួងពាក់ព័ន្ធសំខាន់ក៏ដោយ វានៅមានក្រសួងមួយចំនួនទៀត ក៏មានការពាក់ព័ន្ធក្នុងកិច្ចដំណើរការក្នុងវិស័យនេះដែរ ។ ក្នុងករណីខ្លះ កិច្ចដំណើរការអាចផ្អែកយ៉ាងខ្លាំងលើការសំរេចចិត្ត ដោយស្ថាប័នទាំងនោះ ហើយដែលវាឋិតនៅក្រៅក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ភ្នាក់ងារដែលអនុវត្តន៏យុទ្ធសាស្ត្រ ។ ស្ថានភាពនេះ គួរតែត្រូវជៀសវាងឱ្យបាន តាមការដែលអាចធ្វើទៅបាន ឬ ត្រូវកំណត់ឱ្យបានច្បាស់លាស់ (ស្ថានភាព) ។ ផ្ទុយទៅវិញ កម្មវិធី គួរត្រូវផ្អែកលើការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៏នូវយុទ្ធសាស្ត្ររួមនេះ និងខិតខំបង្កើននូវ ទំនាក់ទំនងប្រតិបត្តិការ រវាងក្រសួងទាំងពីរនេះ ។

ដូចគ្នានេះផងដែរ ដើម្បីសំរេចបាននូវប្រសិទ្ធិភាពរបស់កម្មវិធី ត្រូវយកចិត្តទុកដាក់ ជាពិសេស លើចលនករនៃកម្មវិធី ក្នុងការរៀបចំនូវលទ្ធផល និងសកម្មភាព ដែលចាំបាច់ឱ្យទាន់ពេលវេលា (ដំណាក់កាល និងលក្ខខ័ណ្ឌដើម ចំពោះលទ្ធផល ឬ សកម្មភាព) ។

## ២. កិច្ចដំណើរការទូទៅ នៃការងារ របស់ក្រុមរៀបចំយុទ្ធសាស្ត្រ

ការងារសំរាប់កម្មវិធី ដែលបានស្នើឡើង សំរាប់ក្រុមនេះ មានដូចខាងក្រោម :

- ពិនិត្យលើឯកសារដែលពាក់ព័ន្ធ ដែលរួមមាន រាល់ឯកសារដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ និងឯកសារផ្សេងៗទៀត ដែលទាក់ទងនឹងគោលគំនិតសំខាន់ៗ រួមទាំងឯកសារគំរោង ឬ របាយការណ៏

វាយតំលៃផ្សេងៗទៀត ។ កត្តាសំខាន់ ក្នុងការរៀបចំកម្មវិធី គឺត្រូវគិតពិចារណាលើ បទពិសោធន៍ដកស្រង់ចេញពីកម្មវិធី ឬ គំរោងមុនៗមក ។ល ។

- ប្រសិនបើចាំបាច់ ត្រូវធ្វើការសម្ភាសន៍បន្ថែម ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (បញ្ជីអ្នកពាក់ព័ន្ធ នឹងផ្តល់នៅពេលក្រោយ?)
- ផ្អែកតាមគោលការណ៏នេះ ធ្វើការវិភាគលើបញ្ហាបន្ថែម (រួមទាំង ការវិភាគលើ ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT) និង អ្នកពាក់ព័ន្ធ...) ដើម្បីស្វែងយល់ឱ្យបានស៊ីជំរៅថែមទៀត លើវិស័យនេះ លើឧបស័គ្គសំខាន់ៗ ឱកាស ។ល ។ ដោយរួមទាំងកម្មវិធី និងគំរោងសំខាន់ៗ ដែលកំពុងអនុវត្តន៏ និងគោលបំណង សមិទ្ធិផល ការលំបាក និងចំណុងខ្សោយរបស់វាផង
- កំណត់នូវលទ្ធផលសំខាន់ៗ (គោលបំណង់ជាក់លាក់ គោលដៅដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រ) និងលទ្ធផលដែលទាក់ទង និងក្នុងករណីខ្លះ គឺត្រូវកំណត់នូវសកម្មភាពសំខាន់ៗ (កិច្ចដំណើរការ ដែលត្រូវអនុវត្តន៏) ។ ករណីនេះ គឺត្រូវមានការលើកឡើងនូវផ្នែកផ្សេងៗ សំរាប់កម្មវិធី (ផ្នែកសំខាន់ៗខ្លះត្រូវបានរៀបរាប់ក្នុងឯកសារយុទ្ធសាស្ត្រ) ។ ក្នុងដំណាក់កាលរៀបចំកម្មវិធីនេះ អាចមានការផ្លាស់ប្តូរខ្លះ ប៉ុន្តែផ្នែកផ្សេងៗ គួរត្រូវមានលក្ខណៈដូចៗគ្នា តាមការដែលអាចធ្វើទៅបាន ចំពោះខ្លឹមសាររបស់វា ហើយត្រូវរក្សាឱ្យឋិតក្នុងទំហំសមស្របមួយ ដើម្បីឱ្យការអនុវត្តន៏ មានលក្ខណៈអាចគ្រប់គ្រងបានទាំងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ ។
- ធ្វើការទាក់ទងទៅវិញទៅមកជាប្រចាំ ជាមួយអ្នកពាក់ព័ន្ធ និងក្រុមរៀបចំកម្មវិធីផ្សេងៗទៀត
- ការពណ៌នាអំពីកម្មវិធី គួររួមមាននូវចំណុចដូចខាងក្រោមនេះ

■ ពង្រាងពេលវេលារបស់កម្មវិធី ឬ ផ្នែកផ្សេងៗ ។ ប្រការនេះ គួរត្រូវមានពេលវេលាកំណត់ចាំបាច់សំរាប់សកម្មភាពនានា (ដែលទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងអាទិភាព និងលក្ខខ័ណ្ឌក្នុងចំណុច១) ។

■ ការប៉ាន់ស្មាន់នូវតំលៃសំរាប់គំរោងទាំងមូល និងផ្នែកផ្សេងៗទៀត

■ ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធផ្សេងៗ ក្នុងការអនុវត្តន៏

■ ការពណ៌នា ពីការទំនាក់ទំនងទៅវិញទៅមក និងការជាប់ទាក់ទងជាមួយកម្មវិធីផ្សេងទៀតនៃយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក និង/ឬ ជាមួយវិស័យផ្សេងៗទៀត ។

***(សូមកត់សំគាល់ថា លក្ខខ័ណ្ឌការងារខាងក្រោមនេះ គឺគ្រាន់តែជាពង្រាងដំបូងប៉ុណ្ណោះ ហើយដែលត្រូវរៀបចំ បន្ថែម មុននឹងក្រុមការងាររៀបចំកម្មវិធី ។ ដំណើរការរៀបចំបញ្ចប់កម្មវិធីនេះត្រូវបានកំពុងរៀបចំ ។)***

# លក្ខខណ្ឌការងារ សំរាប់ក្រុមរៀបចំកម្មវិធី
# កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រង
# សំរាប់វិស័យកសិកម្ម និងធនធានទឹក

## ១. សាវតា

សាវតា ចំពោះការងាររៀបចំកម្មវិធីនេះ ត្រូវបានផ្តល់នៅក្នុងពង្រាងរបាយការណ៍យុទ្ធសាស្ត្រកសិកម្ម និងទឹក ។ យុទ្ធសាស្ត្រនេះ នឹងជួយ ជាពិសេស ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវ និងសំរេចបាននូវគោលដៅ ដែលកំណត់ដោយផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ និងដោយគោលដៅអភិវឌ្ឍន៍សហសវត្ស របស់ប្រទេសកម្ពុជា ។ ពតិមានបន្ថែម មានផ្តល់នៅក្នុងឯកសារការងារ ស្តីពីឯកសារយុទ្ធសាស្ត្រ សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមក្នុងវិស័យកសិកម្ម និងទឹក ( មាននៅលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក) ។

គោលដៅសំខាន់ៗរបស់យុទ្ធសាស្ត្រ នឹងត្រូវសំរេចបានតាមរយៈការងារក្នុងកម្មវិធីទាំងប្រាំ ។ កម្មវិធីមួយក្នុងចំណោមកម្មវិធី ទាំងនោះ គឺ កម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រង សំរាប់វិស័យកសិកម្ម និងធនធានទឹក ។

## ២. គោលបំណង

គោលបំណងសំខាន់នៃក្រុមរៀបចំកម្មវិធី គឺ :

ដើម្បីរៀបចំកម្មវិធី ដែលទទួលយកបានដោយសហប្រធាន នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ចំពោះកម្មវិធីគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងសំរាប់វិស័យកសិកម្ម និងធនធានទឹក ។

កាលបរិច្ឆេទ ដែលគ្រោងរៀបចំបញ្ចប់នូវគោលបំណងនេះ គឺ ថ្ងៃទី៣១ ខែ សហា ឆ្នាំ ២០០៧ ។

## ៣. ទំហំ

របាយការណ៍ព្រាងយុទ្ធសាស្ត្រកសិកម្ម និងទឹក ( ក្នុងឧបសម្ព័ន្ធ ១ ចំណុច ៦.១) បង្ហាញនូវទំហំនៃ កម្មវិធី ។ វាផ្អែកទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួម ចំណែកដល់ដំណើរការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ ។ គោលបំណង លទ្ធផល និងសកម្មភាពនានា ដែលបានកំណត់រួចហើយក្នុងផែនការនេះ នឹងត្រូវកែតំរូវ ឡើងវិញ ប្រមូលផ្តុំ និង/ឬ បន្ថែមតាមការចាំបាច់ ។ ចាំបាច់ត្រូវធ្វើការងារបន្ថែមទៀត លើកម្មវិធីនេះ ជាពិសេស ដោយផ្តល់នូវសកម្មភាពសំខាន់ៗ លំអិតថែមទៀត និងប៉ាន់ស្មាននូវធនធានដែលត្រូវការ ដើម្បីធានាថា វាបានផ្តល់

នូវមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈល្អមួយ ក្នុងការចែកចាយធនធាន ដោយមន្ត្រីរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ ។

ត្រូវមានការគិតពិចារណាលើទិដ្ឋភាពនៃកម្មវិធីក្នុងផ្នែកនានា ដូចខាងក្រោម :

១- បង្កើនសមត្ថភាពស្ថាប័ន (រួមទាំងមាន ក្រុមបេសកកម្មជាអាទិភាព និងការលើកទឹកចិត្ត) នោះគឺការពង្រឹងក្នុងគ្រប់ទិដ្ឋភាព នៃសមត្ថភាពស្ថាប័ន ទាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ចំពោះការអនុវត្តន៍រៀង១ខ្លួន នូវគោលនយោបាយ និងផែនការក៏ដូចជាការអនុវត្តន៍នូវច្បាប់ និងបទបញ្ញាតិនានា ។

២- ការបង្កើននូវសេវាកម្ម និងប្រព័ន្ធទិន្នន័យ និងពតិមានស្តីពីកសិកម្ម និងទឹក ដោយបង្កើននូវសេវាកម្ម និងប្រព័ន្ធពតិមានស្តីពីកសិកម្ម និងទឹក (រួមទាំងសន្តិសុខស្បៀង និងប្រព័ន្ធពតិមានស្តីពី ភាពងាយរងគ្រោះ ប្រព័ន្ធទិន្នន័យ ជលសាស្ត្រ និងឧតុនិយម (ទឹកជំនន់ និងគ្រោះរាំងស្ងួត) ស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ដើម្បីគ្រប់គ្រង និងប្រើប្រាស់ឱ្យបានល្អ ដោយអ្នកធ្វើគោលនយោបាយ និងអ្នកប្រើប្រាស់ទិន្នន័យដ៏ទៃទៀត ក៏ដូចជាក្នុងការបង្កើននូវទំនាក់ទំនងក្នុងប្រព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ។

៣- ការបង្កើត និងអនុវត្តន៍នូវច្បាប់កសិកម្ម និងធនធានទឹក ដោយពិនិត្យឡើងវិញ លើច្បាប់ស្តីពីកសិកម្ម និងទឹក ក៏ដូចជាសមត្ថភាពក្នុងការអនុវត្តន៍ច្បាប់ ហើយតាមរយៈនេះ កំណត់ ឬ លើកឡើងនូវការរៀបចំក្របខ័ណ្ឌច្បាប់ និងសមត្ថភាពដែលចាំបាច់បន្ថែមទៀត ។

៤- ការបញ្ជ្រាបយ៉ែនឌ័រ និងសន្តិសុខស្បៀង ដោយពង្រឹង និងកសាងសមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធ ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ស្តីពីបញ្ហាយ៉ែនឌ័រ និងសន្តិសុខស្បៀង ក៏ដូចជាការបង្កើននូវការបញ្ជ្រាប បញ្ហាទាំងនេះផងដែរ ។

៥- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដោយពិនិត្យឡើតវិញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុបច្ចុប្បន្ន (រួមទាំងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ឯកសារគ្រប់គ្រងហិរញ្ញវត្ថុ) និងសមត្ថភាព និងផ្តល់គំនិតក្នុងការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធ ជាពិសេស ទាក់ទងនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ កំណត់នូវការចូលរួមរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៍នូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។

៦- ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតំលៃ ដោយពិនិត្យឡើងវិញលើក្របខ័ណ្ឌ ឬ យន្តការដែលមានស្រាប់ និងផ្តល់នូវគំនិត ឬ វិធានការ សំរាប់ពង្រឹងនូវក្របខ័ណ្ឌ ឬ យន្តការនោះ ។

៧- នីតិវិធី និងយន្តការ ក្នុងការទំនាក់ទំនង ដោយកំណត់នូវ យន្តការ និងនីតិវិធីទំនាក់ទំនងដែលមាន និង លើកឡើងនូវវិធានការដែលមានប្រសិទ្ធិភាព ។

៨- ធ្វើវិមជ្ឈការនូវធនធានមនុស្សដល់ថ្នាក់ខេត្ត ដោយកំណត់នូវសមត្ថភាព និងធនធានមនុស្ស ដែលត្រូវការនៅថ្នាក់ខេត្ត ដើម្បីផ្តល់នូវការគាំទ្របច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ប្រកបដោយប្រសិទ្ធិភាព ។

## ៤. លទ្ធផល និង របាយការណ៍

១- ឯកសារគោលគំនិតមួយ នឹងត្រូវផ្តល់ដល់អ្នកគ្រប់គ្រងការងារ ក្នុងរយៈពេលមួយសប្តាហ៍ នៃការចាប់ផ្តើមការងារ ។

២- លទ្ធផលសំខាន់ៗនោះ គឺឯកសាររៀបចំកម្មវិធីមួយ ជាពង្រាង និងចុងក្រោយ (សូមមើលចំណុច ៥) ។ ឯកសាររៀបចំកម្មវិធី ត្រូវអនុវត្តន៍តាមទំរង់ដែលអាចទទួលយកបាន និងដែលណែនាំដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងមានសង្ខេបក្នុងក្របខ័ណ្ឌជាក់ស្តែងមួយ ។ ឯកសារនេះ នឹងបង្ហាញនូវបណ្តុំនៃសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងកំលុងរយៈពេលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទី III ហើយដែលសកម្មភាពនេះរួមគ្នា នឹងជួយឱ្យក្រសួងទាំងពីរនេះ សំរេចបានប្រកបដោយប្រសិទ្ធិភាព នូវគោលដៅរបស់គេ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

៣- លទ្ធផលសំខាន់ៗ នឹងគាំទ្រដោយ (1) ការបង្ហាញដោយផ្ទាល់មាត់ ក្នុងសិក្ខាសាលាមួយចំពោះ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និង (2) មានឯកសារជំនួយស្មារតីមួយ ផ្តល់ដល់អ្នកគ្រប់គ្រងការងារ ដែលត្រូវត្រួតពិនិត្យឡើងវិញ លើដំណើរការរៀបចំ និងបង្ហាញនូវការរកឃើញ ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធីនោះ ។

## ៥. សកម្មភាព

ក្រុមរៀបចំកម្មវិធីនឹង :

១- ស្វែងយល់ពីរបាយការណ៍ ឬ ឯកសារការងារ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

២- ដាក់ជូននូវឯកសារគោលគំនិត ដែលមានបង្ហាញផងដែរ នូវផែនការការងារគំរូ សំរាប់ធ្វើឯកសាររៀបចំកម្មវិធី និងការយល់ដឹងរបស់ក្រុម លើវិធីសាស្ត្រដែលបានស្នើឡើងចំពោះការងារនោះ ។

៣- ធ្វើការប្រឹក្សា តាមការចាំបាច់ ជាមួយមន្ត្រីសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (រួមទាំងបុគ្គលិកបច្ចេកទេស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ផង) ទៅតាម ការសមស្រប ។

៤- ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ យ៉ាងហោចណាស់មួយសប្តាហ៍ម្តង តាមរយៈអ៊ីម៉ែល ស្តីពី កិច្ចដំណើរការ និងបញ្ហានានា ដែលអាចរារាំងដល់ការបញ្ចប់ការងារដោយជោគជ័យនោះ ។

៥- ដាក់ជូននូវពង្រាងឯកសាររៀបចំកម្មវិធី ធ្វើការកែតំរូវដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងយោបល់ របស់អ្នកគ្រប់គ្រងការងារ និងអ្នកពាក់ព័ន្ធនានា និងដាក់ជូននូវឯកសាររៀបចំកម្មវិធីចុងក្រោយ ។

៦- ធ្វើការទំនាក់ទំនងជាមួយក្រុមរៀបចំកម្មវិធីផ្សេងទៀត ដែលចុះកិច្ចសន្យាជាមួយក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក ។

៧- ជួយដល់ក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្នុងការចងក្រងនូវឯកសារ នេះ និងការរៀបចំកម្មវិធីផ្សេងទៀត ទៅជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយសំរាប់វិស័យកសិកម្ម និងទឹក (តែអ្នក ជំនាញជាតិ តែប៉ុណ្ណោះ) ។

៨- ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ តាមរយៈមធ្យោបាយផ្តល់ឯកសារជំនួយស្មារតី នៃការ រកឃើញនានា ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធី និងពិនិត្យឡើងវិញ នូវដំណើរការ រៀបចំកម្មវិធី ។

៩- បង្ហាញដោយផ្ទាល់មាត់ នូវគំរោងកម្មវិធីដែលលើកឡើង ក្នុងសិក្ខាសាលាសំរាប់សមាជិកក្រុមការងារ បច្ចេកទេសកសិកម្ម និងទឹក ។ ការបង្ហាញនោះ ត្រូវមានរៀបចំជាការបង្ហាញតាមកុំព្យូទ័រ (Power point) និង មានឯកសារចែកផង ។

## ៦. ពេលវេលា

ការបែងចែកពេលវេលាខាងក្រោមនេះ គឺសំរាប់តែដំណាក់កាលសំខាន់ៗ នៃកិច្ចដំណើរការតែប៉ុណ្ណោះ ដោយមានពេលវេលាសំរាប់សកម្មភាពនិមួយៗ ។ ពេលាវេលាសំរាប់កិច្ចដំណើរការទាំងមូល គឺមិនមែនជាការ បូកបញ្ចូល នៃពេលវេលានិមួយៗទាំងនេះ នោះទេ ព្រោះថា ដំណាក់កាលទាំងនេះ វានឹងមិនព្រព្រឹត្តទៅបន្តបន្ទាប់ គ្នារហូតនោះទេ ហើយដើម្បី (១) គិតដល់ពេលវេលាសំរាប់អ្នកជំនាញការ ក្នុងការធ្វើរបាយការណ៍របស់គេ (២) ដើម្បីឱ្យក្រុមរៀបចំកម្មវិធីធ្វើការពិភាក្សា សរសេរ ធ្វើទំនាក់ទំនងរវាងអ្នកជំនាញការអចិន្ត្រៃ និងអ្នកជំនាញការ

រយៈពេលខ្លី ធ្វើការផ្លាស់ប្តូរយោបល់ជាមួយបុគ្គលសំខាន់ៗ ក្រុមការងារយុទ្ធសាស្ត្រ អ្នកគ្រប់គ្រងការងារ ក្រុមសំរបសំរួលការរៀបចំកម្មវិធី ...។ រយៈពេលសរុប នៃកិច្ចដំណើរការនេះ អាចប៉ាន់ស្មានប្រហែល ៦-៧ ខែ ។

១- ការពិនិត្យដំបូងលើឯកសារដែលទាក់ទង : ១ សប្តាហ៍

២- បេសកកម្មរៀបចំ : ២ សប្តាហ៍

៣- បេសកកម្មដើម្បីវិភាគលើបញ្ហា

(ដោយអ្នកកជំនាញការជាតិ ឬ អន្តរជាតិរយៈលេខ្លី) : ២ សប្តាហ៍

៤- រៀបចំឯកសារពង្រាងកម្មវិធីលើកទីមួយ : ៣ សប្តាហ៍

៥- សិក្ខាសាលាដើម្បីពិនិត្យលើពង្រាងឯកសារកម្មវិធី : ១ សប្តាហ៍

៦- រៀបចំបញ្ចប់ឯកសារពង្រាងកម្មវិធី : ២ សប្តាហ៍

## ៧. សមាសភាពរបស់ក្រុម

ក្រុមរៀបចំកម្មវិធីសំខាន់ រួមមានៈ

- អ្នកជំនាញការ ថ្នាក់អន្តរជាតិម្នាក់ (ជំនាញផ្នែកស្ថាប័ន) ជាអ្នកសំរបសរួលយ៉ាងសំខាន់ក្នុងការងារនេះ (មានបេសកកម្មជាប្រចាំ និងធើការតាមដានការងារពីចំងាយតាមរយៈអ៊ីម៉ែល)

- ទីប្រឹក្សាបរទេស នៅក្នុងស្រុកស្រាប់ម្នាក់ ជាសហ-អ្នកសំរបសំរួល (ទីប្រឹក្សាបារាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )

- អ្នកជំនាញការជាតិម្នាក់ ពេញម៉ោង (ជំនាញផ្នែកគ្រប់គ្រង ឬស្ថាប័ន)

- មន្ត្រី ៣ រូបមកពីក្រសួងកសិកមរុក្ខាប្រមាញ់ និងនេសាទ (ដែលមានជំនាញផ្សេងៗគ្នាផ្នែក ហិរញ្ញវត្ថុ និង ថវិកា ឬ ផែនការ ឬ អភិវឌ្ឍន៏ធនធានមនុស្ស)

- មន្ត្រី ៣ រូបមកពីក្រសួងធនធានទឹក និងឧតុនិយម (ដែលមានជំនាញផ្សេងៗគ្នាផ្នែក ហិរញ្ញវត្ថុ និង ថវិកា ឬ ផែនការ ឬ អភិវឌ្ឍន៍ធនធានមនុស្ស)

អ្នកជំនាញការអន្តរជាតិ ៣ ទៅ ៤ នាក់ នឹងត្រូវការសំរាប់ការងារទាំងនេះ ។ ចំនួន ជំនាញ លក្ខខ័ណ្ឌការងារ និងលក្ខណៈសម្បត្តិរបស់គេ នឹងត្រូវកំណត់ក្នុងពេលបេសកកម្មរៀបចំ ។

ដូចបានបង្ហាញក្នុងពង្រាងផែនការសកម្មភាព សំរាប់រៀបចំកម្មវិធីអភិវឌ្ឍន៏កសិកម្ម និងទឹក ក្រុមរៀបចំកម្មវិធី នឹងធ្វើការទាក់ទងយ៉ាងសកម្មជាមួយ មន្ត្រីក្រសួងកសិកមរុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ឬ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹកតាមរយៈក្រុមការងារយុទ្ធសាស្ត្រ ឬ ក្រុមសំរបសំរួលការរៀបចំកម្មវិធី និងគៀងគរនូវធនធានមនុស្សពីអ្នកពាក់ព័ន្ធនានា ។

## ៨. ថវិកា

| រាយមុខរបស់ | តំលៃ<br>(ដុល្លាអាមេរិក) |
|---|---|
| អ្នកសំរបសំរួលអន្តរជាតិ (បេសកកម្មពីរដង ១០ថ្ងៃ និង ២ដង ៥ថ្ងៃ និង ២០ ថ្ងៃធ្វើការនៅការិយាល័យ) | ៥០ ០០០ |
| អ្នកជំនាញការជាតិ ពេញម៉ោង (៦ ខែ) | ៧ ២០០ |
| ៣-៤ អ្នកជំនាញការអន្តរជាតិ បេសកកម្ម ម្នាក់ៗ ១០ ថ្ងៃ | ៣៦ ០០០-៤៨ ០០០ |
| មន្ត្រីមកពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម (ប្រាក់ឧបត្ថម្ភប្រចាំខែ) | ៧ ២០០ |
| សិក្ខាសាលាចំនួន ២ ថ្ងៃ | ៥ ០០០ |
| ការចំណាយក្នុងស្រុក: សំភារៈការិយាល័យ បោពុម្ព ប្រជុំ សិក្ខាសាលា ការបកប្រែ | ៣ ០០០ |
| **សរុប** | ១០៨ ៤០០-១២០ ៤០០ |

## លក្ខខណ្ឌការងារ សំរាប់ក្រុមរៀបចំកម្មវិធី
## កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង

### ១. សាវតា

សាវតា ចំពោះការងាររៀបចំកម្មវិធីនេះ ត្រូវបានផ្តល់នៅក្នុងរបាយការណ៍រៀបចំយុទ្ធសាស្ត្រ II ( ឯកសារបន្ថែម ១) នោះគឺ យុទ្ធសាស្ត្រសំរាប់វិស័យកសិកម្ម និងទឹក ។ យុទ្ធសាស្ត្រនេះ នឹងជួយ ជាពិសេស ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវ និងសំរេចបាននូវគោលដៅ ដែលកំណត់ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ និងដោយគោលដៅអភិវឌ្ឍន៍សហសវត្សរបស់ប្រទេសកម្ពុជា ។ ពត៌មានបន្ថែម មានផ្តល់នៅក្នុងឯកសារការងារ ស្តីពីឯកសារយុទ្ធសាស្ត្រ សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមក្នុងវិស័យកសិកម្ម និងទឹក ( មាននៅលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក) ។ គោលដៅសំខាន់ៗរបស់យុទ្ធសាស្ត្រនេះ នឹងត្រូវសំរេចបាន តាមរយៈការងារក្នុងកម្មវិធីទាំងប្រាំ ។ កម្មវិធីមួយ ក្នុងចំណោមកម្មវិធី ទាំងនោះ គឺ "កម្មវិធីគាំទ្រដល់សន្តិសុខស្បៀង" ។

### ២. គោលបំណង

គោលបំណងសំខាន់នៃក្រុមរៀបចំកម្មវិធី គឺដើម្បីរៀបចំកម្មវិធី ដែលទទួលយកបានដោយសហប្រធាននៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ចំពោះកម្មវិធីគាំទ្រដល់សន្តិសុខស្បៀង ។

កាលបរិច្ឆេទ ដែលគ្រោងរៀបចំបញ្ចប់នូវគោលបំណងនេះ គឺ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៦ ។

### ៣. ទំហំ

របាយការណ៍ព្រាងស្តីពីការបង្កើតយុទ្ធសាស្ត្រ II (ក្នុងឯកសារបន្ថែម ចំណុច ៦.១) បង្ហាញនូវទំហំនៃកម្មវិធី ។ វាផ្អែកទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួម ចំណែកដល់ដំណើរការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ គោលបំណង លទ្ធផល និងសកម្មភាពនានា ដែលបានកំណត់រួចហើយក្នុងផែនការនេះ នឹងត្រូវកែតំរូវឡើងវិញ ប្រមូលផ្តុំ និង/ឬ បន្ថែមតាមការចាំបាច់ ។ ចាំបាច់ត្រូវធ្វើការងារបន្ថែមទៀត លើកម្មវិធីនេះ ជាពិសេសដោយផ្តល់នូវសកម្មភាពសំខាន់ៗ លំអិតថែមទៀត និងប៉ាន់ស្មាននូវធនធានដែលត្រូវការ ដើម្បីធានាថា វាបានផ្តល់នូវមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈល្អមួយ ក្នុងការចែកចាយធនធាន ដោយមន្ត្រីរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ ។ ជាងនេះទៅទៀតនោះ ត្រូវមានការគិតពិចារណាលើទិដ្ឋភាពនៃកម្មវិធីក្នុងផ្នែកនានា ដូចខាងក្រោម :

១-បង្កើន និងធានាឱ្យមានស្បៀងអាហារ ដោយបង្កើននូវការផលិតស្បៀងតាមគ្រួសារ តាមរយៈការមាននូវជំនាញល្អ ក្នុងផ្នែកកសិកម្ម និងការចិញ្ចឹមសត្វ ការគ្រប់គ្រងទឹក និងការគ្រប់គ្រងជលផល និងព្រៃឈើដោយសហគមន៍ ។

២-បង្កើនស្បៀងអាហារ ដោយបង្កើននូវប្រភពបង្កើតចំណូលផ្សេងៗ តាមរយៈការមានជំនាញល្អ ក្នុងផ្នែកជំនួញ អាជីវកម្ម ឬ សហគ្រាសខ្នាតតូច ឱកាសការងារ និងសកម្មភាពក្រៅកសិដ្ឋាន សកម្មភាពទេសចរណ៍ដែលផ្ដល់ផលប្រយោជន៍ដល់អ្នកក្រីក្រ តំរោងតូចៗនៅតាមសហគមន៍ ។ល។

៣-ធានាដល់ការប្រើប្រាស់ស្បៀងអាហារ ដោយយកចិត្តទុកដាក់លើការបង្កើននូវអាហារូបត្ថម្ភ អនាម័យ និងការយល់ដឹងពីអនាម័យ ចំណេះដឹង និងការអនុវត្តន៍ (រួមទាំងជំងឺអេដស៍ផង) ។

៤-ផ្ទេរសិទ្ធអំណាចដល់សហគមន៍មូលដ្ឋាន និងក្រុមនានា និង ពង្រឹងសុវត្ថិភាពសន្តិសុខស្បៀង តាមរយៈការរៀបចំ និងអភិវឌ្ឍន៍សហគមន៍ ដោយមានការចូលរួម ក៏ដូចជាការបង្កើននូវក្រុមជួយខ្លួនឯង ក្រុមសន្សំប្រាក់ ក្រុមស្ត្រី-យ៉ែនឌ័រ សមាគមកសិករ ។ល។

៥-កែលំអគោលនយោបាយ ស្ដីពីសន្តិសុខស្បៀង ។

ទិដ្ឋភាពខាងលើទាំងអស់នេះ ត្រូវទាញចេញ ជាពិសេស ពីឯកសារដែលបានបង្កើតឡើង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីកម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ (NPHFSPR) ឆ្នាំ ២០០៧-២០១១ ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវមានការការគាំទ្រ និងទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ រវាងបណ្ដាផ្នែកទាំងអស់ និងរវាងកម្មវិធីសន្តិសុខស្បៀង និងកម្មវិធីផ្សេងៗទៀត ។

## ៤. លទ្ធផល និង របាយការណ៍

ដោយសារ កម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ (NPHFSPR) ឆ្នាំ ២០០៧-២០១១ ត្រូវបានបង្កើតឡើង និងអនុម័តរួចហើយនោះ លទ្ធផលដែលរំពឹងទុក និងរបាយការណ៍ គឺមានដូចខាងក្រោមនេះ :

១-លទ្ធផលសំខាន់ៗនោះ គឺឯកសាររៀបចំកម្មវិធីមួយ ជាពង្រាង និងចុងក្រោយ (សូមមើលចំណុច ៥) ។ ឯកសាររៀបចំកម្មវិធី ត្រូវអនុវត្តន៍តាមទំរង់ដែលអាចទទួលយកបាន និងដែលណែនាំដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងមានសង្ខេបក្នុងក្របខ័ណ្ឌជាក់ស្ដែងមួយ ។ ឯកសារនេះ នឹងបង្ហាញនូវបណ្ដុំនៃសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងកំលុងរយៈពេលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទី III ហើយដែលសកម្មភាពនេះរួមគ្នា នឹងជួយឱ្យក្រសួងទាំងពីរនេះ សំរេចបានប្រកបដោយប្រសិទ្ធិភាព នូវគោលដៅរបស់គេ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

២- លទ្ធផលសំខាន់ៗ នឹងគាំទ្រដោយ (1) ការបង្ហាញដោយផ្ទាល់មាត់ ក្នុងសិក្ខាសាលាមួយចំពោះ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និង (2) មានឯកសារជំនួយស្មារតីមួយ ផ្តល់ដល់អ្នកគ្រប់គ្រងការងារ ដែលត្រូវត្រួតពិនិត្យឡើងវិញ លើដំណើរការរៀបចំ និងបង្ហាញនូវការរកឃើញ ឬ ការ សង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធីនោះ ។

## ៥.  សកម្មភាព

ក្រុមរៀបចំកម្មវិធី/អ្នកជំនាញការនឹង :

១-ស្វែងយល់ពីរបាយការណ៍ ឬ ឯកសារការងារ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ B1 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

២-ពិនិត្យឡើងវិញលើ កម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយ ភាពក្រីក្រ (NPHFSPR) ឆ្នាំ ២០០៧-២០១១ ដោយរៀបចំនូវផ្នែកផ្សេងៗ លទ្ធផល និងសកម្មភាព ដូចដែលបានកំណត់ក្នុងចំណុច ២ (ទំហំ) ។

៣- ធ្វើការប្រឹក្សា តាមការចាំបាច់ ជាមួយមន្ត្រីសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (រួមទាំងបុគ្គលិកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ផង) តាមការសមស្រប ។

៤-ដាក់ជូននូវពង្រាងឯកសាររៀបចំកម្មវិធី ធ្វើការកែតំរូវដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងយោបល់របស់អ្នកគ្រប់គ្រងការងារ និងអ្នកពាក់ព័ន្ធនានា និងដាក់ជូននូវឯកសាររៀបចំកម្មវិធីចុងក្រោយ ។

៥-ធ្វើការទំនាក់ទំនងជាមួយក្រុមរៀបចំកម្មវិធីផ្សេងទៀត ដែលចុះកិច្ចសន្យាជាមួយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។

៦-ជួយដល់ក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្នុងការចងក្រងនូវឯកសារនេះ និងការរៀបចំកម្មវិធីផ្សេងទៀត ទៅជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយសំរាប់វិស័យកសិកម្ម និងទឹក (តែអ្នកជំនាញជាតិតែប៉ុណ្ណោះ)??? ។

៧-ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ តាមរយៈមធ្យោបាយផ្តល់ឯកសារជំនួយស្មារតី នៃការរកឃើញនានា ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធី និងពិនិត្យឡើងវិញនូវដំណើរការរៀបចំកម្មវិធី ។

៨-បង្ហាញសង្ខេបដោយផ្ទាល់មាត់ នូវគំរោងកម្មវិធីដែលលើកឡើង ក្នុងសិក្ខាសាលា សំរាប់សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។

## ៦. ពេលវេលា

ការងារនេះ គឺត្រូវបានរំពឹងថា នឹងអនុវត្តន៏ក្នុងរយៈពេល ៣ សប្តាហ៍ :

១-ពង្រាងឯកសាររៀបចំកម្មវិធី : ចុងសប្តាហ៍ទី ១

២-យោបល់របស់អ្នកពាក់ព័ន្ធ ផ្តល់ដល់ក្រុមរៀបចំ ឬ អ្នកជំនាញការ : ចុងសប្តាហ៍ទី ២

៣-ឯកសាររៀបចំកម្មវិធីចុងក្រោយ និងជំនួយស្មារតី : ពាក់កណ្តាលសប្តាហ៍ទី៣

៤-ការបង្ហាញក្នុងសិក្ខាសាលារបស់ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក : ចុងសប្តាហ៍ទី៣

## ៧. សមាសភាពរបស់ក្រុម

មានតែអ្នកជំនាញការផ្នែកសន្តិសុខស្បៀងថ្នាក់អន្តរជាតិម្នាក់ប៉ុណ្ណោះ ដែលនឹងធ្វើការកែតំរូវឡើងវិញ និងរៀបចំសំរេចនូវឯកសារ កម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ (NPHFSPR) ឆ្នាំ ២០០៧-២០១១ ។ និងថ្នាក់ ជាតិម្នាក់ ។ ការរួមចំណែករបស់ អ្នកជំនាញការអន្តរជាតិនេះនឹងត្រូវការក្នុងរយៈពេល ៣ សប្តាហ៍នេះពេញ ។

## ៨. ថវិកា

| **រាយមុខរបស់** | **តំលៃ** (ដុល្លាអាមេរិក) |
|---|---|
| អ្នកជំនាញការអន្តរជាតិ ដែលអាចរកបាននៅក្នុងស្រុក តំលៃ ២១ថ្ងៃ x ៣៥០ ដុល្លា | ៧ ៣៥០ |
| ការចំណាយផ្សេងៗ: សំភារៈការិយាល័យ ការបោះពុម្ព ប្រជុំ សិក្ខាសាលា ការបកប្រែ | ១ ០០០ |
| **សរុប** | ៨ ៣៥០ |

# លក្ខខ័ណ្ឌការងារ សំរាប់ក្រុមរៀបចំកម្មវិធី
# កម្មវិធីគាំទ្រដល់កសិកម្ម និង កសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ)

## ១-សាវតា

សាវតា ចំពោះការងាររៀបចំកម្មវិធីនេះ ត្រូវបានផ្តល់នៅក្នុងរបាយការណ៍រៀបចំយុទ្ធសាស្ត្រ II (ឯកសារបន្ថែម ១) ។ យុទ្ធសាស្ត្រនេះ នឹងជួយ ជាពិសេស ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវ និងសំរេចបាននូវគោលដៅ ដែលកំណត់ដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ និងដោយគោលដៅអភិវឌ្ឍន៍សហសវត្ស របស់ប្រទេសកម្ពុជា ។ ពតិមានបន្ថែម មានផ្តល់នៅក្នុងឯកសារការងារ ស្តីពីឯកសារយុទ្ធសាស្ត្រ សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមក្នុងវិស័យកសិកម្ម និងទឹក (មាននៅលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក) ។

គោលដៅសំខាន់ៗរបស់យុទ្ធសាស្ត្រ នឹងត្រូវសំរេចបានតាមរយៈការងារក្នុងកម្មវិធីទាំងប្រាំ ។ កម្មវិធីមួយក្នុងចំណោមកម្មវិធី ទាំងនោះ គឺ កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ) ។

## ២- គោលបំណង

គោលបំណងសំខាន់ នៃក្រុមរៀបចំកម្មវិធី គឺ :

ដើម្បីរៀបចំកម្មវិធី ដែលទទួលយកបានដោយសហប្រធាន នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹកចំពោះ កម្មវិធីគាំទ្រដល់កសិកម្ម និងកសិ-ធុរកិច្ច (ប្រព័ន្ធតំលៃ) ។

កាលបរិច្ឆេទ ដែលគ្រោងរៀបចំបញ្ចប់នូវគោលបំណងនេះ គឺ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៦ ។

## ៣- ទំហំ

របាយការណ៍ព្រាងស្តីពីការបង្កើតយុទ្ធសាស្ត្រ II (ក្នុងឯកសារបន្ថែម ចំណុច ៦.២) បង្ហាញនូវទំហំនៃកម្មវិធី ។ វាផ្អែកទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួម ចំណែកដល់ដំណើរការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ គោលបំណង លទ្ធផល និងសកម្មភាពនានា ដែលបានកំណត់រួចហើយក្នុងផែនការនេះ នឹងត្រូវកែតំរូវឡើងវិញ ប្រមូលផ្តុំ និង/ឬ បន្ថែមតាមការចាំបាច់ ។ ចាំបាច់ត្រូវធ្វើការងារបន្ថែមទៀត លើកម្មវិធីនេះ ជាពិសេសដោយផ្តល់នូវសកម្មភាពសំខាន់ៗ លំអិតថែមទៀត និងប៉ាន់ស្មាននូវធនធានដែលត្រូវការ ដើម្បីធានាថា វាបានផ្តល់នូវមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈល្អមួយ ក្នុងការចែកចាយធនធាន ដោយមន្ត្រីរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ ។

ត្រូវធ្វើការរៀបចំលំអិតថែមទៀត ចំពោះផ្នែកនិមួយៗ (រួមទាំងការប៉ាន់ស្មានតំលៃ និងគោលដៅភូមិសាស្ត្រ) និងធ្វើការវិភាគស៊ីជំរៅ លើភាពទាក់ទង រវាងផ្នែកទាំងនោះ ។ ត្រូវមានការគិតពិចារណា លើទិដ្ឋភាពនៃកម្មវិធីក្នុងផ្នែកនានា ដូចខាងក្រោម :

១-កម្មវិធីជាតិ សំរាប់សន្តិសុខស្បៀងតាមគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ (ប្រព័ន្ធតំលៃ នៅក៏រិតគ្រួសារ): ផ្ទៀងផ្ទាត់នូវភាពទាក់ទង រវាងកម្មវិធីនេះ ទៅនឹងផ្នែកផ្សេងទៀត ។

២-កម្មវិធីផ្គត់ផ្គង់ធនធាន (រួមទាំងប្រព័ន្ធឥណទាន គ្រាប់ពូជ ជី គ្រឿងចក្រកសិកម្ម ប្រព័ន្ធស្រោចស្រព និងឧបករណ៍ ។ល។) ដែលមានបំណងក្នុងការគាំទ្រដល់កសិ-ធុរកិច្ចក្នុងផ្នែកទាំងនេះ នោះគឺ ការពិនិត្យឡើងវិញនូវតួនាទីរបស់សាធារណៈ ឬ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនក្នុងវិស័យនេះ ។ កំណត់នូវការផ្គត់ផ្គង់ធនធាន ទៅតាមទំហំរបស់កសិដ្ឋាន (ទំហំតូច <១.០ហត មធ្យម: ១.០-៥.០ ហត និងដំណាំមានលក្ខណពាណិជ្ជកម្មធំៗ: > ៥.០ ហត) ។

៣-កម្មវិធីផលិតកម្មនៅកសិដ្ឋាន (រួមទាំងដំណាំ ចំការកៅស៊ូតូចៗ ការចិញ្ចឹមសត្វ ការគ្រប់គ្រងទឹកសំរាប់ដំណាំ កម្មវិធីជីកស្រះ និងវារីវប្បកម្ម) ដែលមានគោលបំណង ក្នុងការគាំទ្រដល់កសិ-ធុរកិច្ច ក្នុងផ្នែកទាំងនេះ នោះគឺ ការកំណត់នូវការឧបត្ថម្ភទៅតាមទំហំកសិដ្ឋាន (ទំហំតូច <១.០ហត មធ្យម: ១.០-៥.០ ហត និងដំណាំជាលក្ខណពាណិជ្ជកម្មធំៗ: > ៥.០ ហត) ។ ហើយក៏ត្រូវរួមបញ្ចូលនូវការអនុវត្តន៏ នូវពិពិធកម្មកសិកម្មក្នុងការរៀបចំក្នុងផ្នែកនេះដែរ ។

៤-ការកែច្នៃ និងរកទីផ្សារ (រួមទាំងការកែច្នៃកសិកម្ម ក្រោយពេលប្រមូលផល និងកម្មវិធីកសិ-ធុរកិច្ច ដោយរួមមាន ទាំងការជំនួសនូវការនាំចូល និងបង្កើននូវការនាំចេញ) ដែលមានគោលបំណង ក្នុងការគាំទ្រដល់កសិ-ធុរកិច្ច ក្នុងផ្នែកទាំងនេះ ហើយដោយដាក់បញ្ចូលក្នុងការរៀបចំនូវផ្នែកទាំងនេះ នូវពិចារណាលើការបណ្តុះបណ្តាលជំនាញ (ឧទាហរណ៍ ក្នុងការកែច្នៃ ការរកទីផ្សារ ។ល។) បង្កើនប្រសិទ្ធិភាពមាស៊ីនកិនស្រូវ និងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ។ កំណត់នូវការឧបត្ថម្ភទៅតាមទំហំកសិដ្ឋាន (ទំហំតូច <១.០ហត មធ្យម: ១.០-៥.០ ហត និងដំណាំជាលក្ខណពាណិជ្ជកម្មធំៗ: > ៥.០ ហត) ។

៥-ធ្វើការអភិវឌ្ឍន៏ទីផ្សារសំរាប់អ្នកផលិត និងអ្នកប្រើប្រាស់ (រួមទាំងសន្តិសុខស្បៀង ការត្រួតពិនិត្យ និងធានាគុណភាព ពតិមាន ...)

៦-បង្កើនអង្គការកសិករ (ដែលជាផ្នែកមួយនៃការផ្សព្វផ្សាយផងដែរ): កំណត់នូវតួនាទីរបស់ផ្នែកសាធារណៈ ឬ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ក៏ដូចជា តួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងផ្នែកនេះដែរ ។ រួមបញ្ចូលក្នុងការរៀបចំក្នុងផ្នែកទាំងនេះ នូវការពិចារណាលើ ការធ្វើកិច្ចសន្យាក្នុងកសិកម្ម ដែលមានប្រយោជន៏ដល់អ្នកក្រីក្រ បទបញ្ញត្តិ និងយន្តការដែលទាក់ទង ។ ហើយក៏ត្រូវកំណត់ផងដែរ នូវអង្គការកសិករ ដែលមាន

គោលបំណងជាក់លាក់ ដែលនឹងជំរុញដល់សន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ ការធ្វើឱ្យមានលក្ខណៈពាណិជ្ជកម្ម ចំពោះសហគមន៍កសិករប្រើប្រាស់ទឹក និងកសិកម្ម ។

៧-កម្មវិធីឥណទានជនបទ សំរាប់ការអភិវឌ្ឍន៏កសិកម្ម និងទឹក ដោយកំណត់នូវការគាំទ្រ ទៅតាមទំហំកសិដ្ឋាន (ទំហំតូច <១.០ហត មធ្យមៈ ១.០-៥.០ ហត និងដំណាំជាលក្ខណពាណិជ្ជកម្មធំៗៈ > ៥.០ ហត) ។ ហើយក៏ត្រូវកំណត់ឱ្យបានច្បាស់ផងដែរ នូវយន្តការក្នុងការធានានូវតម្លាភាព នៃការផ្តល់សេវាកម្មឥណទាន និងលំហូរនៃពត៌មានដែលទាក់ទង ។

៨-ផ្តែកធានាដល់ដំណាំៈ កំណត់នូវការគាំទ្រ ជាពិសេស ចំពោះកសិករ ដែលមានកសិដ្ឋានតូច និងមធ្យម ក៏ដូចជាកសិករដែលឋិតក្នុងតំបន់ដែលអាចរងគ្រោះ ។

៩-ទេសចរណ៍ដែលទាក់ទង និងទឹក និងកសិកម្ម ដោយធ្វើការវាយតំលៃលើលទ្ធភាពក្នុងផ្តែកនេះ ។

## ៤. លទ្ធផល និង របាយការណ៍

១-ឯកសារគោលគំនិតមួយ នឹងត្រូវផ្តល់ដល់អ្នកគ្រប់គ្រងការងារ ក្នុងរយៈពេលមួយសប្តាហ៍ នៃការចាប់ផ្តើមការងារ ។

២-លទ្ធផលសំខាន់ៗនោះ គឺឯកសាររៀបចំកម្មវិធីមួយ ជាពង្រាង និងចុងក្រោយ (សូមមើលចំណុច ៥) ។ ឯកសាររៀបចំកម្មវិធី ត្រូវអនុវត្តន៍តាមទំរង់ដែលអាចទទួលយកបាន និងដែលណែនាំដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងមានសង្ខេបក្នុងក្របខ័ណ្ឌជាក់ស្តែងមួយ ។ ឯកសារនេះ នឹង បង្ហាញនូវបណ្តុំនៃសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវអនុវត្តន៏ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងកំលុងរយៈពេលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ ជាតិទី III ហើយដែលសកម្មភាពនេះរួមគ្នា នឹងជួយឱ្យក្រសួងទាំងពីរនេះ សំរេចបានប្រកបដោយប្រសិទ្ធិភាព នូវគោលដៅរបស់គេ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ។

៣-លទ្ធផលសំខាន់ៗ នឹងគាំទ្រដោយ (1) ការបង្ហាញដោយផ្ទាល់មាត់ ក្នុងសិក្ខាសាលាមួយចំពោះ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និង (2) មានឯកសារជំនួយស្មារតីមួយ ផ្តល់ដល់អ្នកគ្រប់គ្រងការងារ ដែលត្រូវត្រួតពិនិត្យឡើងវិញ លើដំណើរការរៀបចំ និងបង្ហាញនូវការរកឃើញ ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធីនោះ ។

## ៥. សកម្មភាព

ក្រុមរៀបចំកម្មវិធីនឹង :

១- ស្វែងយល់ពីរបាយការណ៍ ឬ ឯកសារការងារ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ B1 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

២- ដាក់ជូននូវឯកសារគោលគំនិត ដែលមានបង្ហាញផងដែរ នូវផែនការការងារគំរូ សំរាប់ធ្វើឯកសាររៀបចំកម្មវិធី និងការយល់ដឹងរបស់ក្រុម លើវិធីសាស្ត្រដែលបានស្នើឡើងចំពោះការងារនោះ ។

៣-ធ្វើការប្រឹក្សា តាមការចាំបាច់ ជាមួយមន្ត្រីសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (រួមទាំងបុគ្គលិកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ផង) តាមការសមស្រប ។

៤- ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ យ៉ាងហោចណាស់មួយសប្តាហ៍ម្តង តាមរយៈអ៊ីម៉ែល ស្តីពីកិច្ចដំណើរការ និងបញ្ហានានា ដែលអាចរារាំងដល់ការបញ្ចប់ការងារដោយជោគជ័យនោះ ។

៥- ដាក់ជូននូវពង្រាងឯកសាររៀបចំកម្មវិធី ធ្វើការកែតំរូវដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងយោបល់របស់អ្នកគ្រប់គ្រងការងារ និងអ្នកពាក់ព័ន្ធនានា និងដាក់ជូននូវឯកសាររៀបចំកម្មវិធីចុងក្រោយ ។

៦-ធ្វើការទំនាក់ទំនង ជាមួយក្រុមរៀបចំកម្មវិធីផ្សេងទៀត ដែលចុះកិច្ចសន្យា ជាមួយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។

៧-ជួយដល់ក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្នុងការចងក្រងនូវឯកសារនេះ និងការរៀបចំកម្មវិធីផ្សេងទៀត ទៅជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយ សំរាប់វិស័យកសិកម្ម និងទឹក (តែអ្នកជំនាញជាតិតែប៉ុណ្ណោះ) ។

៨-ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ តាមរយៈមធ្យោបាយផ្តល់ឯកសារជំនួយស្មារតី នៃការរកឃើញនានា ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធី និងពិនិត្យឡើងវិញនូវដំណើរការរៀបចំកម្មវិធី ។

៩-បង្ហាញដោយផ្ទាល់មាត់ នូវគំរោងកម្មវិធីដែលលើកឡើង ក្នុងសិក្ខាសាលា សំរាប់សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។ ការបង្ហាញនោះ ត្រូវមានរៀបចំជាការបង្ហាញតាមកុំព្យូទ័រ (Power point) និងមានឯកសារចែកផង ។

## ៦. ពេលវេលា

ការងារនេះ គឺត្រូវបានរំពឹងថា នឹងអនុវត្តន៍ក្នុងរយៈពេល ២ខែ :

១-ការចាប់ផ្តើមការងារ : ដើមសប្តាហ៍ទី ១

២-របាយការណ៍គោលគំនិត (Inception report) : ដើមសប្តាហ៍ទី ២

៣-ឯកសាររៀបចំកម្មវិធី : ចុងសប្តាហ៍ទី ៥

៤-យោបល់របស់អ្នកគ្រប់គ្រងកម្មវិធី ផ្តល់ដល់ក្រុម : ចុងសប្តាហ៍ទី ៧

៥-ឯកសាររៀបចំកម្មវិធីចុងក្រោយ និងជំនួយស្មារតី : ពាក់កណ្តាលសប្តាហ៍ទី ៩

៦-ការបង្ហាញក្នុងសិក្ខាសាលារបស់ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក : ចុងសប្តាហ៍ទី ៩

## ៧. សមាសភាពរបស់ក្រុម

ក្រុមរៀបចំកម្មវិធី នឹងរួមមាន អ្នកជំនាញផ្នែកកសិ-ធុរកិច្ច ថ្នាក់អន្តរជាតិម្នាក់ និងអ្នកជំនាញខាងកសិកម្ម ថ្នាក់ជាតិម្នាក់ ។ ការរួមចំណែករបស់អ្នកជំនាញការជាតិ គឺក្នុងរយៈពេល ៩សប្តាហ៍ ពេញ ។ ឯការរួមចំណែករបស់ អ្នកជំនាញការអន្តរជាតិ តាមចំណុច ៦ ខាងលើ គឺនឹងត្រូវការក្នុងរយៈពេល ៥ សប្តាហ៍ ដំបូង ។

## ៨. ថវិកា

| **រាយមុខរបស់** | **តំលៃ** (ដុល្លាអាមេរិក) |
|---|---|
| អ្នកជំនាញការអន្តរជាតិ តំលៃ ក្នុង ១ ខែ ១២ ០០០ ដុល្លាអាមេរិក | ១២ ០០០ |
| អ្នកជំនាញការជាតិ តំលៃក្នុងមួយថ្ងៃ ៨០ ដុល្លាអាមេរិក | ៣ ១៥០ |
| អ្នកជំនាញការអន្តរជាតិ ប្រាក់ឧបត្ថម្ភបន្ថែម ៣០ ថ្ងៃ x ៨០ ដុល្លាអាមេរិក | ២ ៤០០ |
| អ្នកជំនាញការអន្តរជាតិ ការធ្វើដំណើរទៅមកម្តង ១ ៥០០ ដុល្លាអាមេរិក | ១ ៥០០ |
| ការចំណាយក្នុងស្រុក: សំភារៈការិយាល័យ បោពុម្ភ ប្រជុំ សិក្ខាសាលា ការបកប្រែ | ៥ ០០០ |
| **សរុប** | ២៤ ០៥០ |

## លក្ខខណ្ឌការងារ សំរាប់ក្រុមរៀបចំកម្មវិធី
## កម្មវិធីគ្រប់គ្រងធនធានទឹក ប្រព័ន្ធស្រោចស្រព និងដីធ្លី

### ១. សាវតា

សាវតា ចំពោះការងាររៀបចំកម្មវិធីនេះ ត្រូវបានផ្តល់នៅក្នុងរបាយការណ៍រៀបចំយុទ្ធសាស្ត្រ II (ឯកសារបន្ថែម ១) ។ យុទ្ធសាស្ត្រនេះ នឹងជួយ ជាពិសេស ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៍នូវការទទួលខុសត្រូវ និងសំរេចបាននូវគោលដៅ ដែលកំណត់ដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ និងដោយគោលដៅអភិវឌ្ឍន៍សហសវត្ស របស់ប្រទេសកម្ពុជា ។ ពត៌មានបន្ថែម មានផ្តល់នៅក្នុងឯកសារការងារ ស្តីពីឯកសារយុទ្ធសាស្ត្រ សំរាប់រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមក្នុងវិស័យកសិកម្ម និងទឹក (មាននៅលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក) ។

គោលដៅសំខាន់ៗរបស់យុទ្ធសាស្ត្រ នឹងត្រូវសំរេចបានតាមរយៈការងារក្នុងកម្មវិធីទាំងប្រាំ ។ កម្មវិធីមួយ ក្នុងចំណោមកម្មវិធី ទាំងនោះ គឺ "កម្មវិធីគ្រប់គ្រងធនធានទឹក ប្រព័ន្ធធារាសាស្ត្រ និងដីធ្លី" ។

### ២. គោលបំណង

គោលបំណងសំខាន់ នៃក្រុមរៀបចំកម្មវិធី គឺ :

ដើម្បីរៀបចំកម្មវិធី ដែលទទួលយកបានដោយសហប្រធាន នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ចំពោះ កម្មវិធីគ្រប់គ្រងធនធានទឹក ប្រព័ន្ធធារាសាស្ត្រ និងដីធ្លី ។

កាលបរិច្ឆេទ ដែលគ្រោងរៀបចំបញ្ចប់នូវគោលបំណងនេះ គឺ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៦ ។

### ៣. ទំហំ

របាយការណ៍ព្រាងស្តីពីការបង្កើតយុទ្ធសាស្ត្រ II (ក្នុងឯកសារបន្ថែម ចំណុច ៦.៤) បង្ហាញនូវទំហំនៃកម្មវិធី ។ វាផ្អែកទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួម ចំណែកដល់ដំណើរការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ គោលបំណង លទ្ធផល និងសកម្មភាពនានា ដែលបានកំណត់រួចហើយក្នុងផែនការនេះ នឹងត្រូវកែតំរូវឡើងវិញ ប្រមូលផ្តុំ និង/ឬ បន្ថែមតាមការចាំបាច់ ។ ចាំបាច់ត្រូវធ្វើការងារបន្ថែមទៀត លើកម្មវិធីនេះ ជាពិសេស ដោយផ្តល់នូវសកម្មភាពសំខាន់ៗ លំអិតថែមទៀត និងប៉ាន់ស្មាននូវធនធានដែលត្រូវការ ដើម្បីធានាថា វាបានផ្តល់នូវមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈល្អមួយ ក្នុងការចែកចាយធនធាន ដោយមន្ត្រីរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ខាងក្រៅ ។

បន្ថែមពីលើចំណុចខាងលើនេះទៀត គឺត្រូវមានការគិតពិចារណាផងដែរលើទិដ្ឋភាព នៃកម្មវិធីក្នុងផ្នែកនានា ដូចខាងក្រោម :

១-ប្រមែប្រមូលរួមគ្នា នូវធនធានទឹក និងដីដែលអាចដាំដំណាំបាន ដោយអនុវត្តន៍តាមវិធីសាស្រ្តគ្រប់គ្រងអាងទន្លេរួម ។

២-បង្កើតនូវលក្ខខ័ណ្ឌ ក្នុងការជ្រើសរើសអាងទន្លេដែលមានអាទិភាព ដោយយកចិត្តទុកដាក់ដល់ភាពទាក់ទង រវាងតំបន់ដែលមានអសន្តិសុខស្បៀង តំបន់ដែលអាចរងគ្រោះ និងឱកាសក្នុងការធ្វើពាណិជកម្ម ។

៣-បច្ចេកវិជ្ជាសំរាប់គ្រប់គ្រង និងប្រើប្រាស់ទឹក ប្រកបដោយនិរន្តរភាព សំរាប់កសិកម្ម ក្នុងតំបន់ ដែលពឹងផ្អែកលើទឹកភ្លៀង ដែលស្រោចស្រពបន្ថែម និងស្រោចស្រពទាំងស្រុង ក្នុងកំរិតចាប់ពីគ្រួសារមួយរហូតដល់កំរិតខ្នាតធំ ។

## ៤. លទ្ធផល និង របាយការណ៍

១-ឯកសារគោលគំនិតមួយ នឹងត្រូវផ្តល់ដល់អ្នកគ្រប់គ្រងការងារ ក្នុងរយៈពេលមួយសប្តាហ៍ នៃការចាប់ផ្តើមការងារ ។

២-លទ្ធផលសំខាន់ៗនោះ គឺឯកសាររៀបចំកម្មវិធីមួយ ជាពង្រាង និងចុងក្រោយ (សូមមើលចំណុច ៥) ។ ឯកសាររៀបចំកម្មវិធី ត្រូវអនុវត្តន៍តាមទំរង់ដែលអាចទទួលយកបាន និងដែលណែនាំដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងមានសង្ខេបក្នុងក្របខ័ណ្ឌជាក់ស្តែងមួយ ។ ឯកសារនេះ នឹង បង្ហាញនូវបណ្តុំនៃសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងកំលុងរយៈពេលផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ជាតិទី III ហើយដែលសកម្មភាពនេះរួមគ្នា នឹងជួយឱ្យក្រសួងទាំងពីរនេះ សំរេចបានប្រកបដោយប្រសិទ្ធិភាព នូវគោលដៅរបស់គេ ក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។

៣-លទ្ធផលសំខាន់ៗ នឹងគាំទ្រដោយ (1) ការបង្ហាញដោយផ្ទាល់មាត់ ក្នុងសិក្ខាសាលាមួយចំពោះ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និង (2) មានឯកសារជំនួយស្មារតីមួយ ផ្តល់ដល់អ្នកគ្រប់គ្រងការងារ ដែលត្រូវត្រួតពិនិត្យឡើងវិញ លើដំណើរការរៀបចំ និងបង្ហាញនូវការរកឃើញ ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធីនោះ ។

## ៥. សកម្មភាព

ក្រុមរៀបចំកម្មវិធីនឹង :

១- ស្វែងយល់ពីរបាយការណ៍ ឬ ឯកសារការងារ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ B1 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

២- ដាក់ជូននូវឯកសារគោលគំនិត ដែលមានបង្ហាញផងដែរ នូវផែនការការងារគំរូ សំរាប់ធ្វើឯកសាររៀបចំកម្មវិធី និងការយល់ដឹងរបស់ក្រុម លើវិធីសាស្ត្រដែលបានស្នើឡើងចំពោះការងារនោះ ។

៣-ធ្វើការប្រឹក្សា តាមការចាំបាច់ ជាមួយមន្ត្រីសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (រួមទាំងបុគ្គលិកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ផង) តាមការសមស្រប ។

៤- ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ យ៉ាងហោចណាស់មួយសប្តាហ៍ម្តង តាមរយៈអ៊ីម៉ែល ស្តីពីកិច្ចដំណើរការ និងបញ្ហានានា ដែលអាចរារាំងដល់ការបញ្ចប់ការងារដោយជោគជ័យនោះ ។

៥- ដាក់ជូននូវពង្រាងឯកសាររៀបចំកម្មវិធី ធ្វើការកែតំរូវដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងយោបល់របស់អ្នកគ្រប់គ្រងការងារ និងអ្នកពាក់ព័ន្ធនានា និងដាក់ជូននូវឯកសាររៀបចំកម្មវិធីចុងក្រោយ ។

៦-ធ្វើការទំនាក់ទំនង ជាមួយក្រុមរៀបចំកម្មវិធីផ្សេងទៀត ដែលចុះកិច្ចសន្យា ជាមួយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។

៧-ជួយដល់ក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្នុងការចងក្រងនូវឯកសារនេះ និងការរៀបចំកម្មវិធីផ្សេងទៀត ទៅជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយ សំរាប់វិស័យកសិកម្ម និងទឹក (តែអ្នកជំនាញជាតិតែប៉ុណ្ណោះ) ។

៨-ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ តាមរយៈមធ្យោបាយផ្តល់ឯកសារជំនួយស្មារតី នៃការរកឃើញនានា ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធី និងពិនិត្យឡើងវិញនូវដំណើរការរៀបចំកម្មវិធី ។

៩-បង្ហាញដោយផ្ទាល់មាត់ នូវគំរោងកម្មវិធីដែលលើកឡើង ក្នុងសិក្ខាសាលា សំរាប់សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។ ការបង្ហាញនោះ ត្រូវមានរៀបចំជាការបង្ហាញតាមកុំព្យូទ័រ (Power point) និងមានឯកសារចែកផង ។

## ៦. ពេលវេលា

ការងារនេះ គឺត្រូវបានរំពឹងថា នឹងអនុវត្តន៏ក្នុងរយៈពេល ២ខែ :

១-ការចាប់ផ្តើមការងារ : ដើមសប្តាហ៏ទី ១

២-របាយការណ៏គោលគំនិត (Inception report) : ដើមសប្តាហ៏ទី ២

៣-ឯកសាររៀបចំកម្មវិធី : ចុងសប្តាហ៏ទី ៥

៤-យោបល់របស់អ្នកគ្រប់គ្រងកម្មវិធី ផ្តល់ដល់ក្រុម : ចុងសប្តាហ៏ទី ៧

៥-ឯកសាររៀបចំកម្មវិធីចុងក្រោយ និងជំនួយស្មារតី : ពាក់កណ្តាលសប្តាហ៏ទី ៩

៦-ការបង្ហាញក្នុងសិក្ខាសាលារបស់ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក : ចុងសប្តាហ៏ទី ៩

## ៧. សមាសភាពរបស់ក្រុម

ក្រុមរៀបចំកម្មវិធី នឹងរួមមាន អ្នកជំនាញផ្នែក.......................... ថ្នាក់អន្តរជាតិម្នាក់ និងអ្នកជំនាញ..........................ថ្នាក់ជាតិម្នាក់ ។ ការរួមចំណែករបស់អ្នកជំនាញការជាតិ គឺក្នុងរយៈពេល ៩សប្តាហ៏ ពេញ ។ ឯការ រួមចំណែករបស់ អ្នកជំនាញការអន្តរជាតិ តាមចំណុច ៦ ខាងលើ គឺនឹងត្រូវការក្នុងរយៈពេល ៥ សប្តាហ៏ ដំបូង ។

## ៨. ថវិកា

| **រាយមុខរបស់** | **តំលៃ** (ដុល្លាអាមេរិក) |
|---|---|
| អ្នកជំនាញការអន្តរជាតិ តំលៃ ក្នុង ១ ខែ ១២ 000 ដុល្លាអាមេរិក | ១២ 000 |
| អ្នកជំនាញការជាតិ តំលៃក្នុងមួយថ្ងៃ ៨0 ដុល្លាអាមេរិក | ៣ ១៥0 |
| អ្នកជំនាញការអន្តរជាតិ ប្រាក់ឧបត្ថម្ភបន្ថែម ៣0 ថ្ងៃ x ៨0 ដុល្លាអាមេរិក | ២ ៤00 |
| អ្នកជំនាញការអន្តរជាតិ ការធ្វើដំណើរទៅមកម្តង ១ ៥00 ដុល្លាអាមេរិក | ១ ៥00 |
| ការចំណាយក្នុងស្រុកៈ សំភារៈការិយាល័យ បោពុម្ព ប្រជុំ សិក្ខាសាលា ការបកប្រែ | ៥ 000 |
| **សរុប** | ២៤ 0៥0 |

## លក្ខខ័ណ្ឌការងារ សំរាប់ក្រុមរៀបចំកម្មវិធី
## កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយ កសិកម្ម និងធនធានទឹក

### ១. សាវតា

សាវតា ចំពោះការងាររៀបចំកម្មវិធីនេះ ត្រូវបានផ្តល់នៅក្នុងរបាយការណ៍រៀបចំយុទ្ធសាស្រ្ត II (ឯកសារបន្ថែម ១) ។ យុទ្ធសាស្រ្តនេះ នឹងជួយ ជាពិសេស ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក្នុងការអនុវត្តន៏នូវការទទួលខុសត្រូវ និងសំរេចបាននូវគោលដៅ ដែលកំណត់ដោយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ជាតិ សំរាប់ឆ្នាំ ២០០៦-២០១០ និងដោយគោលដៅអភិវឌ្ឍន៏សហសវត្ស របស់ប្រទេសកម្ពុជា ។ ពតិមានបន្ថែម មានផ្តល់នៅក្នុងឯកសារការងារ ស្តីពីឯកសារយុទ្ធសាស្រ្ត សំរាប់រៀបចំយុទ្ធសាស្រ្តរយៈពេលមធ្យមក្នុងវិស័យកសិកម្ម និងទឹក (មាននៅលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក) ។

គោលដៅសំខាន់ៗ របស់យុទ្ធសាស្រ្ត នឹងត្រូវសំរេចបានតាមរយៈការងារក្នុងកម្មវិធីទាំងប្រាំ ។ កម្មវិធីមួយក្នុងចំណោមកម្មវិធី ទាំងនោះ គឺ កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយ កសិកម្ម និងធនធានទឹក ។

### ២. គោលបំណង

គោលបំណងសំខាន់ នៃក្រុមរៀបចំកម្មវិធី គឺ :

ដើម្បីរៀបចំកម្មវិធី ដែលទទួលយកបានដោយសហប្រធាន នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ចំពោះ កម្មវិធីសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយ កសិកម្ម និងធនធានទឹក ។

កាលបរិច្ឆេទ ដែលគ្រោងរៀបចំបញ្ចប់នូវគោលបំណងនេះ គឺ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៦ ។

### ៣. ទំហំ

របាយការណ៏ព្រាងស្តីពីការបង្កើតយុទ្ធសាស្រ្ត II (ក្នុងឯកសារបន្ថែម ចំណុច ៦.៤) បង្ហាញនូវទំហំនៃកម្មវិធី ។ វាផ្អែកទៅតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការរួម ចំណែកដល់ដំណើរការធ្វើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ជាតិ ។ គោលបំណង លទ្ធផល និងសកម្មភាពនានា ដែលបានកំណត់រួចហើយក្នុងផែនការនេះ នឹងត្រូវកែតំរូវឡើងវិញ ប្រមូលផ្តុំ និង/ឬ បន្ថែមតាមការចាំបាច់ ។ ចាំបាច់ត្រូវធ្វើការងារបន្ថែមទៀត លើកម្មវិធីនេះ ជាពិសេសដោយផ្តល់នូវសកម្មភាពសំខាន់ៗ លំអិតថែមទៀត និងប៉ាន់ស្មាននូវធនធានដែលត្រូវការ ដើម្បីធានាថា វាបានផ្តល់នូវមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈល្អមួយ ក្នុងការចែកចាយធនធាន ដោយមន្រ្តីរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៏ខាងក្រៅ ។

## ៤. លទ្ធផល និង របាយការណ៍

១-ឯកសារគោលគំនិតមួយ នឹងត្រូវផ្តល់ដល់អ្នកគ្រប់គ្រងការងារ ក្នុងរយៈពេលមួយសប្តាហ៍ នៃការចាប់ផ្តើមការងារ ។

២-លទ្ធផលសំខាន់ៗនោះ គឺឯកសាររៀបចំកម្មវិធីមួយ ជាពង្រាង និងចុងក្រោយ (សូមមើលចំណុច ៥) ។ ឯកសាររៀបចំកម្មវិធី ត្រូវអនុវត្តន៍តាមទំរង់ដែលអាចទទួលយកបាន និងដែលណែនាំដោយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និងមានសង្ខេបក្នុងក្របខ័ណ្ឌជាក់ស្តែងមួយ ។ ឯកសារនេះ នឹង បង្ហាញនូវបណ្តុំនៃសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ក្នុងកំលុងរយៈពេលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិទី III ហើយដែលសកម្មភាពនេះរួមគ្នា នឹងជួយឱ្យក្រសួងទាំងពីរនេះ សំរេចបានប្រកបដោយប្រសិទ្ធិភាព នូវគោលដៅរបស់គេ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

៣-លទ្ធផលសំខាន់ៗ នឹងគាំទ្រដោយ (1) ការបង្ហាញដោយផ្ទាល់មាត់ ក្នុងសិក្ខាសាលាមួយចំពោះ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក និង (2) មានឯកសារជំនួយស្មារតីមួយ ផ្តល់ដល់អ្នកគ្រប់គ្រងការងារ ដែលត្រូវត្រួតពិនិត្យឡើងវិញ លើដំណើរការរៀបចំ និងបង្ហាញនូវការរកឃើញ ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធីនោះ ។

## ៥. សកម្មភាព

ក្រុមរៀបចំកម្មវិធីនឹង :

១- ស្វែងយល់ពីរបាយការណ៍ ឬ ឯកសារការងារ ដែលរៀបចំឡើងដោយក្រុមយុទ្ធសាស្ត្រ B1 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធ ។

២- ដាក់ជូននូវឯកសារគោលគំនិត ដែលមានបង្ហាញផងដែរ នូវផែនការការងារគំរូ សំរាប់ធ្វើឯកសាររៀបចំកម្មវិធី និងការយល់ដឹងរបស់ក្រុម លើវិធីសាស្ត្រដែលបានស្នើឡើងចំពោះការងារនោះ ។

៣-ធ្វើការប្រឹក្សា តាមការចាំបាច់ ជាមួយមន្ត្រីសំខាន់ៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ស្ថាប័នសិក្សានានា សមាជិកក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (រួមទាំងបុគ្គលិកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ផង) តាមការសមស្រប ។

៤- ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ យ៉ាងហោចណាស់មួយសប្តាហ៍ម្តង តាមរយៈអ៊ីម៉ែល ស្តីពីកិច្ចដំណើរការ និងបញ្ហានានា ដែលអាចរារាំងដល់ការបញ្ចប់ការងារដោយជោគជ័យនោះ ។

៥- ដាក់ជូននូវពង្រាងឯកសាររៀបចំកម្មវិធី ធ្វើការកែតំរូវដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងយោបល់របស់អ្នកគ្រប់គ្រងការងារ និងអ្នកពាក់ព័ន្ធនានា និងដាក់ជូននូវឯកសាររៀបចំកម្មវិធីចុងក្រោយ ។

៦-ធ្វើការទំនាក់ទំនង ជាមួយក្រុមរៀបចំកម្មវិធីផ្សេងទៀត ដែលចុះកិច្ចសន្យា ជាមួយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។

៧-ជួយដល់ក្រុមយុទ្ធសាស្ត្រ B1 នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្នុងការចងក្រងនូវឯកសារនេះ និងការរៀបចំកម្មវិធីផ្សេងទៀត ទៅជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយ សំរាប់វិស័យកសិកម្ម និងទឹក (តែអ្នកជំនាញជាតិតែប៉ុណ្ណោះ) ។

៨-ផ្តល់យោបល់ដល់អ្នកគ្រប់គ្រងការងារ តាមរយៈមធ្យោបាយផ្តល់ឯកសារជំនួយស្មារតី នៃការរកឃើញនានា ឬ ការសង្កេត ដែលមិនបានរួមបញ្ចូលក្នុងឯកសាររៀបចំកម្មវិធី និងពិនិត្យឡើងវិញនូវដំណើរការរៀបចំកម្មវិធី ។

៩-បង្ហាញដោយផ្ទាល់មាត់ នូវគំរោងកម្មវិធីដែលលើកឡើង ក្នុងសិក្ខាសាលា សំរាប់សមាជិកក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ។ ការបង្ហាញនោះ ត្រូវមានរៀបចំជាការបង្ហាញតាមកុំព្យូទ័រ (Power point) និងមានឯកសារចែកផង ។

## ៦. ពេលវេលា

ការងារនេះ គឺត្រូវបានរំពឹងថា នឹងអនុវត្តន៍ក្នុងរយៈពេល ២ខែ :

| | | |
|---|---|---|
| ១-ការចាប់ផ្តើមការងារ | : | ដើមសប្តាហ៍ទី ១ |
| ២-របាយការណ៍គោលគំនិត (Inception report) | : | ដើមសប្តាហ៍ទី ២ |
| ៣-ឯកសាររៀបចំកម្មវិធី | : | ចុងសប្តាហ៍ទី ៥ |
| ៤-យោបល់របស់អ្នកគ្រប់គ្រងកម្មវិធី ផ្តល់ដល់ក្រុម | : | ចុងសប្តាហ៍ទី ៧ |
| ៥-ឯកសាររៀបចំកម្មវិធីចុងក្រោយ និងជំនួយស្មារតី | : | ពាក់កណ្តាលសប្តាហ៍ទី ៩ |
| ៦-ការបង្ហាញក្នុងសិក្ខាសាលារបស់ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក | : | ចុងសប្តាហ៍ទី ៩ |

## ៧. សមាសភាពរបស់ក្រុម

ក្រុមរៀបចំកម្មវិធី នឹងរួមមាន អ្នកជំនាញផ្នែកកសិ-ធុរកិច្ច ថ្នាក់អន្តរជាតិម្នាក់ និងអ្នកជំនាញផ្នែកកសិកម្ម ថ្នាក់ជាតិម្នាក់ ។ ការរួមចំណែករបស់អ្នកជំនាញការជាតិ គឺក្នុងរយៈពេល ៩សប្តាហ៍ ពេញ ។ ឯការរួមចំណែករបស់ អ្នកជំនាញការអន្តរជាតិ តាមចំណុច ៦ ខាងលើ គឺនឹងត្រូវការក្នុងរយៈពេល ៥ សប្តាហ៍ ដំបូង ។

## ៨. ថវិកា

| **រាយមុខរបស់** | **តំលៃ** (ដុល្លាអាមេរិក) |
|---|---|
| អ្នកជំនាញការអន្តរជាតិ តំលៃ ក្នុង ១ ខែ ១២ ០០០ ដុល្លាអាមេរិក | ១២ ០០០ |
| អ្នកជំនាញការជាតិ តំលៃក្នុងមួយថ្ងៃ ៨០ ដុល្លាអាមេរិក | ៣ ១៥០ |
| អ្នកជំនាញការអន្តរជាតិ ប្រាក់ឧបត្ថម្ភបន្ថែម ៣០ ថ្ងៃ x ៨០ ដុល្លាអាមេរិក | ២ ៤០០ |
| អ្នកជំនាញការអន្តរជាតិ ការធ្វើដំណើរទៅមកម្តង ១ ៥០០ ដុល្លាអាមេរិក | ១ ៥០០ |
| ការចំណាយក្នុងស្រុក: សំភារៈការិយាល័យ បោពុម្ព ប្រជុំ សិក្ខាសាលា ការបកប្រែ | ៥ ០០០ |
| **សរុប** | ២៤ ០៥០ |